សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# វិធានការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ ដោយចៅក្រមស៊ើបសួរ

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **វ៉ាន់ ធារិត**

លោក **គួន មាសសាម៉ន**

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ាង ឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **វ៉ាន់ តារិត** និង **គួន មាសសាម៉ន** ជានិស្សិត **ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្ត** ឆ្នាំទី ៤ ជំនាន់ទី១៨ ក្នុងឆ្នាំសិក្សា២០១៤-២០១៨ សូមសម្តែងនូវកតញ្ញូ និងដឹងគុណដ៏ជ្រាលជ្រៅមិនអាចកាត់ថ្លៃបានដល់លោកអ្នកមានទាំងបួន គឺលោកឪពុក **ណោត វ៉ាន់** និងអ្នកម្តាយ **គឹម សារឿន** និងលោកឪពុក **គួន ម៉ៅ** និងអ្នកម្តាយ **សែម ម៉ុក** ដែលបានផ្តល់នូវកំណើតដល់រូបយើងខ្ញុំ និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងបានផ្គត់ផ្គង់ចំពោះការស្នាក់នៅ និង ការរៀនសូត្រតាំងពីថ្នាក់មតេយ្យសិក្សារហូតមកដល់កម្រិតថ្នាក់បរិញ្ញាបត្រ និង បានរួមចំណែកទាំងការផ្តល់នូវកម្លាំងចិត្ត ការអប់រំ ប្រៀនប្រដៅ និងផ្តល់នូវព្រហ្មវិហារធម៌ពីសំណាក់សំណាក់បុព្វញាតិ និងសាខាញាតិ។ សេចក្តីដឹងគុណទាំងអស់ពុំអាចកាត់ថ្លៃបាននឹងមិនអាច រៀបរាប់អស់សេចក្តីនៅក្នុងក្រដាស **ស** មួយដែលមានអក្សរលេចឡើងបន្តិចបន្តួចនេះបានឡើយ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ **ក្រសួងអប់រំ យុវជន និងកីឡា** ព្រមទាំង **សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** បានផ្តល់នូវកន្លែងបណ្តុះបណ្តាលចំណេះដឹង និងបណ្តុះនូវ ស្មារតីការស្រាវជ្រាវ និងការបង្កើនចំណេះវិជ្ជា ផ្នែកនីតិសាស្រ្ត (ច្បាប់) នេះរហូតដល់ការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នីតិសាស្រ្ត ប្រកបដោយភាពជោគជ័យ និងចំណេះដឹងពិតប្រាកដ។

យើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ** និង**លោក លោកស្រី សាស្រ្តាចារ្យ** នៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ដែលលោក លោកស្រីបានផ្តល់នូវការអប់រំ ទាំងចំណេះដឹង នឹងសីលធម៌ដល់យើងខ្ញុំក្នុងអំឡុងរយៈពេលជិត ៤ ឆ្នាំនេះ។

ជាងនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រង នៃ **បណ្ណាល័យនីតិសាស្រ្ត** បានរៀបចំ និងគ្រប់គ្រងឯកសារ ព្រមទាំងសៀវភៅ ដែលបង្ករជាលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវ និង ជាការចូលរួមចំណែកក្នុងការរៀបចំតាក់តែងសារណានេះឡើង។

ជាពិសេសនោះ យើងខ្ញុំសូមថ្លែងអំណរគុណដល់ លោកសាស្រ្តាចារ្យ **ហ៊ាង ឡេង** ដែលជាសាស្រ្តចារ្យណែនាំការសរសេរសារណានេះ ដោយលោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃផ្តល់នូវគំនិតនិងយោបល់ក្នុងការកែសម្រួល និងត្រួសត្រាយផ្លូវដល់ យើងខ្ញុំកន្លងមករហូតបានសម្រេចនូវស្នាដៃមួយនេះ។

ជាចុងក្រោយយើងសូម ថ្លែងអំណរគុណ ដល់ បងៗ ប្អូនៗ និងមិត្តនិស្សិត ដែលបានស្គាល់យើងខ្ញុំ និងបានផ្តល់នូវកម្លាំងចិត្តក្នុងការជំរុញការសរសេរ និងតាក់តែងសារណានេះឡើងដោយផ្តល់នូវគុណតម្លៃដោយទទួលទុកជាឯកសារស្រាវជ្រាវជាបណ្តោះអាសន្ន រួមជាការផ្តល់នូវគំនិតបន្តិចបន្តួចគ្រាន់ជាការស្រាវជ្រាវបន្ថែមក្នុងថ្នាក់នីតិសាស្រ្ត និង បង្ហាញបទពិសោធន៍ចំពោះការអនុវត្តជាក់ស្តែងនៅសាលាដំបូងដើម្បីយកមកប្រៀបធៀបនឹងទ្រឹស្តីដែលបានផ្តល់ដោយសាស្រ្តាចារ្យ។

# អារម្ភកថា

ដោយបានឆ្លងកាត់ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ (*ច្បាប់* ) ឆ្នាំទី៣ ឆមាសទី២ ផ្តោតទៅលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌតាមកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ និង ការខិតខំប្រឹងប្រែងស្រាវជ្រាវរួមទាំងបានរួមចំណែកអនុវត្តជាក់ស្តែងនៅសាលាដំបូងខេត្តកណ្តាល ក្នុងនាមជា ***ជំនួយការចៅក្រម*** អស់រយៈពេលជិត ០១ ឆ្នាំ ពាក់ព័ន្ធនឹងចៅក្រមស៊ើបសួរដែលបានចាប់អារម្មណ៍ និង មានគោលបំណងបង្ហាញនូវបទពិសោធន៍ជាក់ស្តែងសម្រាប់ការសិក្សាស្រាវជ្រាវទើបស្រឡាញ់លើប្រធានបទ ***"វិធានការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌដោយចៅក្រមស៊ើបសួរ"*** ដែលជាវិធានការសំខាន់សម្រាប់បទល្មើសព្រហ្មទណ្ឌដែល តំណាងអយ្យការបានសម្រេចប្តឹងមកចៅក្រមដែលទទួលបន្ទុកកិច្ចស៊ើបសួរជាពិសេសគឺប្រភេទបទល្មើសឧក្រិដ្ឋតែម្តង។

ដោយប្រធានបទមួយនេះទោះបីមានការស្រាវជ្រាវច្រើន និង តាក់តែងចងក្រងជាសារណាច្រើនក៏ពិតមែនតែគ្រាន់ជា ការផ្តល់នូវគំនិតស្រាវជ្រាវនិងបែបផែនមិនដូចគ្នាទាំងស្រុងឡើយ ជាពិសេសគឺការពន្យល់ ជាមួយនឹងនីតិវិធីអនុវត្តជាក់ស្តែង។ ដោយឃើញអំពីភាពខ្វះខាតជាច្រើនទើប សម្រេចចិត្តចងក្រងនូវខ្លឹមសារសារណានេះ ឱ្យមានលក្ខណៈល្អប្រសើរ និងទំនើបជាមុនៗ។ ក្រោយពេលដែលយើងខ្ញុំបានចូលរួម ក្នុងការអនុវត្តជាក់ស្តែងបានបង្ហាញឱ្យឃើញថា មានការលំបាកក្នុងការយកទ្រឹស្តីទៅអនុវត្តទាំងស្រុងជាមួយនឹងអំពើដែលជាបទល្មើសព្រហ្មទណ្ឌ ដែលតែងតែបានកកើតឡើងនៅក្នុងសង្គមខ្មែរជាពិសេសគឺមានស្ថានភាពប្រញាប់ និងត្រូវការអនុវត្តកាត់ៗច្រើន ប៉ុន្តែក្នុងគោលបំណងការពារយុត្តិធម៌សង្គម និងបង្ការឱ្យបាននូវការប្រព្រឹត្តបទល្មើសជាថ្មីរបស់ជនត្រូវចោទ ឬដើម្បីការពារសុវត្ថិភាពរបស់ជនត្រូវចោទ ឬ ដើម្បីការពារផលប្រយោជន៍របស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរងគ្រោះពីអំពើរបស់អ្នកផ្តើមគំនិតចារី សហចារី ឬអ្នកសមគំនិត។

ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាគឺមាន ភាពស្មុគស្មាញដោយសារតែវាជាវិធានចាប់ផ្ដុំឱ្យបុគ្គលដែលបានទទួលនូវសិទ្ធិអំណាច ត្រូវតែអនុលោមតាមគ្រប់កាលទេសៈ លើកលែងតែបញ្ញត្តិជាឆន្ទានុសិទ្ធិ របស់អាជ្ញាធរតុលាការ ក្រៅពីនេះមិនអាចធ្វើបានតាមតែអំពើចិត្តរបស់ខ្លួនឡើយ ។ កាលណាមានអំពើណាមួយដែលធ្វើឡើងដោយផ្ទុយពីអ្វីដែល ក្រមនីតិវិធីបានចាប់បង្ខំកិច្ចទាំងនោះ នឹងត្រូវបានបុគ្គលមានផលប្រយោជន៍ជាភាគីព្រហ្មទណ្ឌអាចប្តឹងសុំមោឃភាពកិច្ចទាំងនោះ ទៅស្ថាប័នមានសមត្ថកិច្ច។

ជាចុងក្រោយយើងខ្ញុំសង្ឃឹមថា គ្រប់កិច្ចការស្រាវជ្រាវរួមទាំងឯកសារយោងដែលយកមកតាំងបង្ហាញក្នុងស្នាដៃនេះវាគ្រាន់តែមានគោលបំណងសិក្សាតែប៉ុណ្ណោះ វាជៀសមិនផុតពីការធ្វេសប្រហែសបង្កើតឱ្យមាននូវកំហុសដោយប្រការណាមួយឡើយ ដូច្នេះសូមខន្តីអភ័យទោសជាមុននិងជួយកែលម្អនូវកំហុសទាំងឡាយណាដែលកើតមាននៅក្នុងស្នាដៃមួយនេះ។

យើងខ្ញុំសូមទទួលនូវការរិះគន់ពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ បងៗ ប្អូនៗ មិត្តៗនិស្សិតទាំងអស់ដែលបានអានស្នាដៃមួយនេះ និងរីករាយទទួលនូវកំហុសដែលកើតមានដោយអចេតនា។

# មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........ ១

**ជំពូកទី១.គោលការណ៍នៃការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ** ........ ៣

**ផ្នែកទី១ .គោលការណ៍ទូទៅ និងភារកិច្ចចៅក្រមស៊ើបសួរ** ........ ៣

**កថាខណ្ឌ១.គោលការណ៍ក្នុងការស្រាវជ្រាវបទល្មើស** ........ ៣

១.១.ឯករាជ្យភាពរបស់ចៅក្រមស៊ើបសួរ ........ ៤

១.២.ការធានាភាពត្រឹមត្រូវក្នុងការអនុវត្តច្បាប់ ........ ៤

១.៣.ប្រមូលភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ........ ៥

១.៤.ការទទួលខុសត្រូវចំពោះមុខងារ ........ ៥

**កថាខណ្ឌ២. ភារកិច្ចគតិយុត្តមុនចាប់ផ្តើមស្រាវជ្រាវបទល្មើស** ........ ៦

**២.១.ដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ** ........ ៦

២.១.១.ករណីចំពោះសំណុំរឿងជាក់ស្តែង ........ ៧

២.១.២.ករណីចំពោះសំណុំរឿងមិនជាក់ស្តែង ........ ៨

**២.២.ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី** ........ ៨

២.២.១.ការបញ្ជូនពាក្យបណ្តឹងទៅតំណាងអយ្យការធ្វើការចោទប្រកាន់ ........ ៨

២.២.២.ឆន្ទានុសិទ្ធិក្នុងការចាប់ផ្តើមស្រាវជ្រាវដោយខ្លួនឯង ........ ៩

**ផ្នែកទី២.សិទ្ធិអំណាចនៃការប្រើប្រាស់វិធានការនិរន្តរាយ** ........ ៩

**កថាខណ្ឌ១.វិធានការបង្ខំរបស់ចៅក្រមស៊ើបសួរ** ........ ១០

**១.១.វិធាននិរន្តរាយ** ........ ១០

១.១.១.ដីកាបង្គាប់ឲ្យចូលខ្លួន ........ ១០

១.១.២.ដីកាបង្គាប់ឲ្យនាំខ្លួន ........ ១១

១.១.៣.ដីកាបង្គាប់ឲ្យចាប់ខ្លួន ........ ១១

**១.២.វិធានការត្រួតពិនិត្យរបស់តុលាការ** ........ ១២

១.២.១.ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ........ ១២

១.២.២.ដីកាបង្គាប់ឲ្យឃុំខ្លួនជាបណ្តោះអាសន្ន ........ ១៣

១.២.៣.ដីកាបង្គាប់ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ............................ ១៣
**កថាខណ្ឌ២.លក្ខខណ្ឌ និងរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន** ........................................................ ១៤
**២.១.កម្មវត្ថុនៃការឃុំខ្លួនជាបណ្ដោះអាសន្ន** ........................................................................................ ១៤
២.១.១.លក្ខខណ្ឌនៃបុគ្គលដែលត្រូវបានចោទប្រកាន់........................................................ ១៤
២.១.២.មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន ..................................................................... ១៥
**២.២.រយៈពេល និងការពន្យារនៃការឃុំខ្លួនជាបណ្ដោះអាសន្ន**........................................................ ១៥
២.២.១.ករណីបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម............................................................................... ១៥
**ជំពូកទី២.ប្រតិបត្តិការស្រាវជ្រាវបទល្មើសដោយចៅក្រមស៊ើបសួរ**................................................ ១៧
**ផ្នែកទី១. ដំណើរការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ** ................................................................. ១៧
**កថាខណ្ឌ១.កិច្ចដំបូងក្នុងការស្រាវជ្រាវបទល្មើស**....................................................................... ១៧
**១.១.ការសួរចម្លើយជនត្រូវចោទ** ............................................................................................ ១៧
១.១.១.កំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង .......................................................... ១៧
១.១.២.កំណត់ស្ដីពីការពិភាក្សាដេញដោលចំពោះមុខ .......................................................... ១៨
១.១.៣.កំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទ........................................................... ១៩
**១.២.ការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឬជនរងគ្រោះ**................................................... ២១
១.២.១.កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ឬជនរងគ្រោះ .................. ២១
**១.៣.ការស្ដាប់ចម្លើយសាក្សី** ................................................................................................. ២២
១.៣.១.ការធ្វើសម្បថ និងករណីលើកលែង........................................................................... ២២
១.៣.២.កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយសាក្សី ................................................................ ២៣
**កថាខណ្ឌ២.ការឆែកឆេរ និងធ្វើកោសលវិច្ឆ័យ** ............................................................................ ២៥
**២.១.ការឆែកឆេរទីកន្លែងដែលពាក់ព័ន្ធនឹងបទល្មើស**................................................................ ២៥
២.១.១.ទីលំនៅឋាន ឬទីសំណាក់........................................................................................ ២៦
២.១.២.ការិយាល័យ ឬក្រុមហ៊ុនមេធាវី.................................................................................. ២៧
២.១.៣.កំណត់ហេតុចាប់យកវត្ថុតាង និងការស្ដាប់ទូរស័ព្ទ .................................................. ២៩
**២.២.ការធ្វើកោសលវិច្ឆ័យវត្ថុតាងចាប់យក**......................................................................... ៣០

២.២.១.ដីកាសម្រេចចាត់តាំងអ្នកជំនាញ ........ ៣១

២.២.២.លទ្ធផលនៃការធ្វើកោសលវិច័យ ........ ៣១

**ផ្នែកទី២ ការផ្ទេរសិទ្ធិអំណាចឲ្យស្រាវជ្រាវបទល្មើសជំនួស ........ ៣២**

**កថាខណ្ឌ១.ដីកាសម្រេចចាត់តាំងឲ្យស៊ើបសួរជំនួស ........ ៣២**

**១.១.ការចាត់តាំងចៅក្រមផ្សេងឲ្យស្រាវជ្រាវជំនួស ........ ៣៣**

១.១.១.ចៅក្រមសាលាដំបូងក្នុងសមត្ថកិច្ច ........ ៣៣

១.១.២.ចៅក្រមសាលាដំបូងផ្សេងទៀត ........ ៣៣

**១.២ ការចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ស្រាវជ្រាវជំនួស ........ ៣៤**

១.២.១.មន្ត្រីនគរបាលជាតិ ឬកងរាជអាវុធហត្ថ ........ ៣៤

១.២.២.មន្ត្រីរាជការសាធារណៈដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌ ........ ៣៤

**កថាខណ្ឌ២.សិទ្ធិអំណាចនៃការស្រាវជ្រាវបទល្មើសជំនួស ........ ៣៥**

**២.១.សិទ្ធិអំណាចដែលផ្តល់ជូនចៅក្រមស៊ើបសួរជំនួស ........ ៣៥**

២.១.១.ការកំណត់កិច្ចស៊ើបសួរជំនួសមួយផ្នែក ........ ៣៥

២.១.២.ប្រើប្រាស់អំណាចដែលចៅក្រមស៊ើបសួរមាន ........ ៣៦

**២.២.សិទ្ធិអំណាចដែលបានកំណត់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ........ ៣៦**

២.២.១.ចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរច្បាស់លាស់ ........ ៣៧

២.២.២.ករណីពិសេសដែលមិនអាចស៊ើបសួរជំនួស ........ ៣៨

**ជំពូកទី៣ ការបញ្ចប់កិច្ចការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ ........ ៣៩**

**កថាខណ្ឌ១.នីតិវិធីដើម្បីបញ្ចប់កិច្ចស្រាវជ្រាវបទល្មើស ........ ៣៩**

**១.១.ដីកាបញ្ជូនពត៌មាន និងលិខិតជូនដំណឹងបញ្ចប់កិច្ចស្រាវជ្រាវ ........ ៣៩**

១.១.១.ដីកាបញ្ជូនពត៌មានទៅអយ្យការ ........ ៤០

១.១.២.លិខិតជូនដំណឹងទៅភាគី ........ ៤០

១.១.៣.ពត៌មានបញ្ជូនត្រឡប់មកវិញ ........ ៤០

**១.២.ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ ........ ៤១**

១.២.១.មន្ត្រីអនុវត្តបញ្ជូនសំណុំរឿង ........ ៤១

១.២.២.រយៈពេលបញ្ជូនត្រឡប់វិញ ........ ៤១

**១.៣.ដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ** ........ ៤២

១.៣.១.ប្ដឹងសុំឱ្យលើកលែងការចោទប្រកាន់ ........ ៤៣

១.៣.២.ប្ដឹងសុំឲ្យកែប្រែបទចោទ ........ ៤៣

១.៣.៣.ប្ដឹងសុំឱ្យបញ្ជូនទៅជំនុំជម្រះ ........ ៤៣

**កថាខណ្ឌ២.ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ** ........ ៤៤

**២.១.ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ** ........ ៤៤

២.១.១.លើកលែងការចោទប្រកាន់ ........ ៤៥

២.១.២.កែប្រែឬ រក្សាការចោទប្រកាន់របស់តំណាងអយ្យការ ........ ៤៥

២.១.៣.សម្រេចអំពីសិទ្ធិជនត្រូវចោទក្នុងឃុំ និងវត្ថុតាង ........ ៤៥

**២.២.របៀបនៃការបញ្ជូនសំណុំរឿងរបស់ចៅក្រមស៊ើបសួរ** ........ ៤៦

២.២.១.ការជូនដំណឹងទៅគ្រប់ភាគីពាក់ព័ន្ធ ........ ៤៦

២.២.២.បញ្ជូនសំណុំរឿងទៅរដ្ឋបាលជម្រះ ........ ៤៧

**សេចក្ដីសន្និដ្ឋាន** ........ ៤៨

**អនុសាសន៍** ........ ៤៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ក្រោយពីពេលដែលបានសិក្សាលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌនាឆ្នាំទី ៣ កន្លងមកនៅក្នុងអំឡុងឆ្នាំ២០១៧ **ថ្នាក់នីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** បាននូវចំណេះដឹងនិងគំនិតបន្តិចបន្តួចទៅលើមូលដ្ឋាន នៃនីតិវិធីព្រហ្មទណ្ឌសម្រាប់ធ្វើការស្រាវជ្រាវបន្ថែមក្នុងដំណាក់កាល ចៅក្រមស៊ើបសួរដែលបានផ្តោតសំខាន់តែទៅលើគោលការណ៍ទូទៅ និងវិធានការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌរួមជាបទពិសោធន៍អនុវត្តជាក់ស្តែងនៅ សាលាដំបូងខេត្តកណ្តាល រហូតដល់ការបញ្ចប់កិច្ចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរតាមរយៈដីកាដំណោះស្រាយ។

ក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ដំណាក់កាល នៃការវិនិច្ឆ័យបទល្មើសដល់ជនល្មើសត្រូវឆ្លងកាត់នូវដំណាក់កាលរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលកសាងសំណុំរឿងបន្តមកដល់ ដំណាក់កាលរបស់អយ្យការអមសាលាដំបូងខេត្ត/រាជធានី ដើម្បីចំណាត់ការបន្តនឹងបន្តរហូតមកដល់ដំណាក់កាលចៅក្រមស៊ើបសួរ និងចុងក្រោយគឺដំណាក់កាលជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌ។

ចៅក្រមស៊ើបសួរ មានសិទ្ធិអំណាចក្នុងការស្រាវជ្រាវបទល្មើស និង បង្ហាញនូវការពិតរឿងហេតុដែលទាក់ទង នឹងអង្គហេតុដែលតំណាងអយ្យការបានប្តឹងមកខ្លួនរួមទាំងមានវិធានការមួយចំនួនដែលក្រមនីតិវិធីបានកំណត់សម្រាប់ចៅក្រមក្នុងមុខងារជាចៅក្រមស៊ើបសួរ។ ដោយក្រមនីតិវិធីព្រហ្មទណ្ឌមិនបានកំណត់ចំពោះចៅក្រមស៊ើបសួរថា មានពេលវេលាប៉ុន្មានសម្រាប់ស្រាវជ្រាវបទល្មើស ឬត្រូវបញ្ចប់នៅពេលណាឡើយដោយច្បាប់ទុកសិទ្ធិឱ្យចៅក្រមស៊ើបសួរ ធ្វើជាបុរេវិនិច្ឆ័យក្នុងការបញ្ចប់កិច្ចស៊ើបសួរ ឬបញ្ចប់តាមការស្នើសុំរបស់ភាគីព្រហ្មទណ្ឌ។ កាលដែលមិនបានកំណត់ពេលវេលាបញ្ចប់សម្រាប់កិច្ចរបស់ចៅក្រមស៊ើបសួរក្នុងការស្រាវជ្រាវបទល្មើស ធ្វើឱ្យចៅក្រមស៊ើបសួរមានពេលវេលាពេញលេញ ដើម្បីស្វែងរកភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ។ ចៅក្រមស៊ើបសួរជាតួអង្គ ០៤ ក្នុងសេចក្តីសម្រេចរបស់ខ្លួន។ សួរថាតើនឹងមានយុត្តិធម៌ទេ បើសិនជាស្ថាប័នអយ្យការធ្វើការចោទប្រកាន់ហើយទទួលបន្ទុកកិច្ចស្រាវជ្រាវបទល្មើសបន្ថែមទៀត និង ជួយរកភស្តុតាងដោះបន្ទុកឱ្យជនត្រូវចោទ? ជនរងគ្រោះដែលត្រូវបានតំណាងអយ្យការតម្កល់រឿងទុកឥតចាត់ការ? អាចដាក់ពាក្យបណ្តឹងអាជ្ញាឱ្យមានចតនាតាមវិធីណា? រួមទាំងអស់នេះហើយទើបត្រូវតែមានស្ថាប័នស៊ើបសួរមួយដែលមានឯករាជ្យភាព និងមិនស្ថិតនៅក្រោមការគាបសង្កត់ស្ថាប័នណាមួយឡើយទៅ កិច្ចដែលខ្លួនស្រាវជ្រាវ និង ត្រូវប្រមូលភស្តុតាងដែលមានការពាក់ព័ន្ធនៅក្នុងសំណុំរឿងក្តីដោយយកមកបង្ហាញនៅ ចំពោះមុខយុត្តាធិការជំនុំជម្រះ។

ដំណាក់កាលចៅក្រមស៊ើបសួរ ជាយុត្តាធិការមួយដែលនៅចន្លោះកណ្តាល រវាងអយ្យការក្នុងការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ និង ជាយុត្តាធិការជំនុំជម្រះ។ ទៀតសោទចៅក្រមស៊ើបសួរប្រៀបដូចជាយុត្តាធិការចោទប្រកាន់ផង និងយុត្តាធិការជំនុំជម្រះផងដែរ ដោយសារតែនៅពេលដែលព្រះរាជអាជ្ញាដែលជាម្ចាស់បណ្តឹងអាជ្ញាបានបើកការស៊ើបសួរ មកចៅក្រមស៊ើបសួរតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឱ្យស៊ើបសួរ នោះសិទ្ធិអំណាចទាំងស្រុងទៅលើការវិនិច្ឆ័យសម្រេចក្តីតាមរយៈ ដីកាដំណោះស្រាយរបស់ខ្លួនដោយភាពឯករាជ្យ ដោយមិនឈរទៅលើការគាបសង្កត់ពីអំណាចណាមួយឡើយ។ ក្នុងដីកាដំណោះស្រាយនោះ ចៅក្រមស៊ើបសួរ ក៏អាចសម្រេចធ្វើការប្រកាន់បទល្មើសបញ្ជូនទៅ យុត្តាធិការ

ជំនុំជម្រះតាមការប្ដឹងសុំពីតំណាងអយ្យការ ប្រសិនជាខ្លួនយល់ឃើញថាដូចគ្នា។ ប៉ុន្តែប្រសិនជាករណីដែលខ្លួនយល់ឃើញថាមិនមែនជាបទល្មើសព្រហ្មទណ្ឌខ្លួនអាចលើកលែងបទចោទ និងដោះលែងជនត្រូវចោទឱ្យមានសេរីភាពឡើងវិញ។

ការស្រាវជ្រាវនេះ មានគោលបំណងបង្ហាញនូវវិធានការដែលចៅក្រមស៊ើបសួរបានប្រើប្រាស់ក្នុងការស្វែងរកការពិត *(រឿងហេតុពិតប្រាកដជាអ្វី?)* ក្នុងអង្គហេតុ។ ចៅក្រមស៊ើបសួរមានវិធានការអ្វីខ្លះក្នុងការស្វែងរកការពិតដែលត្រូវប្រមូលភស្តុតាងស្រាវជ្រាវរកជនត្រូវចោទ ការឆែកឆេរ ឬធ្វើកោសលវិច័យលើវត្ថុតាង ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់យ៉ាងតឹងរឹងក្នុងការប្រើប្រាស់វិធានការនីមួយៗករណីខ្លះទៀតត្រូវតែប្រើប្រាស់វិធានការតាមកាលៈទេសៈនឹងស្ថានភាពជាក់ស្ដែង។ លើសពីនេះទៅទៀត និង បង្ហាញនូវបទពិសោធន៍ទាំងឡាយក្នុងការអនុវត្តជាក់ស្ដែងជាមួយនឹងចៅក្រមស៊ើបសួរ ដោយផ្ទាល់នៅសាលាដំបូងខេត្តកណ្ដាល ក្នុងការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ រួមជាមួយនឹងទ្រឹស្ដីដែលមានបញ្ញត្តិក្នុងក្រមនីតិវិធី។

ជាលទ្ធផលនៃការស្រាវជ្រាវនេះ និង បានចូលរួមចំណែកក្នុងទស្សនៈទានជាគំនិតក្នុងការអនុវត្តន៍ ជាមួយទ្រឹស្ដីក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ផ្នែកចៅក្រមស៊ើបសួរទៅលើដំណើរការនីតិវិធីដែលអនុវត្តជាក់ស្ដែងនៅតាមសាលាដំបូង រហូតដល់ស្វែងរកឃើញការពិត។ មុនចាប់ផ្ដើមចៅក្រមស៊ើបសួរត្រូវធ្វើកិច្ចណាអ្វីខ្លះ ក្នុងអំឡុងពេលស្រាវជ្រាវត្រូវធ្វើដូចម្ដេចខ្លះ? នឹងមានឯកសារជារូបរាងយ៉ាងដូចម្ដេចហើយនឹងបន្តទៅណា?ទៀតរហូត ដល់ពេលបញ្ចប់កិច្ចការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌរបស់ចៅក្រមស៊ើបសួរ។ ដែលការស្រាវជ្រាវប្រធានបទមួយនេះ មានរចនាបទដូចខាងក្រោមនេះ៖

**ជំពូកទី១.គោលការណ៍នៃការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ**

**ជំពូកទី២.ប្រតិបត្តិការស្រាវជ្រាវបទល្មើសដោយចៅក្រមស៊ើបសួរ**

**ជំពូកទី៣.ការបញ្ចប់កិច្ចការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ**

# ជំពូកទី១

# គោលការណ៍នៃការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ

ជាគោលការណ៍នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលមាន នាពេលបច្ចុប្បន្នកាលណាដែលមានបទល្មើសបានកើតឡើង តំណាងអយ្យការតែងតែបើកការស៊ើបសួរ មកចៅក្រមស៊ើបសួរ ដើម្បីធ្វើស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ ឱ្យមូលពេញលេញសិនមុន និងបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ក្នុងករណីដែលជាសំណុំរឿងមានភាពស្មុគស្មាញ និង មិនមានភស្តុតាងដាក់បន្ទុកលើជនសង្ស័យគ្រប់គ្រាន់ ឬអាចជាបទល្មើស ឧក្រិដ្ឋដែលច្បាប់តម្រូវ។ ដើម្បីអាចឱ្យការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌមួយមានភាពច្បាស់លាស់ និង ជៀសវាងនូវភាពអគតិទាំងបួន។[១] ច្បាប់បានតម្រូវចំពោះចៅក្រមស៊ើបសួរ ក្នុងការបំពេញកិច្ចស្រាវជ្រាវបទល្មើសរបស់ខ្លួនប្រកបដោយភាពត្រឹមត្រូវ នឹងអាចជួយផ្តល់នូវយុត្តិធម៌ដល់សង្គមបាន។

## ផ្នែកទី១.គោលការណ៍ទូទៅ និងភារកិច្ចចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ គឺជារូបវន្តបុគ្គលដែលមានឋានៈជាអ្នកស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌក្នុងគោលបំណងបង្ហាញនូវភាពត្រឹមត្រូវ និង មានភស្តុតាងគ្រប់គ្រាន់ដើម្បីដោះបន្ទុក ឬដាក់បន្ទុកឱ្យជនត្រូវចោទ។ ចៅក្រមស៊ើបសួរ នាពេលដំណើរការរឿងក្តីរបស់ខ្លួនត្រូវតែមានភាពយុត្តិធម៌ និងឈរនៅកណ្តាល គ្រប់ភាគីព្រហ្មទណ្ឌ ឬហៅថា *"កញ្ចក់ឆ្លុះបញ្ចាំងនៃហេតុការណ៍ពិតប្រាកដ"* ដែលខ្លួនត្រូវបានច្បាប់ដាក់នូវភារកិច្ច ដើម្បីឱ្យចៅក្រមស៊ើបសួរ ដំណើរការដោយគ្មានភាពលម្អៀង ឬសកម្មក្នុងការស្រាវជ្រាវ និងស្វែងរកការពិតជូនដល់ ជនស្លូតត្រង់ដែលធ្វើឱ្យមានភាពយុត្តិធម៌។[២] ម្យ៉ាងទៀតវាស្រប នឹងគោលបំណងបង្កើតឱ្យមាន ប្រព័ន្ធចៅក្រមស៊ើបសួរ សម្រាប់ការស្វែងរកនូវភស្តុតាងមកបញ្ជាក់ថាអំពើដែល តំណាងអយ្យការធ្វើការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌ ឬមិនមែនជាបទល្មើស ដូចជាករណី ដែលចៅក្រមស៊ើបសួរមិនបាន បានប្រឹងប្រែងស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ តាមកាលដែលតំណាងអយ្យការបាន បើកការស៊ើបសួរដោយទុកសំណុំរឿងចោល និង បំពេញតែកិច្ចសួរចម្លើយជនត្រូវចោទ ឬគ្រាន់តែស្តាប់ចម្លើយជនរងគ្រោះ និង សាក្សីបន្តិចបន្តួចរួចបិទកិច្ចការស៊ើបសួរ។

### កថាខណ្ឌ១.គោលការណ៍ក្នុងការស្រាវជ្រាវបទល្មើស

ជាគោលការណ៍ចៅក្រមស៊ើបសួរ ត្រូវតែមានឯករាជ្យភាពរបស់ខ្លួនចំពោះស្ថាប័នអយ្យការ និងភាគីនៃរឿងក្តីព្រហ្មទណ្ឌ ក្នុងពេលដំណើរការវិធានការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌធ្វើយ៉ាងណាបង្ហាញនូវការពិតឱ្យបាន។ ប្រសិនជាមិនមានបទល្មើសព្រហ្មទណ្ឌដូចជាការចោទប្រកាន់ពីតំណាងអយ្យការទេ ឬគ្មានភស្តុតាងណាមួយដូចការចោទប្រកាន់ គប្បីឱ្យលើកលែង ឬអាចសម្រេចផ្សេងពីតំណាងអយ្យការ។ មួយវិញទៀតធ្វើយ៉ាងណាកុំឲ្យមានអគតិទាំងបួនមកធ្វើជាត្រីមុខក្នុងការវិនិច្ឆ័យចំពោះជនត្រូវចោទ ឬជនរងគ្រោះដែលបានបង្កើតឱ្យមានភាពអយុត្តិធម៌ និងការប្តឹងតវ៉ាមិនចេះចប់ដែល

[១] <u>អគតិទាំងបួន ឬភាពលំអៀង</u> មាន (<u>ឆន្ទាគតិ</u> គឺសេចក្តីលម្អៀងព្រោះតែស្រឡាញ់, <u>មោហាគតិ</u> គឺសេចក្តីលម្អៀងព្រោះតែមិនយល់ខុសត្រូវ,<u>ភយាគតិ</u> គឺសេចក្តីលម្អៀងព្រោះខ្លាចបុណ្យស័ក្តិ,<u>ទោសាគតិ</u> គឺសេចក្តីលម្អៀងព្រោះតែសម្អប់ )វចនានុក្រមសម្តេច **ជួនណាត**។

[២] យោងតាម ជំពូកទី៣, ការស៊ើបសួរ សៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌរបស់, រ.ប.ស.វ.ត ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦។

បណ្តាលឱ្យសង្គមគ្មានសណ្តាប់ធ្នាប់ និងសន្តិសុខ។ ទើបមានគោលការណ៍លេចឡើងជាទូទៅក្នុងការស្រាវជ្រាវ និងបំពេញភារកិច្ចក្នុងឋានៈជាចៅក្រមស៊ើបសួរដូចខាងក្រោមនេះ៖

**១.១.ឯករាជ្យភាពរបស់ចៅក្រមស៊ើបសួរ**

ការបំពេញមុខងារក្នុងនាមខ្លួនជាចៅក្រមស៊ើបសួរ (***ស្វែងរកការពិតរឿងហេតុ***) ក្នុងការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ ណាមួយឱ្យចេញជារឿងពិតដែលនៅក្រោមការលាក់បាំង ឬគ្មានតម្រុយជាក់ច្បាស់ថាបុគ្គលណាមួយបានចូលរួមប្រព្រឹត្ត ឬមិនបានចូលរួមលុះត្រាណាតែ អ្នកបំភ្លឺការពិតគ្មានភាពលម្អៀងទៅលើភាគីណាម្ខាងដោយផ្អែកទៅភស្តុតាងមុននឹងថាបុគ្គលនោះបានប្រព្រឹត្តបទល្មើស ឬមិនបាន។

ការធានានូវឯករាជ្យភាពរបស់ចៅក្រមស៊ើបសួរ ជាការចំបាច់បំផុតដែលចៅក្រមនីមួយៗត្រូវតែមានមនសិការ ក្នុងការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌដោយមិនភូតភរ ឬ លាក់បាំងនូវតម្រុយអ្វីមួយដែលធ្វើឱ្យការពិតទៅជារឿងមិនពិតក្រោមការកែប្រែ ឬមិនបង្ហាញនូវអ្វីដែលមានប្រយោជន៍ដល់ភាគីណាម្ខាងដោយទទួលនូវអំពើពុករលួយពីភាគីណាមួយ ឬគតិយជន ឬដើម្បីទម្លាប់កំហុស ឬជួយឱ្យរួចផុតពីការទទួល ទណ្ឌកម្មតាមក្រមព្រហ្មទណ្ឌ។ ពាក្យថាឯករាជ្យភាពរបស់ចៅក្រមស៊ើបសួរ ត្រង់ថាបង្ហាញនូវអ្វីៗ ដែលរកឃើញក្រោយពីការស្រាវជ្រាវបទល្មើសរបស់ចៅក្រមស៊ើបសួរ ដោយមិនរងនូវក្រោមសម្ពាធពីភាគីណាមួយរួមមានជនត្រូវចោទ តំណាងអយ្យការ ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ឬអាចអ្នកទទួលខុស ត្រូវរដ្ឋប្បវេណីលើសពីនេះទៅទៀតនោះគឺការសម្រេច និងការស្រាវជ្រាវ របស់ខ្លួនគឺធ្វើឡើងដោយស្របនឹងសម្បជញ្ញៈ ជាអ្នកស្រាវជ្រាវបទល្មើសប្រកបដោយតម្លាភាព ភាពទៀងត្រង់នឹងការស្រឡាញ់យុត្តិធម៌នៃសង្គម។ **ករណីដែលមាន** ដើមបណ្តឹងរដ្ឋប្បវេណី និង តំណាងអយ្យការស្នើសុំឱ្យស៊ើបសួរ ឬស្នើសុំធ្វើកោសលវិច័យ ឬប្រតិកោសលវិច័យ ស្នើសុំវត្ថុតាងចាប់យក គឺចៅក្រមស៊ើបសួរអាចសម្រេចធ្វើតាម ឬមិនតាមការស្នើសុំបានជាឆន្ទានុសិទ្ធិ។[៣]

**១.២.ការធានាភាពត្រឹមត្រូវក្នុងការអនុវត្តច្បាប់**

ធានាភាពត្រឹមត្រូវសំដៅទៅលើស្ថានភាពក្នុងនាមជាចៅក្រមស៊ើបសួរធ្វើការវិនិច្ឆ័យ និង សេចក្តីសម្រេចរបស់ខ្លួនត្រូវតែស្រប នឹងបទប្បញ្ញត្តិដែលក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាដែលបានតម្រូវគ្រប់ការសម្រេចសេចក្តីរបស់ខ្លួនត្រូវតែមាននូវសំអាងហេតុ (***ការយល់ឃើញ និង ឯកសារយោង***) និងមានសំអាងច្បាប់(***មាត្រាច្បាប់កំណត់អំពីសិទ្ធិ ឬយុត្តិសាស្ត្រ***) ដើម្បីឆ្លុះបញ្ចាំងអំពីភាពត្រឹមត្រូវដែលខ្លួនបានខិតខំប្រឹងប្រែង និងអនុលោមតាមបញ្ញត្តិច្បាប់ក្នុងការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ។

កាលណាការអនុវត្តផ្ទុយពីទម្រង់ដែលច្បាប់បានកំណត់ នឹង នាំឱ្យមានការប្តឹងសុំមោឃភាពនីតិវិធីតាមបណ្តឹងរបស់អ្នកមានសិទ្ធិ លើកឡើងអំពីមោឃភាពនីតិវិធីទៅ សភាស៊ើបសួរនៃសាលាឧទ្ធរណ៍។[៤] មួយវិញទៀត ការអនុវត្តត្រូវធានាថាការស្រាវជ្រាវរបស់ខ្លួន ដើម្បីបង្ហាញការពិតត្រូវតែស្របតាមបញ្ញត្តិនិង ផលប្រយោជន៍នៃការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ។ យ៉ាងណាក៏មានករណីអញ្ញត្រកម្មចំពោះការខ្វះចន្លោះប្រហោងនៃច្បាប់ ទើបចៅក្រមស៊ើបសួរអាចធ្វើកិច្ចស្រាវជ្រាវនោះ ដោយឈរលើគោលការណ៍

---

[៣] អនុលោមមាត្រា ១៣២ ១៣៣ ១៣៤ ១៦១ និងមាត្រា ១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[៤] អនុលោមមាត្រា ២៥២ មោឃភាពស៊ើបសួរនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ផលប្រយោជន៍នីតិវិធីដូចជាករណីបំផ្លាញវត្ថុតាងមុនពេលបើកសវនាការជាដើម។[5]

**ករណីមាន៖** ការរឹបអូសបំផ្លាញចោលមាន់ទាំង **៩២ ក្បាល** នៅដំណាក់កាលចៅក្រមស៊ើបសួរ មិនមានបទប្បញ្ញត្តិណាមួយចែងឱ្យជាក់លាក់ថាចៅក្រមស៊ើបសួរ អាចបំផ្លាញវត្ថុតាងចាប់យកមុនពេលដាក់ទៅចៅក្រមជំនុំជម្រះ មានតែករណីប្រគល់វត្ថុចាប់យកត្រឡប់ទៅម្ចាស់កម្មសិទ្ធិករវិញ។

**១.៣.ប្រមូលភស្តុតាងដាក់បន្ទុក និងដោះបន្ទុក**

ការធានានូវគោលការណ៍រកភស្តុតាងដាក់បន្ទុក និង ដោះបន្ទុកជាមូលគ្រឹះនៃប្រព័ន្ធចៅក្រមស៊ើបសួរក្នុងការប្រមែប្រមូលភស្តុតាងនានា អាចភស្តុតាងជាឯកសារ ភស្តុតាងជាសាក្សី ភស្តុតាងជាសំលេង និងគ្រប់សេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ និងរបាយការណ៍សរុបរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញតួនាទី ជាអ្នកស៊ើបសួរជំនួសតាមការចាត់តាំងរបស់ចៅក្រមស៊ើបសួរ។[6] ការស៊ើបសួរដាក់បន្ទុកមានន័យថាស្វែងរកភស្តុតាងមកធ្វើមូលដ្ឋាន ក្នុងការបញ្ជូនជនត្រូវចោទទៅធ្វើការជំនុំជម្រះនូវអំពើដែលជនត្រូវចោទបានប្រព្រឹត្ត។ ចំណែកការស៊ើបសួរដោះបន្ទុកស្វែងរកភស្តុតាងនូវអ្វីៗ ដែលជនត្រូវចោទមិនបានប្រព្រឹត្តដូចជាការចោទប្រកាន់របស់តំណាងអយ្យការ ឬជាភស្តុតាងដែលអាចជួយសម្រាលទោសដល់ជនត្រូវចោទ។ [...ដោយសារតែចៅក្រមស៊ើបសួរ ជាយុត្តាធិការស៊ើបសួរផង និងជាយុត្តាធិការជំនុំជម្រះផង...]។[7] **ករណីដូចជា** ជនត្រូវចោទ បានបើកបររថយន្តដោយធ្វេសប្រហែស និងបណ្តាលឱ្យរងរបួសជាទម្ងន់តែជនត្រូវចោទមិនរត់គេចខ្លួនថែមទាំងជួយដឹកជនរងគ្រោះទៅមន្ទីរពេទ្យ។

**១.៤.ការទទួលខុសត្រូវចំពោះមុខងារ**

ជាគោលការណ៍ចៅក្រមស៊ើបសួរ មិនទទួលខុសត្រូវចំពោះកំហុសក្នុងការស្រាវជ្រាវរបស់ខ្លួនអ្វីៗទាំងអស់នៅពេល ដំណើរការស្រាវជ្រាវបទល្មើស និងសម្រេចបញ្ជូនទៅជំនុំជម្រះ ទោះបីជាចៅក្រមជំនុំជម្រះរកមិនឃើញពិរុទ្ធភាព ឬប្រកាសសាលក្រមលើកលែងបទចោទចំពោះជនជាប់ចោទ។[8] មួយវិញទៀតនោះចៅក្រម មិនទទួលខុសត្រូវខាងបទល្មើសព្រហ្មទណ្ឌ ឬក៏កំហុសរដ្ឋប្បវេណីណាមួយចំពោះការសម្រេច ដែលធ្វើឡើងក្នុងក្របខណ្ឌសមត្ថកិច្ច និង មុខងាររបស់ខ្លួនក្នុងឋានៈជាចៅក្រមឡើយ។[9] ក៏ប៉ុន្តែមិនមែន គ្រប់តែករណីទាំងអស់នោះឡើយ ច្បាប់បានការពារតែករណីចៅក្រមស៊ើបសួរ សម្រេចសេចក្តីដោយគ្មានចេតនាទុច្ចរិតតែប៉ុណ្ណោះទេ ចំពោះការស្រាវជ្រាវបទល្មើសរបស់ខ្លួនក្នុងមុខងារជាចៅក្រមស៊ើបសួរ កាលណាមានភស្តុតាងផ្ទុយពីនេះចៅក្រមស៊ើបសួរ និង ទទួលខុសត្រូវអាចទាំងបទល្មើសព្រហ្មទណ្ឌនិងអាចជាកំហុសរដ្ឋប្បវេណី។[10] ជាងនេះទៅទៀត រដ្ឋធម្មនុញ្ញបានកំណត់ឱ្យមាន

[5] យោងឧបសម្ព័ន្ធទី ៨០ ដីកាសម្រេចរបស់ប្រធានសាលាដំបូងខេត្តកណ្តាល និងជាចៅក្រមស៊ើបសួរចុះថ្ងៃ១៩ ខែធ្នូ ឆ្នាំ២០១៧។

[6] យោងតាម សៀវភៅនីតិភស្តុតាងរបស់លោក ចៅក្រម **អ៊ិនបូផា** បោះពុម្ពផ្សាយលើកទី២ ទំព័រទី ២២៥ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦។

[7] យោងឯកសារបង្រៀនសិស្សក្រឡាបញ្ជីជំនាន់ទី៣ សារៈសំខាន់កិច្ចនិតិវិធីក្នុងដំណាក់កាលយុត្តាធិការស៊ើបសួរ និងការទទួលខុសត្រូវ ខ្ពស់របស់ក្រឡាបញ្ជី...។

[8] អនុលោមមាត្រា ១៣៣ ថ្មី រដ្ឋធម្មនុញ្ញ ចៅក្រមមិនត្រូវបានហូតមុខងារឡើយ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។

[9] អនុលោមមាត្រា ៦ ជំពូកទី១ បទប្បញ្ញត្តិរួម នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

[10] អនុលោមមាត្រា ៦ កថាខណ្ឌទី២ វាក្យខណ្ឌទី១ គោលការណ៍នេះនៃចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤។

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានសិទ្ធិអំណាចក្នុងការដាក់ពិន័យលើចៅក្រមដែលបានប្រព្រឹត្តខុស។ **ដូចមានករណី៖** ចៅក្រមស៊ើបសួរ បានសម្រេចលើកលែងបទចោទប្រកាន់លើជនត្រូវចោទឈ្មោះ ខ ដោយសារតែទទួលបានលោភធនជាប្រាក់សម្រាប់ការលើកលែងបទចោទប្រកាន់នេះ។

**កថាខណ្ឌ២. ភាគពុកិច្ចគតិយុត្តមុនចាប់ផ្ដើមស្រាវជ្រាវបទល្មើស**

ជាគោលការណ៍ចៅក្រមស៊ើបសួរ មិនអាចចាប់ផ្ដើមស្រាវជ្រាវបទល្មើសណាមួយដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីតំណាងអយ្យការឡើយ។ មានតែតំណាងអយ្យការទេដែលមានសិទ្ធិសម្រេចអំពីការបញ្ជូនបទល្មើសព្រហ្មទណ្ឌណាមួយដែលមានភាពស្មុគស្មាញ និងភស្តុតាងមិនទាន់គ្រប់គ្រាន់មកចៅក្រមស៊ើបសួរ ដើម្បីស្រាវជ្រាវ និងស្វែងរកភស្តុតាងដាក់បន្ទុក ឬដោះបន្ទុក។[១១] ម្យ៉ាងទៀតវិញចំពោះករណីបទល្មើសឧក្រិដ្ឋច្បាប់បានតម្រូវ និងបញ្ជាក់បំពេញបន្ថែមនៅក្នុងបញ្ញត្តិទាក់ទងនឹងចៅក្រមស៊ើបសួរ ដែលតម្រូវឱ្យតំណាងអយ្យការត្រូវតែប្ដឹងមកចៅក្រមស៊ើបសួរ ដើម្បីធ្វើការស៊ើបសួរជាដាច់ខាតទោះបីជា មានភស្តុតាងគ្រប់គ្រាន់យ៉ាងណាក៏ដោយ ករណីគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទេគឺគ្មានសិទ្ធិអំណាចស្រាវជ្រាវបទល្មើសខ្លួនឯងឡើយ ទោះជាខ្លួនដឹងយ៉ាងណាក៏ដោយ។[១២]

ករណីអញ្ញត្រកម្ម ចំពោះចៅក្រមស៊ើបសួរគឺ អាចធ្វើការស៊ើបសួរបានតាមពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដែលតំណាងអយ្យការ សម្រេចតម្កល់សំណុំរឿងនោះទុកឥតចាត់ការ រួមទាំងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញ ស្របនឹងសេចក្ដីរបស់ព្រះរាជអាជ្ញាអមសាលាដំបូងផងដែរនោះ។[១៣] ដោយមានស្ថានភាពបែបនេះទើប ក្រមនីតិវិធីព្រហ្មទណ្ឌមានយន្តការជួយសង្គ្រោះនូវស្ថានបែបនេះ( *ពន្យល់នៅចំនុច ២.២* )

**២.១.ដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ**

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាកិច្ចលាយលក្ខណ៍អក្សរដែលតំណាងអយ្យការប្ដឹងមកកាន់ចៅក្រមស៊ើបសួរ តាមការយល់ឃើញរបស់ខ្លួន ឬបញ្ញត្តិច្បាប់ដែលបានចាប់បង្ខំតំណាងអយ្យការត្រូវតែប្ដឹងមកចៅក្រមស៊ើបសួរជាដាច់ខាតប្រសិនជាមានករណីបទល្មើសឧក្រិដ្ឋ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ របស់តំណាងអយ្យការ អាចមានការបើកការស៊ើបសួរលើបុគ្គលម្នាក់ ឬច្រើននាក់ ឬមានករណីអញ្ញត្រជន (***គ្មានសារតាជាតិគ្រប់គ្រាន់ ឬគ្មានតែម្ដង***) មកកាន់ខ្លួនជាចៅក្រមស៊ើបសួរ។ ជាគោលការណ៍ចៅក្រមស៊ើបសួរ ធ្វើការស្រាវជ្រាវតែទៅអង្គហេតុដែលតំណាងអយ្យការសម្រេចប្ដឹងមកខ្លួនតែប៉ុណ្ណោះមិនមែនធ្វើការស៊ើបសួរទៅលើបុគ្គលឡើយ។ ចៅក្រមស៊ើបសួរ មិនអាចពង្រីកវិសាលភាពទៅលើអង្គហេតុណាមួយដែល តំណាងអយ្យការមិនបានប្ដឹងមកខ្លួនតាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមឡើយ។ តែប្រសិនជាអង្គហេតុដែលជាស្ថានភាពបន្ថែមទម្ងន់ទោសនៃអង្គហេតុដែលតំណាងអយ្យការប្ដឹងមក ចៅក្រមស៊ើបសួរ មិនចាំបាច់មាន ដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ បន្ថែម

---

[១១] អនុលោមមាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[១២] អនុលោមមាត្រា ១២២ ការបើកការស៊ើបសួរ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[១៣] អនុលោមមាត្រា ៤១ និងមាត្រា ៤១ ជម្រើសនៃការចោទប្រកាន់ និងការតម្កល់រឿងទុកឥតចាត់ការ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

អ្វីឡើយ។[១៥] ដោយសារតែអ្នកនីតិបញ្ញត្តិយល់ឃើញថា វាជាស្ថានភាពពិសេសមួយដែលជនត្រូវចោទបានប្រព្រឹត្តបទល្មើសតាមដំណាក់កាលមុនពេលសម្រេចនូវគោលបំណងចុងក្រោយរបស់ខ្លួន។

*-ជាបទពិសោធអនុវត្តជាក់ស្តែងនៅសាលាដំបូងផ្ទាល់៖*

នៅពេលដែលមានសំណុំរឿងក្តីព្រហ្មទណ្ឌ បានចូលមកដល់តំណាងអយ្យការ ដែលត្រូវបានបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌អាចជាកងរាជអាវុធហត្ថ ឬមន្ត្រីនគរបាលជាតិដែលមានជនសង្ស័យមកជាមួយនោះច្រើនតែជាបទល្មើសជាក់ស្តែងនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌។កាលណាតំណាងអយ្យការធ្វើការចោទប្រកាន់ និង បើកការស៊ើបសួរនោះត្រូវតែនាំជនជាប់សង្ស័យមកតាមរយៈរដ្ឋបាលត្រូវបញ្ជូនមកចៅក្រមស៊ើបសួរភ្លាមៗ ទាំងសំណុំរឿង និង ជនដែលតំណាងអយ្យការសម្រេចចោទប្រកាន់ មកបង្ហាញចំពោះចៅក្រមស៊ើបសួរ។ ដោយឡែកនៅដំណាក់កាលអយ្យការមិនមានការបែងចែកសំណុំរឿងជាក់ស្តែង ឬមិនជាក់ស្តែងទេ មានករណីតែបទល្មើសជាក់ស្តែង និងករណីបទល្មើសមិនជាក់ស្តែង។ ការបែងចែកនេះក្នុងគោលបំណងងាយស្រួលក្នុងការអនុវត្តនីតិវិធី នៅចំពោះមុខតំណាងអយ្យការមកចំពោះមុខចៅក្រមស៊ើបសួរ ករណីសំណុំរឿងជាក់ស្តែង និងមិនជាក់ស្តែងតាមនីតិវិធីនីមួយៗ។

**២.១.១.ករណីចំពោះសំណុំរឿងជាក់ស្តែង**

ការអនុវត្តជាក់ស្តែងនៅតាមសាលាដំបូង កាលណាដែលមានជនសង្ស័យត្រូវបាននាំមកបង្ហាញចំពោះមុខតំណាងអយ្យការច្រើនតែ តំណាងអយ្យការពិនិត្យលក្ខខណ្ឌ និងបទល្មើសដែលជនសង្ស័យបានប្រព្រឹត្តអាចបទល្មើសឧក្រិដ្ឋ មជ្ឈិម និងលហុ? ដែលខ្លួនគួរតែត្រូវធ្វើការបើកការស៊ើបសួរ មកចៅក្រមស៊ើបសួរ ឬយ៉ាងណា? ដោយសារតែច្បាប់តម្រូវចំពោះបទល្មើសឧក្រិដ្ឋត្រូវតែបើកការស៊ើបសួរ និង ចំពោះបទល្មើសមជ្ឈិមវិញ ច្បាប់ទុកជាឆន្ទានុសិទ្ធឱ្យតំណាងអយ្យការថ្លឹងថ្លែងគួរបើក ឬមិនបើកក្នុងករណីដែលមានភស្តុតាងមិនទាន់គ្រប់គ្រាន់ ចំពោះនីតិវិធីជំនុំជម្រះ ឬមានភាពស្មុគស្មាញគួរតែបើកការស៊ើបសួរ។

ករណីក្រៅពីបទល្មើសឧក្រិដ្ឋ និងមជ្ឈិមមិនមានការបើកការស៊ើបសួរឡើយ។ លើកលែងតែមានករណីដែលតំណាងអយ្យការ ធ្វើការប្តឹងទៅចៅក្រមស៊ើបសួរចំពោះបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមតែក្រោយមកចៅក្រមស៊ើបសួរ ចេញដីកាដំណោះស្រាយកែប្រែបទចោទមកជា បទលហុទៅវិញ។

សំណុំរឿងជាក់ស្តែងដែលមានខ្លួនជនជាប់សង្ស័យត្រូវបាន តំណាងអយ្យការធ្វើការបញ្ជូនមកចៅក្រមស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះ ចៅក្រមស៊ើបសួរ ត្រូវតែទទួលយកសំណុំរឿង និងជនត្រូវចោទដែលមន្ត្រីនគរបាលបាននាំយកមកបង្ហាញនៅចំពោះមុខខ្លួនតែម្តង។ ចៅក្រមស៊ើបសួរ មិនអាចពន្យារពេលណាមួយទេ ត្រូវតែធ្វើការត្រួតពិនិត្យទៅលើជនត្រូវចោទ និង មានការសួរចម្លើយជនត្រូវចោទ រួមទាំងមានកំណត់ហេតុផ្សេងៗ ដែលក្រមនីតិវិធីបានតម្រូវឱ្យធ្វើជាការចាំបាច់ និងអាចមានការចូលរួមពិភាក្សាដេញដោលនៅចំពោះមុខខ្លួនអាចមាន តំណាងអយ្យការ មេធាវី និងអ្នកបកប្រែ ក្រោយពីចៅក្រមស៊ើបសួរដែលបានធ្វើការសួរចម្លើយ ឬពិភាក្សារួចរាល់ចៅក្រមស៊ើបសួរ នឹងសម្រេចអំពីសិទ្ធិសេរីភាព ជនត្រូវចោទអាចសម្រេចឱ្យនៅក្រៅឃុំ ឬអាចសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន ដោយសារតែបញ្ហាការឃុំខ្លួនជនត្រូវចោទ និង ការមិនឃុំខ្លួនជារឿងសំខាន់ពាក់ព័ន្ធកិច្ចស៊ើបសួរ។

[១៥] អនុលោមមាត្រា ១២៥ វិសាលភាពនៃការប្តឹង នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧។

#### **២.១.២.ករណីចំពោះសំណុំរឿងមិនជាក់ស្តែង**

ចំពោះសំណុំរឿងមិនជាក់ស្តែងវិញជា សំណុំរឿងមិនមានខ្លួនជនសង្ស័យយកមក ចំពោះមុខចៅក្រមស៊ើបសួរ ដែលជនត្រូវចោទមិនបានចូលមកនៅចំពោះមុខចៅក្រមស៊ើបសួរភ្លាមៗ នោះឡើយ។ ដូច្នេះចៅក្រមស៊ើបសួរ មិនប្រញាប់ចំពោះចំណាត់ការសំណុំរឿងនោះឡើយ និង ដោយសារតែចៅក្រមស៊ើបសួរ ត្រូវការពេលវេលាជាច្រើនជាងបទល្មើសដែលមានខ្លួនជនត្រូវចោទ។

ជាគោលការណ៍ចំពោះសំណុំរឿងមិនជាក់ស្តែង ចៅក្រមស៊ើបសួរច្រើន តែកោះហៅដើមបណ្តឹងរដ្ឋប្បវេណីមកស្តាប់ចម្លើយ និងបន្ទាប់មកទៀតនឹងចេញនូវវិធានការនិរន្តរាយបង្ខំឱ្យជនត្រូវចោទចូលមក ចំពោះមុខចៅក្រមស៊ើបសួរនឹងធ្វើនីតិវិធីដូចជាសំណុំរឿងជាក់ស្តែងដែរ ដោយចុងក្រោយសម្រេចអំពីសិទ្ធិ សេរីភាពរបស់ជនត្រូវចោទ។

### **២.២.ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ជាយន្តការចុងក្រោយ នៃការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះគ្មានផ្លូវណាមួយ ក្រៅពីវិធាននេះទេ។ ជាគោលការណ៍ម្ចាស់បណ្តឹងអាជ្ញាមានតែតំណាងអយ្យការ តែមួយគត់ដែលធានា ដោយរដ្ឋធម្មនុញ្ញជាច្បាប់កំពូលខ្ពស់ជាងគេបំផុតនៃព្រះរាជាណាចក្រកម្ពុជា។ ជាករណីពិសេសដើម្បីបំពេញចន្លោះប្រហោងចំពោះចំណាត់ការរបស់ ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាដែលបានសម្រេចតម្កល់សំណុំរឿងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការ នោះជនរងគ្រោះអាចបណ្តឹងមកចៅក្រមស៊ើបសួរតែម្តង។[១៥] ដែលមានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញាដែលជនរងគ្រោះទទួលរងនូវអំពើជាបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម។ **ដូចជាករណី ក** ត្រូវទទួលរងនូវអំពើហិង្សាដោយសារតែដើរជិតកន្លែងការដ្ឋានសំណង់ដោយមានមានធ្លាក់ដែកត្រូវដៃរបស់ខ្លួន។ ក្រោយពីបានប្តឹងទៅស្ថាប័នអយ្យការ ព្រះរាជអាជ្ញាបានសម្រេចតម្កល់ដោយយល់ឃើញថា វាគ្មានបទល្មើសព្រហ្មទណ្ឌដោយសារតែការដ្ឋានសំណង់ធ្វើឡើងគឺ ត្រឹមត្រូវតាមច្បាប់ នឹងកាតព្វកិច្ចប្រុងប្រយ័ត្នដោយមិនសុខចិត្តនឹងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការបានបន្ត ប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីធ្វើអធិបញ្ញាឱ្យធ្វើការចោទប្រកាន់តែត្រូវបានអគ្គព្រះរាជអាជ្ញា នៅតែសម្រេចតម្កល់ការសម្រេចរបស់ព្រះរាជអាជ្ញាទុកជាបានការ ទើបជនរងគ្រោះ ឬសិទ្ធិវន្តដាក់ពាក្យបណ្តឹងមកចៅក្រមស៊ើបសួរតែម្តង។

#### **២.២.១.ការបញ្ជូនពាក្យបណ្តឹងទៅតំណាងអយ្យការធ្វើការចោទប្រកាន់**

ក្រោយពីចៅក្រមស៊ើបសួរបានទទួលពាក្យបណ្តឹងព្រហ្មទណ្ឌ ត្រូវតែពិនិត្យទៅលើពាក្យបណ្តឹងនោះជាមុនសិនថា តើជាពាក្យបណ្តឹងសាមញ្ញ ឬជាពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដោយមានបែងចែកករណីនេះ ប្រសិនជាពាក្យណ្តឹងសាមញ្ញត្រូវបញ្ជូនមក ស្ថាប័នអយ្យការដើម្បីជាសមត្ថកិច្ច។ ចំពោះករណីពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចៅក្រមស៊ើបសួរ ធ្វើការកត់សម្គាល់ក្នុងដីការបស់ខ្លួន ជាមុននឹងបញ្ជូនពាក្យបណ្តឹង និង ដីការបស់ខ្លួនទៅ

[១៥]អនុលោមមាត្រា ៥ ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧។

តំណាងអយ្យការឱ្យធ្វើការចោទប្រកាន់។[16] ការធ្វើការសាកសួរជនរងគ្រោះមកដាក់ពាក្យ ថាតើអង្គហេតុយ៉ាងណាខ្លះ? អ្នកឯងមានភស្តុតាងអ្វីខ្លះ? ដាក់បង្ហាញមកមាន ភស្តុតាងមួយ ពីរ បី ដោយចៅក្រមស៊ើបសួរ ត្រូវបង្ហាញនៅក្នុងដីការបស់ខ្លួនថាវាមានបទល្មើសឬយ៉ាងណា ដើម្បីឱ្យតំណាងអយ្យការកែប្រែចិត្តចោទប្រកាន់ចំពោះអំពើដែលខ្លួន និងអគ្គព្រះរាជអាជ្ញាបានសម្រេចតម្កល់ទុកឥតចាត់ការ។ សួរថាបើអ្នកជាបានតម្កល់ ហើយអគ្គព្រះរាជអាជ្ញាតម្កល់ទៀត តើអ្នកអាចសម្រេចបន្តការស៊ើបសួរឬទេ? ជាគោលការណ៍តំណាងអយ្យការត្រូវតែបើកការស៊ើបសួរក្រោយពីបានទទួលនូវដីកា និង ពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងដែលបានបញ្ជូនមកដោយចៅក្រមស៊ើបសួរ និងអាចស្នើសុំទៅចៅក្រមស៊ើបសួរវិញសុំកុំឱ្យស៊ើបសួរ ប្រសិនជាបណ្ដឹងអាជ្ញាត្រូវផុតរលត់ ឬអំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌតែ ចៅក្រមស៊ើបសួរអាចសម្រេចស៊ើបសួរ ឬក៏មិនស៊ើបសួរតាមដីកាសម្រេចរបស់ខ្លួនដោយមានសំអាងហេតុបាន។[17]

### ២.២.២.ឆន្ទានុសិទ្ធិក្នុងការចាប់ផ្ដើមស្រាវជ្រាវដោយខ្លួនឯង

ករណីដែលចៅក្រមស៊ើបសួរ សម្រេចតាមការទទួចស្នើសុំជនរងគ្រោះ អាចចេញដីកាសម្រេចដោយមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់តំណាងអយ្យការប្រសិនជាសម្រេចស៊ើបសួរ។ ជាគោលការណ៍ចៅក្រមស៊ើបសួរ ទទួលតាមពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីជនដែលប្រកាសថាខ្លួនរងគ្រោះ ត្រូវតែប្រាប់អំពីអត្តសញ្ញាណរបស់បុគ្គល នោះឱ្យបានច្បាស់លាស់ និងត្រូវដាក់ប្រាក់តម្កល់ ដើម្បីធានានូវបណ្ដឹងដោយគ្មានការបំពាន ឬការអូស បន្លាយពេលវេលា។ ចៅក្រមស៊ើបសួរត្រូវតែ ពិនិត្យទៅលើជីវភាព និងលទ្ធភាពជនរងគ្រោះ នឹងចេញដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាក់ធានា ឬកំណត់ពេលវេលានៃការបង់ប្រាក់ធានានេះ អាចប្រគល់ត្រឡប់វិញ ប្រសិនជារកឃើញថាបទល្មើសដូចការស្នើសុំ បើសិនជាករណីផ្ទុយបំពាន ឬអូសបន្លាយពេលវេលានីតិវិធីរបស់តុលាការនោះត្រូវរឹបអូស។[18]

## ផ្នែកទី២.សិទ្ធិអំណាចនៃការប្រើប្រាស់វិធានការនិរន្ដរាយ

ដើម្បីឆ្លើយតបទៅនឹងតម្រូវការ នៃកិច្ចស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌរបស់ ចៅក្រមស៊ើបសួរ និងតម្រូវឱ្យជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធចូលមកបង្ហាញខ្លួនដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននោះ ដោយប្រើប្រាស់នូវវិធានបង្ខំណាមួយ ទើបអាចឱ្យជនត្រូវចោទចូលមកបានតាមរយៈដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និង ដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្ដោះអាសន្ន។[19] ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំ និងដីកាបង្គាប់ចាប់ខ្លួនជាវិធានការ មានវិសាលភាពអាចចេញទៅលើជនត្រូវចោទ ឬជនជាប់ពាក់ព័ន្ធនឹងអង្គហេតុក្នុង ដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឱ្យស៊ើបសួរនោះ។ ជាគោលការណ៍វិធានការនិរន្ដរាយអនុវត្តក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា តែដីកា

[16]អនុលោមមាត្រា ១៣៩ការបញ្ជូនពាក្យបណ្ដឹងទៅព្រះរាជអាជ្ញា កថាខណ្ឌទី ១នៃក្រមនីតិវីធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[17]អនុលោមមាត្រា ១៣៩ ថាខណ្ឌទី៤ នៃក្រមនីតិវីធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[18] អនុលោមមាត្រា ១៤០ ១៤១ និងមាត្រា ១៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[19] អនុលោមមាត្រា ១៨៥វិធានការនិរន្ដរាយ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

បង្គាប់ឱ្យចាប់ខ្លួន ក្នុងករណីមានភាពចាំបាច់អាចធ្វើការផ្សព្វផ្សាយជាអន្តរជាតិដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌គ្រប់មធ្យោបាយឱ្យមានប្រសិទ្ធិភាព។

**កថាខណ្ឌ១.វិធានការបង្ខំរបស់ចៅក្រមស៊ើបសួរ**

វិធានការបង្ខំ (អន្តរាយ) គឺការរំលោភសិទ្ធិសេរីភាពបុគ្គលដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ ក្នុងគោលបំណងដំណើរការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ និងផលប្រយោជន៍សង្គមជាតិ ឬបង្ការនូវការកើតបទល្មើសជាថ្មី។ ជាគោលការណ៍សិទ្ធិសេរីភាពបុគ្គល ត្រូវបានការពារដោយច្បាប់ធានារ៉ាប់រងមិនឱ្យមានការរំលោភលើរូបរាងកាយបុគ្គលណាមួយឡើយ។ មួយវិញទៀតការពារជីវិតកិត្តិយសសេចក្ដីថ្លៃថ្នូប្រជាពលរដ្ឋ។ ការចាប់ខ្លួនរបស់បុគ្គល និង ឃុំខ្លួនទៅលើជនអាចធ្វើទៅបាន លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ដែលមានជាធរមាននៅក្នុងព្រះរាជាណាក្រកម្ពុជា។[២០]

**១.១.វិធាននិរន្តរាយ**

វិធានការនិរន្តរាយ គឺជាបណ្តុំបទដ្ឋានគតិយុត្តដែលបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចាប់ពីមាត្រា **១៨៥** រហូតដល់មាត្រា **២២២** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ សម្រាប់ផ្តល់សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរ ក្នុងការប្រើប្រាស់ក្នុងគោលបំណងផលប្រយោជន៍ស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ និង គោលដៅបង្គាប់ឱ្យជនត្រូវចោទ ឬជនដែលមានតម្រុយពិរុទ្ធចូលមកបង្ហាញខ្លួននៅចំពោះចៅក្រមស៊ើបសួរ ឬអ្នកជំនួស និងអាចបង្គាប់ឱ្យយកជនត្រូវចោទទៅពន្ធនាគារ ឬមណ្ឌលឃុំជាបណ្តោះអាសន្ន។

**១.១.១.ដីកាបង្គាប់ឲ្យចូលខ្លួន**

ជាបញ្ជាដល់បុគ្គលដែលជាជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាពឱ្យចូលមកចំពោះមុខចៅក្រមស៊ើបសួរ តាមកាលបរិច្ឆេទដែលបានកំណត់ក្នុងដីកា។ សាមីខ្លួនដែលបានទទួលដីកានេះ អាចមកដោយសេរីនៅចំពោះមុខចៅក្រមស៊ើបសួរ តាមកាលកំណត់ ដើម្បីមកធ្វើការឆ្លើយបំភ្លឺនូវអ្វីៗ ដែលចៅក្រមស៊ើបសួរ ធ្វើការសាកសួរក្នុងឋានៈជាជនត្រូវចោទដែលត្រូវបានតំណាងអយ្យការធ្វើការប្តឹងចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។[២១] ជាទូទៅដីកានេះប្រើប្រាស់នៅពេលដែលជនត្រូវចោទ ឬ បុគ្គលមានតម្រុយពិរុទ្ធភាពមិនបានរត់គេចពីការទទួលខុសត្រូវអំពីអំពើបទល្មើស ក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬកងរាជអាវុធហត្ថមិនបានឆ្លើយតបនឹងការកោះហៅ ឬនៅជំណាក់កាលអយ្យការ។ ក្រោយពេលដែលជនត្រូវចោទ បានចូលខ្លួនមកចំពោះចៅក្រមស៊ើបសួរតាមការបង្គាប់ឱ្យចូលខ្លួន ចៅក្រមស៊ើបសួរត្រូវសួរចម្លើយភ្លាមៗ។ អ្នកដែលត្រូវទទួលបន្ទុកក្នុងការអនុវត្តដីកានេះគឺ មន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ច នាទីលំនៅរបស់ជនត្រូវចោទ បានស្ថិតនៅដោយបញ្ជូនដីកានេះទៅតាមនីតិវិធី និងព្រមទាំងបង្វិលចុងដីកាដើមដោយមានចុះហត្ថលេខារបស់អ្នកទទួល ឬ អ្នកប្រគល់ ឬរបាយការណ៍ស្តីពីការបញ្ជូនទៅជនត្រូវចោទកំពុងស្ថិតនៅក្រៅ របស់តុលាការសមត្ថកិច្ចតាមនីតិវិធីច្បាប់ដែលបានចែងអំពីរបៀបស្តីពីការបញ្ជូន។[២២]

---

[២០]អនុលោមមាត្រា ៣៨ អំពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។

[២១]អនុលោមមាត្រា ១៨៧ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[២២] អនុលោមមាត្រា ២៣២របៀបកោះហៅ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧។

**១.១.២.ដីកាបង្គាប់ឲ្យនាំខ្លួន**

ជាបញ្ជាកងកម្លាំងសាធារណៈដើម្បីឱ្យចាប់ នឹងនាំខ្លួនជនត្រូវចោទ ឬបុគ្គលមានតម្រុយពិរុទ្ធភាព ដែលបានគេចវេសមិនព្រមចូលមកបង្ហាញខ្លួនមកចំពោះមុខចៅក្រមស៊ើបសួរ ឬរឹងទទឹងមិនព្រមមកតាម រយៈដីកាបង្គាប់ឱ្យចូលខ្លួនដែលចៅក្រមស៊ើបសួរបានចេញជាម្តង ឬជាពីរដងរួចមកហើយតែមិនព្រមចូលខ្លួនដដែល ឬបានរត់គេចចេញពីមូលដ្ឋាន។ ដីកាបង្គាប់ឱ្យនាំខ្លួនអនុញ្ញាតឱ្យកងកម្លាំងសាធារណៈធ្វើការចាប់ខ្លួន និង នាំជនត្រូវចោទមកបង្ហាញនៅចំពោះមុខចៅក្រមស៊ើបសួរនៅថ្ងៃនឹងចាប់ខ្លួន បានតែម្តង។ ករណីដែលមិនអាចនាំខ្លួនជនត្រូវចោទមកបង្ហាញចំពោះ មុខចៅក្រមស៊ើបសួរទេត្រូវយកទៅអង្គភាពនគរបាល ឬមណ្ឌលឃុំខ្លួន ឬពន្ធនាគារមិនឱ្យលើសពីរយៈពេល ២៤ ម៉ោងយ៉ាងយូក្រោយពីការឃុំខ្លួន។[២៣] ក្រោយពីបន្ទប់ពីថ្ងៃដែលបានឃុំខ្លួនជនត្រូវចោទ ត្រូវនាំខ្លួនជនត្រូវចោទមកចំពោះមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួស។ មន្ត្រីពន្ធនាគារត្រូវតែជូនដំណឹងអំពីជនត្រូវចោទដែលបានឃុំខ្លួនឱ្យបាន ឆាប់រហ័សបំផុត ដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចបន្ត។ នៅថ្ងៃបន្ទាប់បើសិនជាមិនបានមកបង្ហាញខ្លួនទេត្រូវតែដោះលែងឱ្យមានសេរីភាពឡើងវិញ។[២៤] អ្នកដែលទទួលបន្ទុកអនុវត្តដីកានេះគឺជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងករណីបន្ទាន់នោះ ដីកានេះត្រូវតែផ្សព្វផ្សាយគ្រប់មធ្យោបាយទាំងអស់ដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ចំពោះការចាប់ខ្លួន និងនាំខ្លួនមិនអាចចូលទៅលំនៅឋានមុនម៉ោង **៦ព្រឹក** និងក្រោយ **ម៉ោង ១៨** ល្ងាចបានឡើយ។ នៅពេលដែលមានឧបសគ្គក្នុងការអនុវត្តដីកានេះត្រូវតែជូនដំណឹងទៅដល់ចៅក្រមស៊ើបសួរ ដែលបានចេញដីកាបង្គាប់ឱ្យនាំខ្លួននេះជាបន្ទាន់ដើម្បីសុំគោលការណ៍បន្ថែម។

**១.១.៣.ដីកាបង្គាប់ឲ្យចាប់ខ្លួន**

ជាបញ្ជាទៅដល់មន្ត្រីនគរបាលយុត្តិធម៌ឱ្យធ្វើការស្រាវជ្រាវ និងស្វែងរកចាប់ខ្លួនជនត្រូវចោទដែលកំពុងតែរត់គេចខ្លួនមិនដឹងស្ថិតនៅទីណាមួយពិតប្រាកដ។

បញ្ជាឱ្យចាប់ខ្លួនគឺជាលក្ខខណ្ឌតឹងរឹងបំផុតដោយសារ តែវាប៉ះពាល់នូវសិទ្ធិសេរីភាពយ៉ាងខ្លាំងដែលច្បាប់តម្រូវឱ្យចៅក្រមស៊ើបសួរ គោរពនូវលក្ខខណ្ឌទាំងនោះ ទើបអាចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនបាន។ ជាគោលការណ៍មុន និងចេញដីកាបង្គាប់ឱ្យចាប់ខ្លួនទៅលើជនត្រូវចោទ ត្រូវតែជូនដំណឹងទៅតំណាងអយ្យការ ដែលបានធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។[២៥] យោបល់របស់តំណាងអយ្យការអាចមានការឯកភាព ឬមិនឯកភាពតែមិនមែនជាកាតព្វកិច្ចសម្រាប់ចៅក្រមស៊ើបសួរឡើយ ចំពោះយោបល់ មិនឯកភាពឱ្យធ្វើការចាប់ខ្លួនជនត្រូវចោទ។

*-លក្ខខណ្ឌ* អាចចាប់ខ្លួនជនត្រូវចោទ ឬបុគ្គលមានពិរុទ្ធភាពដូចជា៖ ជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមដែលដាក់ទោសពន្ធនាគារ និងជនត្រូវចោទត្រូវបាននគរបាលមានសមត្ថកិច្ចបានបញ្ជាក់អំពីការរត់គេចខ្លួន ឬចាកចេញពីមូលដ្ឋានមិនដឹងស្ថិតនៅទីកន្លែងណា ឬ

---

[២៣] យោងតាមសៀវភៅនីតិវិធីព្រហ្មទណ្ឌនៃ រ.ប.ស.វ.ត ដីកាបង្គាប់នាំខ្លួន,ទំព័រទី ៥៧ ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០០៦។

[២៤] អនុលោមមាត្រា ១៩០ មាត្រា១៩២ និងមាត្រា១៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[២៥] អនុលោមមាត្រា ១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

ស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដីកាបង្គាប់ឱ្យចាប់ខ្លួនគឺជាវិធានការឱ្យស្រាវជ្រាវតាមចាប់ខ្លួន និងនាំខ្លួនជនត្រូវចោទទៅពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដែលមានបញ្ជាក់បង្គាប់ឱ្យទទួល និងឃុំខ្លួនជនត្រូវចោទក្នុងដីកាបង្គាប់ឱ្យចាប់ខ្លួនដល់ប្រធានពន្ធនាគារ ឬប្រធានមណ្ឌលតែម្តង។[២៦] ត្រូវតែគោរពរលើពេលវេលាដែលច្បាប់ហាមឃាត់ការចូលទៅក្នុងលំនៅឋានមុនពេលម៉ោង **៦ព្រឹក** និងក្រោយ **ម៉ោង ១៨**។ ក្នុងករណីដែលត្រូវឃុំខ្លួននៅក្រៅដែនសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ និងមិនអាចបញ្ជូនខ្លួនជនត្រូវចោទដែលចាប់ខ្លួនជនត្រូវចោទមកចំពោះមុខចៅក្រមស៊ើបសួរបានទេ ត្រូវបានស្តាប់ចម្លើយដោយតំណាងអយ្យការនៅទីកន្លែងត្រូវបានចាប់ខ្លួន។

### ១.២.វិធានការត្រួតពិនិត្យរបស់តុលាការ

ជាយន្តការមួយនៅដំណាក់កាលចៅក្រមស៊ើបសួរ ដែលអនុញ្ញាតឱ្យចៅក្រមស៊ើបសួរធ្វើការសម្រេចអំពីសិទ្ធិសេរីភាពរបស់ជនត្រូវចោទដែលកំពុងតែបង្ហាញខ្លួននៅចំពោះខ្លួនថា តើគួរតែមានវិធានការយ៉ាងណា? ដើម្បីធានាថាជនត្រូវចោទនឹងបង្ហាញខ្លួនគ្រប់ពេលដែលនីតិវិធីត្រូវការ និងការបង្ការនូវការប្រព្រឹត្តបទល្មើសជាថ្មី ឬបង្កនូវឧបសគ្គដល់ការស្រាវជ្រាវការពិតក្នុងសំណុំរឿងក្តី។ តែទោះបីជាមានវិធានការណាមួយត្រូវតែគោរពទៅផលប្រយោជន៍ នៃការស្រាវជ្រាវបទល្មើសដែលត្រូវធ្វើឡើងតាមរយៈដីកាសម្រេចដោយមានសំអាងហេតុ និងសំអាងច្បាប់។

#### ១.២.១.ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ

ជាគោលការណ៍ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរពាក់ព័ន្ធ និង សេរីភាពរបស់ជនត្រូវចោទមានពីរប្រភេទដែលចៅក្រមស៊ើបសួរ សម្រេចសេចក្តីដោយមានសំអាងហេតុចំពោះដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួនជាបណ្តោះអាសន្ន និង ដីកាសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្នដែលមិនចាំបាច់មានសំអាងហេតុអ្វីឡើយ ចំពោះករណីចេញដីកាសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្ន។[២៧]

*-ករណីសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន*

ចៅក្រមស៊ើបសួរ ត្រូវតែសម្រេចឃុំខ្លួនជាបណ្តោះអាសន្នដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬតាមរយៈដីកាសន្និដ្ឋានស្នើសុំឱ្យឃុំខ្លួនជាបណ្តោះអាសន្នរបស់តំណាងអយ្យការ។ ចំពោះការសម្រេចឃុំខ្លួនជាបណ្តោះអាសន្នអាចធ្វើទៅបានលុះត្រាតែទោសដាក់ពន្ធនាគារស្មើ ឬលើសពី **០១ឆ្នាំ** ឡើងទៅ និងជាជនត្រូវចោទ មានអាយុយ៉ាងតិច **១៤ឆ្នាំ** ឡើងទៅរួមទាំងមានមូលហេតុណាមួយក្នុងបញ្ញត្តិច្បាប់បានកំណត់ទុកជាមុន។

*-ករណីសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្ន*

ការសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្នចៅក្រមស៊ើបសួរត្រូវតែពិនិត្យនិង ពិចារណានូវលក្ខខណ្ឌផ្សេងៗ ដើម្បីធានាឱ្យបាននូវការចូលបង្ហាញខ្លួននៅតុលាការគ្រប់ដំណាក់កាលនីតិវិធី និងបង្ការឱ្យបាននូវការបង្កនូវឧបសគ្គដល់ដំណើរការ នៃនីតិវិធីស្រាវជ្រាវបទល្មើស ឬអាចត្រូវបានជនត្រូវចោទដែលខ្លួន

[២៦] អនុលោមមាត្រា ២០១ ការបង្ហាញខ្លួនតាមដីកាបង្គាប់ឱ្យចាប់ខ្លួន នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[២៧] អនុលោមមាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

បានអនុញ្ញាតឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នបំផ្លាញនូវស្នាកស្នាម ឬគម្រុយពិរុទ្ធជាងនេះ ទៅទៀតអាច ប្រព្រឹត្តបទល្មើសទៅលើជនរងគ្រោះ ឬសិទ្ធិវន្តព្រមទាំងសាក្សីដែលបានដឹងហេតុការណ៍ផងដែរ។

**១.២.២.ដីកាបង្គាប់ឲ្យឃុំខ្លួនជាបណ្តោះអាសន្ន**

ជាបញ្ជាបង្គាប់មកប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និង ឃុំជនដែលមានក្នុងកម្មវត្ថុនៃដីកាសម្រេចបង្គាប់ឱ្យឃុំខ្លួនជាបណ្តោះអាសន្ន រហូតដល់មានការសម្រេចផ្សេងពីនេះ។[២៨] ប្រធានពន្ធនាគារ ឬប្រធានមណ្ឌល ត្រូវតែទទួល នឹងឃុំខ្លួនជនដែលមានក្នុងកម្មវត្ថុនៃដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្តោះអាសន្នរហូតទាល់តែបានទទួលដំណឹងអំពីការដោះលែងឱ្យមានសិទ្ធិសេរីភាពវិញ។[២៩]

**ដូចជាករណី៖** យើងជាចៅក្រមស៊ើបសួរសាលាដំបូងខេត្ត...បានឃើញសំណុំលេខ........បានដីកាសន្និដ្ឋានលេខ....និងដីកាសម្រេចលេខ... នឹងយល់ថាដើម្បីបង្ការកុំឱ្យមានបទល្មើសកើតមានជាថ្មី ហេតុដូច្នេះសម្រេចបង្គាប់ឱ្យឃុំឈ្មោះ... និងបង្គាប់មកប្រធានពន្ធនាគារឱ្យទទួល និងឃុំខ្លួនជននេះឱ្យបានសម្រេចតាមដីកានេះ។

**១.២.៣.ដីកាបង្គាប់ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**

ចំពោះការដាក់ឱ្យស្ថិតនៅក្រោមការ ត្រួតពិនិត្យតាមផ្លូវតុលាការ ជាវិធានមួយសម្រាប់ដាក់ឱ្យជនត្រូវចោទ ដែលចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្ន។ ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ត្រូវតែកំណត់កាតព្វកិច្ចចំពោះជនត្រូវចោទឱ្យបានជាក់លាក់ និងច្បាស់លាស់ចំពោះកាតព្វកិច្ចដែលច្បាប់កំណត់មានរហូតដល់ទៅ **១២** ចំនុច ដោយចៅក្រមស៊ើបសួរ អាចសំអាងមានច្រើន ឬមួយ ទៅតាមកាលៈទេសៈនៃបទល្មើស ឬមានការព្រួយបារម្ភខ្លាចជនត្រូវចោទរត់គេចខ្លួន ឬលែងចូលមកបង្ហាញខ្លួនតាមការកោះហៅពីអាជ្ញាធរតុលាការ។[៣០] កាតព្វកិច្ចដែលចៅក្រមស៊ើបសួរអាចសម្រេចជ្រើសរើសបានមានដូចជា៖ **១**.មិនត្រូវចាកចេញក្រៅពីព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ **២**.មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ **៣**.មិនត្រូវទៅកាន់ ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ **៤**.ត្រូវចូលបង្ហាញខ្លួននៅចំពោះមុខមន្ត្រីនគរបាលជាតិ ឬកងរាជអាវុធតាមការកំណត់ដោយចៅក្រមស៊ើបសួរ **៥**.ត្រូវឆ្លើយតបនិងការកោះហៅដោយអ្នកជំនួសចៅក្រមស៊ើបសួរ **៦**.ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវឯកសារអត្តសញ្ញាណប័ណ្ណ **៧**.មិនត្រូវបើកបររថយន្ត **៨**.មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ **៩**.ដាក់ប្រាក់ធានា ដែលទឹកប្រាក់នេះ និងថេរវេលាបង់ប្រាក់ត្រូវកំណត់ដោយចៅក្រមស៊ើបសួរ **១០**.មិនត្រូវកាន់កាប់ ឬយកតាមនូវអាវុធ និងអាវុធដែលត្រូវបានចោទប្រកាន់ត្រូវប្រគល់ជូនការិយាល័យក្រឡាបញ្ជី **១១**.ត្រូវប្រគល់ខ្លួនគ្រូពេទ្យពិនិត្យ ដែលដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ **១២**.មិនត្រូវធ្វើសកម្មភាពវិជ្ជាជីវៈខ្លះ។ តែការអនុវត្តចំណុចទី**១២** នេះចៅក្រមស៊ើបសួរមិនអាចហាមឃាត់វិជ្ជាជីវៈខាងសហជីព និង អាណត្តិបោះឆ្នោត បានឡើយដោយសារតែវាជាការប៉ះពាល់សិទ្ធិសេរីភាពដែលធានា

[២៨] អនុលោមមាត្រា ២១៩ និងមាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[២៩] អនុលោមមាត្រា ២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៣០] អនុលោមមាត្រា ២២៣ ការត្រួតពិនិត្យតាមផ្លូវតុលាការ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

ដោយរដ្ឋធម្មនុញ្ញ និងខូចខាតប្រយោជន៍ របស់កម្មករនិយោជិត និងផលប្រយោជន៍ដែលកើតចេញពីការបោះឆ្នោតដោយប្រជាពលរដ្ឋ។

**កថាខណ្ឌ២.លក្ខខណ្ឌ និងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន**

ជាគោលការណ៍សេរីភាពរបស់ជនត្រូវចោទត្រូវតែមាន។ ច្បាប់ត្រូវតែគោរពនូវសេរីភាពរបស់បុគ្គលម្នាក់ៗ ដែលមាន ប៉ុន្តែការគោរពនូវសិទ្ធិសេរីភាពចំពោះបុគ្គលដែលបានប្រព្រឹត្តនូវអំពើណាមួយ ដែលច្បាប់បានហាមឃាត់សិទ្ធិសេរីភាព មិនត្រូវយកមកអនុវត្តឡើយក្នុងលក្ខខណ្ឌ ដើម្បីការពារនូវការប្រព្រឹត្តបទល្មើសជាថ្មី និងការពារសុវត្ថិភាពសង្គម។ ប៉ុន្តែដើម្បីអាចដកហូតនូវសេរីភាពដើរហើរ ច្បាប់បានបញ្ញត្តិអំពីលក្ខខណ្ឌ ដើម្បីដកហូតនូវសេរីភាពជាបណ្តោះអាសន្ន។ ដោយសារតែរដ្ឋធម្មនុញ្ញបានកំណត់ថា ជនជាប់ចោទកាលណាក៏ដោយត្រូវចាត់ទុកថា ជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។[៣១] ទោះបីជាច្បាប់អនុញ្ញាតផ្តល់សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរក្នុងការដកហូត នូវសិទ្ធិសេរីភាពយ៉ាងណាក៏ដោយក៏ ច្បាប់បានកំណត់រយៈពេលមួយជាក់លាក់ ក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន កាលណាហួសរយៈពេលដែលច្បាប់បានកំណត់ត្រូវតែដោះលែងឱ្យ ជនត្រូវចោទមានសិទ្ធិសេរីភាពឡើងវិញ នឹងអាចវិធានការផ្សេងៗដែលបានបញ្ញត្តិក្នុងការអនុវត្តវិធានការត្រួតពិនិត្យ និង តាមដានជនត្រូវចោទ ដើម្បីដំណើរការនីតិវិធីនិងធានាថាជនត្រូវចោទចូលមកបង្ហាញគ្រប់ដំណាក់កាលនីតិវិធីរបស់តុលាការ។

**២.១.កម្មវត្ថុនៃការឃុំខ្លួនជាបណ្តោះអាសន្ន**

ដើម្បីអាចឱ្យចៅក្រមស៊ើបសួរ ធ្វើការឃុំខ្លួនលើជនត្រូវចោទជាបណ្តោះអាសន្នត្រូវតែគោរពទៅលើលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់។ ទោះបីជាច្បាប់បានផ្តល់នូវសិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរ យ៉ាងណាក៏ដោយត្រូវតែពិចារណាទៅលើបុគ្គលិកលក្ខណៈ របស់ជនត្រូវចោទដែលអាចរស់នៅក្នុងពន្ធនាគារជាពិសេសសុខភាពនឹងសតិអារម្មណ៍ រួមទាំងផលប្រយោជន៍នៃកិច្ចនីតិវិធីជាចម្បងទោះបីជាច្បាប់មិន ចែងតែនេះជាឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ ក្រៅពីនេះត្រូវតែមានលក្ខខណ្ឌ ដែលច្បាប់បានកំណត់ ទើបចៅក្រមស៊ើបសួរអាចឃុំខ្លួនជាបណ្តោះអាសន្នបាន។

**២.១.១.លក្ខខណ្ឌនៃបុគ្គលដែលត្រូវបានចោទប្រកាន់**

គោលការណ៍អនីតិជន ដែលបានប្រព្រឹត្តបទល្មើសដែលមានអាយុតិចជាង **១៤ឆ្នាំ** មិនទទួលអាយុតិចជាង **១៤ឆ្នាំ** ក៏ត្រូវបានបន្តនីតិវិធីរហូតមកដល់ដំណាក់កាលចៅក្រមស៊ើបសួរ? អាចដោយសារតែតំណាងអយ្យការ បានបើកការស៊ើបសួរនូវសំណុំរឿង ដែលមានអនីតិជនដែលមានអាយុតិចជាង **១៤ ឆ្នាំ** មកជាមួយ នឹងមិនអាចវិនិច្ឆ័យអំពីអាយុរបស់ជនជាប់សង្ស័យ ទើបចេញដីកាបញ្ជូនសំណុំរឿងឱ្យស៊ើបសួរ មកកាន់ចៅក្រមស៊ើបសួរ ទើបចៅក្រមស៊ើបសួរអាចសម្រេចលើកលែងបទចោទប្រកាន់ចំពោះអនីតិជននៅក្រោមអាយុ **១៤ឆ្នាំ** ដោយផ្អែកទៅលើភស្តុតាងគ្រប់គ្រាន់អាចបញ្ជាក់អំពីនត្ថិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។[៣២] ជនត្រូវចោទ ត្រូវតែចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែល

---

[៣១] អនុលោមមាត្រា ៣៨ កថាខណ្ឌទី៧ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣។

[៣២] អនុលោមមាត្រា៩២ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនចុះថ្ងៃទី១៤ខែកក្កដាឆ្នាំ២០១៦។

ទោសដាក់ពន្ធនាគារស្មើ ឬលើសពី **០១ឆ្នាំ** ករណីក្រៅពីនេះ ចៅក្រមស៊ើបសួរ មិនអាចអនុវត្តបញ្ញត្តិទាក់ទងនឹងការឃុំខ្លួនជាបណ្ដោះអាសន្នបានទេ ដោយសារតែបញ្ញត្តិនេះការពារនូវការដកហូតនូវសិទ្ធិសេរីភាពរបស់បុគ្គល។[៣៣]

**២.១.២.មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន**

មូលដែលច្បាប់អនុញ្ញាត ចំពោះការឃុំខ្លួនជាបណ្ដោះអាសន្ន ត្រូវតែមានយោងមូលហេតុក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលអាចមានមួយ ឬច្រើន។ ចៅក្រមស៊ើបសួរដាច់ខាតត្រូវតែសំអាងហេតុក្នុងមូលហេតុណាមួយដែលច្បាប់បានកំណត់។ មូលហេតុទាំងនោះមានដូចជាៈ **១.**ដើម្បីបញ្ចប់បទល្មើសនិងបង្ការបទល្មើសកុំឱ្យកើតមានជាថ្មី **២.**ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទនិងអ្នកសមគំនិត **៣.**ដើម្បីរក្សាភស្តុតាង និងតម្រុយជាសម្ភារៈ **៤.**ដើម្បីធានារក្សាទុក ជនត្រូវចោទជូនតុលាការតាមនីតិវិធី **៥.**ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ **៦.**ដើម្បីធានាការពារនូវសណ្ដាប់ធ្នាប់សាធារណៈ កុំឱ្យមានភាពច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស។[៣៤] **ករណីដែលៈ ក** ជនត្រូវចោទដែលបានប្រព្រឹត្ត "***ឃាតកម្មគិតទុកជាមុន***" ទៅលើជនរងគ្រោះ **ខ** ដែល បានស្លាប់បាត់បង់ជីវិតនិងជនត្រូវចោទនេះធ្លាប់មានប្រវត្តិប្រព្រឹត្តបទល្មើសជាច្រើនដង។

**២.២.រយៈពេល និងការពន្យារនៃការឃុំខ្លួនជាបណ្ដោះអាសន្ន**

រយៈពេលជាកាលកំណត់មួយដែលច្បាប់បាន គណនាពិចារណាជាមុននូវអំឡុងពេលសម្រាប់ឱ្យចៅក្រមស៊ើបសួរ សម្រេចដាក់ជនត្រូវចោទឱ្យជាប់ពន្ធនាគារជាបណ្ដោះអាសន្ន ដោយធ្វើការបែងចែកករណីជាពីដាច់ដោយឡែកពីគ្នាគឺ ករណីនីតិជន និងករណីអនីតិជន។ ដោយនីតិជនត្រូវបានកំណត់រយៈពេលសម្រាប់បទល្មើសឧក្រិដ្ឋ និងសម្រាប់បទល្មើសមជ្ឈិម។ ចំពោះអនីតិជនត្រូវបែងចែកជាអាយុមានអាយុ **១៤ឆ្នាំ** ទៅដល់ **១៦ឆ្នាំ** និង**១៦ឆ្នាំ** ដល់ក្រោម **១៨ឆ្នាំ** ដោយអាចធ្វើឃុំខ្លួនជាបណ្ដោះអាសន្នទៅតាមប្រភេទនៃបទល្មើសនីមួយៗដែលមានបទល្មើសឧក្រិដ្ឋ ឬជាបទល្មើសមជ្ឈិម។

**២.២.១.ករណីបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម**

ចំពោះករណីនេះថេរវេលា នៃការឃុំខ្លួនជាបណ្ដោះអាសន្ន ត្រូវតែប្រែប្រួលទៅតាម បទល្មើសដែលជនត្រូវចោទបានប្រព្រឹត្ត នឹងទាក់ទងជាមួយអាយុរបស់ជនត្រូវចោទដែលបានកំណត់នៅពេលដែលមានបទល្មើសបានកើតឡើង។

***-ករណីឃុំខ្លួនជាបណ្ដោះអាសន្នចំពោះនីតិជនប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងមជ្ឈិម***

ជាទូទៅនីតិជនដែលបានបទល្មើសឧក្រិដ្ឋ ចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនជាបណ្ដោះអាសន្នអតិបរមាមិនឱ្យលើសពីរយៈ **០៦ខែ** ចំពោះជនត្រូវចោទ។[៣៥] បទល្មើសមជ្ឈិមវិញ ចៅក្រមស៊ើបសួរអាចធ្វើការសម្រេចឃុំខ្លួនជាបណ្ដោះអាសន្ន អតិបរមាមិនឱ្យលើសរយៈពេល **០៤ខែ** ចំពោះជនត្រូវចោទ។[៣៦]

[៣៣] អនុលោមមាត្រា ២០៤ ករណីនៃការឃុំខ្លួនបណ្ដោះអាសន្ន នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៣៤] អនុលោមមាត្រា ២០៥ មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៣៥] អនុលោមមាត្រា ២០៨ ថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នឧក្រិដ្ឋ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៣៦] អនុលោមមាត្រា ២០៩ ថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នបទមជ្ឈិម នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

***-ករណីឃុំខ្លួនជាបណ្តោះអាសន្នចំពោះអនីតិជនប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងមជ្ឈិមៈ***

ចំពោះអនីតិជនដែលមានអាយុចាប់ពី **១៤ឆ្នាំ**ដល់ **១៦ឆ្នាំ** ចៅក្រមស៊ើបសួរ អាចធ្វើការឃុំខ្លួនជាបណ្តោះអាសន្នបានចំពោះការប្រព្រឹត្តបទល្មើសមជ្ឈិម មានរយៈពេលអតិបរមាមិនឱ្យលើសពី **០២** ខែ ចំពោះអនីតិជនដែលអាយុតិចជាង **១៦ឆ្នាំ** និងរយៈពេល **០៤ខែ** ចំពោះអនីតិជនដែលមានអាយុចាប់ពី **១៦ឆ្នាំ** ដល់ក្រោម **១៨ឆ្នាំ**។[៣៧] ចំពោះអនិតិជនដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ចៅក្រមស៊ើបសួរ នឹងអាចសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន បានដែលមានថេរវេលាអតិបរមាមិនឱ្យលើសពី **០៤ខែ** ចំពោះអនីតិជនដែលមានអាយុតិចជាង **១៦ឆ្នាំ** និងចំពោះអនិតិជនដែលមានអាយុចាប់ពី **១៦ឆ្នាំ**ទៅដល់ក្រោម **១៨ឆ្នាំ** ការឃុំខ្លួនជាបណ្តោះអាសន្នមិនឱ្យលើសពីរយៈ **០៦ខែ** ឡើយ។[៣៨] ជាពិសេសនោះការឃុំខ្លួនជាបណ្តោះអាសន្នចំពោះអនីតិជន ក្នុងបទល្មើសមជ្ឈិមមិនត្រូវលើសពីពាក់កណ្តាល នៃអប្បរមានៃទោសដែលច្បាប់បានកំណត់ឡើយ។ **ដូចជាករណី ក** បានប្រព្រឹត្តបទល្មើស "**លួច**" ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ពី **០៦ ខែ** ទៅ **៣ ឆ្នាំ** ដែលខ្លួន ទើបតែមានអាយុ ១៧ ឆ្នាំ។ អប្បរមានៃទោសកំណត់សម្រាប់អនីតិជននោះ **០៣ ខែ** ដូច្នេះ ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជាបណ្តោះអាសន្នបានតែរយៈពេលអតិបរមាត្រឹមតែ **០៣ ខែ** មិនមែន **០៤ ខែ** តាមការកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

### ២.២.២.ការពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

ជាគោលការណ៍ការពន្យារពេល នៃការឃុំខ្លួនជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវតែមានសំអាងហេតុសម្រាប់ការពន្យារនេះចំណែកការពន្យារចំពោះបទល្មើសឧក្រិដ្ឋ និងមជ្ឈិមមានការខុសប្លែកពីគ្នា។ ដោយសារតែបទល្មើសឧក្រិដ្ឋ ចៅក្រមស៊ើបសួរ ត្រូវការចំណោយពេលវេលាសម្រាប់ស្រាវជ្រាវបទល្មើសបន្ថែម និងមិនមានលក្ខខណ្ឌណាមួយ ដើម្បីដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នទេ ចៅក្រមស៊ើបសួរ អាចនឹងសម្រេចពន្យារពេលវេលាបានចំពោះតែនីតិជនតែប៉ុណ្ណោះ ដែលបានប្រព្រឹត្តបទល្មើស ចំពោះករណីអនីតិជនវិញមិនអាចធ្វើការពន្យារពេលបានឡើយ។ ចំពោះនីតិជនដែលបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចទូលំទូលាយក្នុងការពន្យារពេលឃុំខ្លួនជនត្រូវចោទជាបន្តបាន ដោយច្បាប់បានកំណត់ឱ្យចៅក្រមស៊ើបសួរមានសិទ្ធិពន្យារបាន **០២ ដង** និងរយៈពេល **០៦ខែ** ក្នុងមួយម្តងៗ។[៣៩] ចំណែកចំពោះបទល្មើសមជ្ឈិមវិញ ចៅក្រមស៊ើបសួរអាចពន្យារពរពេលបានរយៈពេល **០២ខែ** បានតែម្តងគត់។[៤០] ដែលមានដូចជាករណី ជនត្រូវចោទ **ក** ត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជាបណ្តោះអាសន្ន កាលពីថ្ងៃ**១០** ខែ**តុលា** ឆ្នាំ**២០១៧** រហូតមក ទាល់ថ្ងៃទី**១០** ខែ**មេសា** ឆ្នាំ**២០១៨** គ្រប់រយៈពេល ០៦ខែ ចំពោះបទល្មើសឧក្រិដ្ឋ តែការស្រាវជ្រាវមិនទាន់គ្រប់គ្រាន់ទេ គឺអាចសម្រេចឱ្យមានការខ្លួនជាបណ្តោះអាសន្នបន្តទៅទៀតបាន។

ᨀᨀ▯ᨀᨀ

---

[៣៧] អនុលោមមាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៣៨] អនុលោមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៣៩] អនុលោមមាត្រា ២០៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៤០] អនុលោមមាត្រា ២០៩ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

# ជំពូកទី២
# ប្រតិបត្តិការស្រាវជ្រាវបទល្មើសដោយចៅក្រមស៊ើបសួរ

ជាគោលការណ៍ដំណើរក្នុងការស្វែងរកពិរុទ្ធភាពរបស់ជនត្រូវចោទ ដោយតំណាងអយ្យការធ្វើការចោទប្រកាន់តាមរយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ ព្រះរាជអាជ្ញាដែលអាចបង្ហាញខ្លួននូវជនត្រូវចោទភ្លាមៗ ជាសំណុំរឿងជាក់ស្តែង។ ចំពោះសំណុំរឿងមិនជាក់ស្តែងច្រើនតែមិនមានខ្លួនរបស់ជនត្រូវចោទ ភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឱ្យស៊ើបសួរទេ មកចំពោះមុខចៅក្រមស៊ើបសួរ។

## ផ្នែកទី១. ដំណើរការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ

ចៅក្រមស៊ើបសួរដែលបានទទួលបន្ទុកក្នុងការស្រាវជ្រាវបទល្មើស ក្រោយពីបានទទួលបណ្តឹងពីតំណាងអយ្យការរួចមកនោះត្រូវតែ ពិនិត្យមើលទៅលើសំណុំរឿងដែលគេបានបញ្ជូនឱ្យខ្លួន ដើម្បីសិក្សា និងចាប់ផ្តើមបំពេញកិច្ចស្រាវជ្រាវស្វែងរកការពិតក្នុងនាមជាចៅក្រមស៊ើបសួរ។ ការស្រាវជ្រាវបទល្មើសក្នុងសំណុំរឿងក្តីព្រហ្មទណ្ឌទៀតសោទត្រូវធ្វើទៅតាមករណីនីមួយៗ ដែលអាចជាសំណុំរឿងជាក់ស្តែង ឬសំណុំរឿងមិនជាក់ស្តែងត្រូវអនុលោមតាមបទប្បញ្ញត្តិក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នឹងការអនុវត្តជាក់ស្តែង។

### កថាខណ្ឌ១. កិច្ចដំបូងក្នុងការស្រាវជ្រាវបទល្មើស

ករណីទូទៅសំណុំរឿង ដែលតំណាងអយ្យការបញ្ជូនមកឱ្យចៅក្រមស៊ើបសួរតែងតែមានភ្ជាប់នូវ គ្រប់ឯកសារ ដែលត្រូវបានកសាងដោយមន្រ្តីនគរបាលយុត្តិធម៌ និងតំណាងអយ្យការដែលមានដូចជាៈ កំណត់ ហេតុស្តីពីការសួរចម្លើយរបស់ជនសង្ស័យ កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ជនរងគ្រោះ ឬដើមបណ្តឹង រដ្ឋប្បវេណី កំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សី និងកំណត់ហេតុស្តីពីការឃាត់ខ្លួនជនសង្ស័យ រួមទាំង វត្ថុតាង និងឯកសារផ្សេងៗទៀតដែលមានតម្លៃជាភស្តុតាងក្នុងបទល្មើសនោះ។ ដោយឡែកនៅអយ្យការវិញ មានដូចជាៈ កំណត់ស្តីពីការសួរចម្លើយរបស់ជនសង្ស័យ ដីកាសន្និដ្ឋានស្នើសុំឱ្យឃុំខ្លួនបណ្តោះអាសន្ន ដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឱ្យស៊ើបសួរជាអាទិ៍។

#### ១.១.ការសួរចម្លើយជនត្រូវចោទ

ការសួរចម្លើយជនត្រូវចោទ គឺជាកិច្ចដែលចាំបាច់របស់ចៅក្រមស៊ើបសួរ ត្រូវតែសួរនូវរាល់សំនួរធ្វើកំណត់ហេតុស្តីការបង្ហាញខ្លួន បង្ហាញខ្លួនលើកដំបូង កំណត់ហេតុស្តីពីការពិភាក្សាដេញដោលចំពោះមុខ និងកំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ។ ក្នុងករណីពិសេសចៅក្រមស៊ើបសួរមិនអាចសួរចម្លើយជនត្រូវចោទ ជាអនីតិជនបានឡើយ ត្រូវតែមានមេធាវីអមជានិច្ចដែលមេធាវីអាចត្រូវបានដោយប្រធានសាលាដំបូង ឬជ្រើសរើសដោយ ឆន្ទះរបស់ជនត្រូវចោទចំពោះមេធាវីការពារសិទ្ធិ។[៤១]

#### ១.១.១.កំណត់ហេតុស្តីពីការបង្ហាញខ្លួនលើកដំបូង

ការបង្ហាញខ្លួនជនត្រូវចោទលើកដំបូងនៅចំពោះមុខចៅក្រមស៊ើបសួរ ត្រូវតែធ្វើកំណត់ហេតុដែលមានបញ្ជាក់អំពីបន្ទប់របស់ចៅក្រមស៊ើបសួរ.. លេខសំណុំរឿង...ចុះថ្ងៃទី...ខែ...ឆ្នាំ... និង ព្រមទាំង

[៤១] អនុលោមមាត្រា១៤៣ការចូលដំណឹងអំពីការដាក់ឱ្យនៅក្រោមការពិនិត្យនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ខែសីហាឆ្នាំ២០០៧។

មានឈ្មោះថៅក្រមស៊ើបសួរ ក្រឡាបញ្ជី ដែលបានកត់ត្រានូវកំណត់ហេតុនោះ។ ថៅក្រមស៊ើបសួរ ត្រូវពិនិត្យមើល អត្តសញ្ញាណរបស់ជនត្រូវចោទ ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមាន ការខុសគ្នា ឬដូចគ្នា ឬទេ? ដែលមានគោលបំណងក្តាប់ឱ្យបាននូវអត្តសញ្ញាណរបស់ជនត្រូវចោទ កុំ ឱ្យការភាន់ច្រឡំ អំពីអត្តសញ្ញាណរបស់ជនត្រូវចោទផ្សេងៗ គ្នាទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ន ប្រវត្តិនៃការប្រព្រឹត្តបទល្មើសថាធ្លាប់បានប្រព្រឹត្តបទល្មើស ឬមិនធ្លាប់ពីមុនមកនោះ។ ស្ថានភាពរបស់ ជនត្រូវចោទ ជារឿងសំខាន់នឹងចាំបាច់ កាលណាជនត្រូវចោទខ្វះនូវសមត្ថភាពណាមួយនោះ ថៅក្រម ស៊ើបសួរ មានករណីកិច្ចចាត់នូវវិធានការភ្លាមៗដើម្បីការពារនូវសិទ្ធិស្របច្បាប់របស់ជនត្រូវចោទ។[៤២]

បន្ទាប់មកទៀតនោះថៅក្រមស៊ើបសួរត្រូវតែប្រាប់នូវសិទ្ធិសំខាន់ៗ ដល់ជនត្រូវចោទមានដូច ជាៈបទល្មើសដែលត្រូវបានតំណាងអយ្យការធ្វើការចោទប្រកាន់ បទប្បញ្ញត្តិច្បាប់កំណត់បទល្មើស និង សិទ្ធិមិនឆ្លើយនឹងសំនួរ សិទ្ធិពឹងពាក់មេធាវី សិទ្ធិស្នើសុំចាត់តាំងមេធាវី សិទ្ធិស្នើសុំឱ្យស៊ើបសួរ សិទ្ធិ ដាក់បណ្តឹង មោឃភាពនីតិវិធី សិទ្ធិបណ្តឹងទៅសភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ សិទ្ធិទទួលបានអ្នកបក ប្រែ និង សិទ្ធិស្នើ សុំបិទការស៊ើបសួរក្រោយផុតរយៈ **០១ឆ្នាំ** និងកិច្ចផ្សេងៗ ទៀតដែលថៅក្រមស៊ើបសួរ នឹងសម្រេចក្រោយពីការបញ្ចប់កិច្ចបង្ហាញខ្លួនរបស់ ជនត្រូវចោទលើកដំបូង។[៤៣] គោលបំណងក្នុង ការធ្វើកំណត់ហេតុនេះ ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវដែលថៅក្រមស៊ើបសួរ បានអនុលោមទៅតាម វិធានដែលច្បាប់បានកំណត់ និង ដើម្បីតុលាការជាន់ខ្ពស់បានយល់អំពីរឿងរ៉ាវនៅពេលមានការ តវ៉ា ដែលតម្រូវឱ្យថៅក្រមស៊ើបសួរ ធ្វើកិច្ចនេះ ករណីដែល ថៅក្រមស៊ើបសួរមិនបានបំពេញកិច្ចនេះទេ និងអាចនាំឱ្យមានការប្តឹងអំពីកិច្ចដែល ថៅក្រមស៊ើបសួរមិនបានបំពេញ និងក្នុងគោលការណ៍ទទួលបាន ដំណឹងអំពីបទចោទជាមុននឹងការ ដំណើរការរឿងក្តីព្រហ្មទណ្ឌដោយថៅក្រមស៊ើបសួរ។ កំណត់ហេតុ នេះត្រូវតែអានឱ្យជនត្រូវចោទស្តាប់ និងប្រសិនជា មិនមានការជំទាស់អ្វីទេនោះ ត្រូវតែឱ្យជនត្រូវចោទ ផ្តិតម្រាមដៃ នឹងចុះហត្ថលេខាដោយថៅក្រមស៊ើបសួរ ក្រឡាបញ្ជី មេធាវី អ្នកបកប្រែ ទុកជាភស្តុតាង ក្នុងសំណុំរឿង។[៤៤]

### ១.១.២.កំណត់ស្តីពីការពិភាក្សាដេញដោលចំពោះមុខ

បង្ហាញនូវភាពគ្មានកំហុសក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដូចជាអ្វី ដែលព្រះរាជអាជ្ញាបាន ធ្វើការចោទមកលើខ្លួន និងតាមពាក្យបណ្តឹងរបស់ជនរងគ្រោះដោយមានការអនុញ្ញាតពី ថៅក្រមស៊ើបសួរ លើកគ្រប់សំនួរត្រូវមានគោលបំណងបង្ហាញពីការពិត នៃបទល្មើសទាំងសំនួររបស់ព្រះរាជអាជ្ញា មេធាវី អាចធ្វើជំទាស់ប្រឆាំងមិនឱ្យសួរ នូវសំនួរណាមួយបាន ដោយសារតែ ជាសំនួរមិនបានបង្ហាញនូវភាព ត្រឹមត្រូវនៃអង្គហេតុ ឬមិនពាក់ព័ន្ធអង្គហេតុសោះ ឬប៉ះពាល់ដល់ សត្តិអារម្មណ៍របស់ជនត្រូវចោទ ឬ ជនរងគ្រោះ។ គ្រាប់ការជំទាស់ត្រូវតែមានហេតុផលសមរម្យ និង ការសម្រេចយល់ព្រមឱ្យសួរសំនួរ ឬ មិនឱ្យសួរត្រូវសម្រេចដោយឥស្សរចិត្តរបស់ ថៅក្រមស៊ើបសួរ គ្រប់ការដែលមិនអនុញ្ញាតឱ្យសួរសំនួរណា

[៤២] អនុលោមមាត្រា ១៤៤ ជំនួយរបស់អ្នកបកប្រែ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[៤៣] អនុលោមមាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[៤៤] អនុលោមមាត្រា២៤១ វិធានដោយឡែក នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

មួយនោះ ចៅក្រមស៊ើបសួរត្រូវតែឱ្យក្រឡាបញ្ជី ខ្លួនកត់ត្រាចូលក្នុងកំណត់ហេតុទាំងអស់។ គ្រប់សំនួរដែលបានសួរអាចជាសំនួរនាំមុខ សំនួរបកស្រាយ ឬសំនួរបិទមុខ។[៤៥] មេធាវី និងតំណាងអយ្យការធ្វើការសាកសួរទៅលើជនត្រូវចោទ ជនរងគ្រោះ ដើមបណ្តឹង រដ្ឋប្បវេណី ឬសាក្សីបាន។ ប៉ុន្តែជនត្រូវចោទ ឬជនរងគ្រោះ ក៏អាចសួរសំនួរបានតាមរយៈចៅក្រមស៊ើបសួរដែរ។ ជាគោលការណ៍សាក្សីមុននឹងឆ្លើយនូវសំនួរត្រូវតែធ្វើសម្បថជាមុននៅចំពោះ មុខវត្ថុសក្តិសិទ្ធិលើកលែង តែសាក្សីមួយចំនួន គឺពុំចាំបាច់ធ្វើសម្បថដូចមានក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។[៤៦]

**១.១.៣.កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ**

ជនត្រូវចោទ ដែលបានចូលមកបង្ហាញខ្លួននៅចំពោះមុខ ចៅក្រមស៊ើបសួរ ត្រូវតែសួរចម្លើយនូវរាល់សំនួរអ្វីៗ ដែលចៅក្រមស៊ើបសួរយល់ឃើញថាមានភាពចាំបាច់ ដើម្បីបង្ហាញនូវការពិតក្នុងអង្គហេតុ ដែលត្រូវបានតំណាងអយ្យការ ធ្វើការចោទប្រកាន់។ ជាគោលការណ៍ជនត្រូវចោទជាអនីតិជនត្រូវតែមានមេធាវីអមជានិច្ច នៅពេលចៅក្រមស៊ើបសួរធ្វើការសួរចម្លើយ ករណីណាក៏ដោយចៅក្រមស៊ើបសួរមិនអាចសួរចម្លើយ ជនត្រូវចោទដែលជាអនីតិជនដោយគ្មានមេធាវីអមបានឡើយ ករណីដែលធ្វើផ្ទុយពីនេះនឹងនាំឱ្យមានការប្តឹងសុំមោឃភាពនៃកិច្ចនីតិវិធី។[៤៧] ចំពោះជនត្រូវចោទដែលមានមេធាវីរួចហើយនោះ ចៅក្រមស៊ើបសួរត្រូវតែធ្វើការកោះហៅយ៉ាងតិច **០៥ ថ្ងៃមុន** នៃការសួរចម្លើយ។[៤៨] ជាអញ្ញត្រកម្មចំពោះករណី ជនត្រូវចោទបានបង្ហាញឆន្ទះក្នុងការបង់បោះមេធាវី ឬក៏ ជាករណីពិសេសដែលស្របពេលចៅក្រមស៊ើបសួរ យល់ឃើញថា មានចាំបាច់សំរាប់ការសួរចម្លើយជនត្រូវចោទនោះ ដោយមិនចាំបាច់រងចាំវត្តមានមេធាវីអមឡើយ ក្នុងករណីដែលមានការបារម្ភខ្លាចបាត់បង់នូវតម្រុយនៃភស្តុតាង ឬអាចមានមូលហេតុនឹងបណ្តាលឱ្យមាន មរណភាពរបស់ជនត្រូវចោទនោះ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទ បានដោយមិនចាំបាច់មានវត្តមានរបស់មេធាវីទេ។[៤៩] ការធ្វើសេចក្តីសន្និដ្ឋានការពារក្តីក្នុងគោលបំណងការពារ និង ផលប្រយោជន៍ស្របច្បាប់របស់ជនត្រូវចោទ ឬបំភ្លឺ នូវហេតុការពិតជាក់ស្តែងត្រឹមត្រូវ នៃហេតុការណ៍ដែលត្រូវបាន ព្រះរាជអាជ្ញាធ្វើការប្តឹងចោទប្រកាន់មកចៅក្រមស៊ើបសួរ ជនពាក់ព័ន្ធក្នុងអង្គហេតុ នឹងវត្ថុតាង ឬមិនបានព្រឹត្តដូចអ្វីៗដែលតំណាងអយ្យការធ្វើការប្តឹងចោទប្រកាន់ ដើម្បីអាចឱ្យ ចៅក្រមស៊ើបសួរមានលទ្ធភាពគ្រប់គ្រាន់ក្នុងការស្វែងរកការពិតនឹងអាចស្រាវជ្រាវតាមអ្វីៗដែលជាចម្លើយរបស់ ជនត្រូវចោទដែលបានចង្អុលបង្ហាញនូវជនពាក់ព័ន្ធ ឬវត្ថុតាងក្រោយពីមានការប្រព្រឹត្តបទល្មើស និងមធ្យោបាយផ្សេងៗក្នុងការប្រព្រឹត្តបទល្មើស។គ្រប់ការបោះបង់មេធាវី ឬករណីបន្ទាន់ ឬការកោះហៅមេធាវីត្រឹមត្រូវតែមិនបានចូលមកតាមការកំណត់កាលបរិច្ឆេទទេ កំណត់ដោយចៅក្រមស៊ើបសួរ ត្រូវតែកត់ត្រាចូលនៅក្នុងកំណត់ហេតុ ដោយត្រឹមត្រូវអំពីហេតុការណ៍ទាំងនោះនៅ

[៤៥] យោងសៀវភៅនីតិភស្តុតាង របស់លោកចៅក្រម **អ៊ិន បូជា** ពុម្ពផ្សាយលើកទី២ ឆ្នាំ២០១៦។

[៤៦] យោងឧបសម្ពន្ធលេខ ១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។

[៤៧] អនុលោមមាត្រា ១៤៣ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៤៨] យោងមេរៀននីតិវិធីព្រហ្មទណ្ឌ ចំណុច **ក** ការសួរចម្លើយជនត្រូវចោទ រ.ប.ស.វ.ត.កចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦។

[៤៩] អនុលោមមាត្រា ១៤៥ ផ្នែកទី២ ការសួរចម្លើយជនត្រូវចោទ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

កំណត់ហេតុសួរចម្លើយជនត្រូវចោទដោយក្រឡាបញ្ជី។ គ្រប់កំណត់ហេតុត្រូវតែមានហត្ថលេខារបស់ចៅក្រមស៊ើបសួរ ក្រឡាបញ្ជី និង ស្នាមម្រាមដៃរបស់ ជនត្រូវចោទទុកជាភស្តុតាងក្នុងសំណុំរឿងក្តី។

*-ជាបទពិសោធអនុវត្តជាក់ស្តែងនៅសាលាដំបូងថ្នាល់៖*

ករណីមានខ្លួនជនត្រូវចោទ ជនត្រូវចោទដែលត្រូវបានកងកម្លាំងនាំយកមកបង្ហាញខ្លួនភ្លាមៗនៅចំពោះមុខចៅក្រមស៊ើបសួរ (*ក្រឡាបញ្ជីជាអ្នកសួរជំនួស*) ភ្ជាប់ជាមួយនឹងសំណុំរឿងដែលត្រូវបានតំណាងអយ្យការបើកការស៊ើបសួរ នោះចៅក្រមស៊ើបសួរគឺត្រូវតែឱ្យក្រឡាបញ្ជីធ្វើកំណត់ហេតុ **បីប្រភេទ** សំរាប់ជនត្រូវចោទម្នាក់ៗ ដែលមានកំណត់ហេតុលេខ ***១ ២ ៣*** ខាងលើ។ ប៉ុន្តែកំណត់ហេតុដែលមានភាពចាំបាច់សរសេរមុនគេគឺ កំណត់ហេតុទី **៣** ក្នុងការសួរចម្លើយជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវតែប្រាប់នូវសិទ្ធិសំខាន់ៗដល់ជនត្រូវចោទ បើសិនជាគ្មានការស្នើសុំអ្វីផ្សេងពីជនត្រូវចោទទេគឺចៅក្រមស៊ើបសួរ អាចចាប់ផ្តើមសួរចម្លើយជនត្រូវចោទតែម្តង។ យើងជាចៅក្រមស៊ើបសួរ បានប្រាប់នូវសិទ្ធិដល់អ្នករួចអស់ហើយ តើអ្នកអាចឆ្លើយនឹងសំនួររបស់យើងបានដោយខ្លួនឯង? តើគ្រប់ចម្លើយដែលអ្នកបានឆ្លើយ នៅចំពោះមុខមន្រ្តីនគរបាលយុត្តិធម៌។[៥០] ចំពោះមុខតំណាងអយ្យការមានការជំទាស់អ្វីទេ ឬមានការបង្ខិតបង្ខំដែរឬយ៉ាងណាដែរ? រក្សាទុកចម្លើយដែលអ្នក បានឆ្លើយនៅដំណាក់កាលនគរបាល និង តំណាងអយ្យការទាំងស្រុង ឬចំណុចណាខ្លះ? គេឃាត់ខ្លួន អ្នកនៅកាលបរិច្ឆេទណា និងនៅទីកន្លែងណា? ចូលរាប់រៀបរាប់អំពីការចាប់ផ្តើមប្រព្រឹត្តបទល្មើសរហូត ដល់ពេលដែលញ្ចប់យ៉ាងណាខ្លះ? មូលហេតុអ្វីបានជាអ្នកប្រព្រឹត្តបទល្មើស? មានការស្តាយក្រោយនូវអំពីរបស់អ្នកដែរឬទេ? អ្នកចង់កែប្រែខ្លួនជាពលរដ្ឋល្អវិញឬទេ?មានអ្នកណាខ្លះចូលរួមប្រព្រឹត្ត?អ្នកគេចខ្លួនដឹងនៅកន្លែងណាខ្លះទេឬទេ? តើអ្នកអាចសហការជាមួយនឹងយើងបង្ហាញនូវមុខ ជនផ្សេងទៀត?។ ជាសម្តីចុងក្រោយរបស់អ្នកមានអ្វីជាការស្នើសុំ ឬសំណូមពរអ្វីខ្លះដល់តុលាការដែរ ឬទេ?។

**ដូចជាករណី**លោក **ក** បានប្រព្រឹត្តបទល្មើស "***អំពើលួច***" និងត្រូវបានតំណាងអយ្យការចោទប្រកាន់តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៦** នៃក្រមព្រហ្មទណ្ឌ នឹងបើកការស៊ើបសួរតាមដានរកនូវពិរុទ្ធភាពរបស់ជនត្រូវចោទចៅក្រមស៊ើបសួរ អាចប្រើប្រាស់អំណាចបង្ខំដែលមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីឱ្យជននោះចូលមកចំពោះមុខខ្លួនជាចៅក្រមស៊ើបសួរ គោលបំណងមកបំភ្លឺនូវរឿងហេតុដែលពាក់ព័ន្ធ និង អំពើរបស់ជននោះ។ គ្រប់ការសួរចម្លើយ គឺដូចគ្នាទៅនឹងករណីដែលមានខ្លួនក្នុងសំណុំរឿងមកភ្លាមៗ ផងដែរ។ ដូចជាករណីនៅ ***ថ្ងៃអង្គារ ០៩កើត ខែស្រាពណ៍ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១*** ត្រូវនឹងថ្ងៃទី០១ខែសីហា ឆ្នាំ២០១៧ ប្រជាពលរដ្ឋបានចូលរុករកជ័រឈើក្នុងព្រៃបានប្រទះឃើញ សាកសពស្អុយរលួយនៅក្នុងព្រៃដោយមានស្នាមអារកដោយបន្សល់ទុក នូវអត្តសញ្ញាណប័ណ្ណកាបូបលុយ និង មានសរសៃសក់ជាប់នឹងដៃរបស់សព ប្តឹងរាយការណ៍មកសមត្ថកិច្ចតែសមត្ថកិច្ចមិនបានចាប់អារម្មណ៍ បន្តនីតិវិធីរហូតដល់ចៅក្រមស៊ើបសួរ។ ដូច្នេះចៅក្រមស៊ើបសួរ អាចសម្រេចចិត្តក្នុងការប្រើប្រាស់វិធានការ និរន្តណាមួយ ដើម្បីបង្គាប់ឲ្យជនដែលសង្ស័យថា មានការពាក់ព័ន្ធអង្គហេតុខាងលើចូលមកចំពោះមុខខ្លួនបាន។

[៥០] មន្ត្រីនគរបាលយុត្តិធម៌សំដៅដល់មន្ត្រីនគរបាលជាតិ ឬកងរាជអាវុធហត្ថ និងមន្ត្រីសាធារណៈផ្សេងៗដែលទទួលបាននីតិសម្បទា។

### ១.២.ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ

ការស្តាប់ចម្លើយជនរងគ្រោះ ឬដើមបណ្តឹងអាចផ្តល់នូវអត្ថន័យថាជា កិច្ចដែលចៅក្រមស៊ើបសួរស្តាប់គ្រប់នូវការរៀបរាប់របស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចូលមកបង្ហាញនៅចំពោះមុខចៅក្រមស៊ើបសួរ។[៥១] ដោយសារតែជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីជាភាគីនៃសំណុំរឿងក្តីព្រហ្មទណ្ឌចៅក្រមស៊ើបសួរ ត្រូវស្តាប់នូវរាល់ការបំភ្លឺនូវហេតុការណ៍កើតឡើងទៅលើជនរងគ្រោះ ឬដើមបណ្តឹង រដ្ឋប្បវេណីដែលបានដឹងអំពីហេតុការណ៍។

#### ១.២.១.កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ

ជនដែលបានទទួលរងគ្រោះនូវព្យសនកម្មដែលប្រព្រឹត្តដោយ ជនត្រូវចោទ អាចចូលមកនៅចំពោះមុខចៅក្រមស៊ើបសួរ នៅពេលណាក៏បាននៅម៉ោងរដ្ឋបាល ដើម្បីស្នើសុំឱ្យចៅក្រមស៊ើបសួរទទួលនូវពាក្យបណ្តឹងដែលជនរងគ្រោះបានទទួលរង។ ចំពោះជនរងគ្រោះ ដែលមិនបានចូលមកចំពោះមុខតុលាការនោះចៅក្រមស៊ើបសួរក៏អាចចេញ ដីកាកោះហៅជនរងគ្រោះឱ្យមកចំពោះមុខខ្លួនដោយកំណត់ពេលវេលា និងទីកន្លែង រួមទាំងម៉ោងនៃការស្តាប់ចម្លើយនឹងឱ្យ ជនរងគ្រោះយកមកជាភ្ជាប់នូវឯកសារសំខាន់ៗសម្រាប់បំភ្លឺអង្គហេតុដែលបានកើតឡើងលើខ្លួន។ នៅពេលដែលជនរងគ្រោះបានមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរនោះ។ គ្រប់ការស្តាប់ចម្លើយរបស់ជនរងគ្រោះ បានរៀបរាប់ប្រាប់ដល់ចៅក្រមស៊ើបសួរ ត្រូវតែឱ្យក្រឡាបញ្ជីកត់ត្រានូវរាល់អ្វីបានឆ្លើយដោយជនរងគ្រោះ។ ចំពោះដើមបណ្តឹងមានមេធាវី ចៅក្រមស៊ើបសួរត្រូវអនុវត្តដូចនឹងគ្នា និងបទប្បញ្ញត្តិស្តីពីការសួរចម្លើយជនត្រូវចោទ។ ប៉ុន្តែក្នុងរឿងក្តីព្រហ្មទណ្ឌ ទោះបីជាដើមបណ្តឹងរដ្ឋប្បវេណីមាន មេធាវីក៏ដោយគឺមិនអាចឱ្យមេធាវីឆ្លើយជំនួសជនរងគ្រោះ ឡើយដោយសារតែមានតែសាមីខ្លួនតែប៉ុណ្ណោះ ទើបអាចដឹងគ្រប់ហេតុការណ៍បាន និងអាចបង្ហាញប្រាប់នូវពត៌មានចាំបាច់ និងអារម្មណ៍ដែលបានជួបហេតុការណ៍ផ្ទាល់ភ្នែក។[៥២]

**ជាករណីដែល៖** ជនរងគ្រោះឈ្មោះ ត ត្រូវបានជនត្រូវចោទ "*ឆបោក*"ប្រាក់អស់ចំនួន **១០ លានរៀល** ដោយប្រើប្រាស់នូវឋានៈក្លែងក្លាយ ដើម្បីធ្វើឱ្យជនរងគ្រោះឈ្មោះ **ត** ប្រគល់ប្រាក់នោះ តែម្តងដោយសារតែការជឿជាក់ទៅលើឋានៈដែលជនត្រូវចោទបានប្រើប្រាស់ជាមធ្យោបាយ។

***-ជាបទពិសោធអនុវត្តជាក់ស្តែងនៅសាលាដំបូងផ្ទាល់៖***

ជនរងគ្រោះដែលបានដាក់ពាក្យបណ្តឹងនៅមន្ត្រីនគរបាលយុត្តិធម៌ ឬតំណាងអយ្យការបានភ្ជាប់នូវសំណុំរឿងក្តីដែលត្រូវបានបើកការស៊ើបសួរនោះ ចៅក្រមស៊ើបសួរតែងតែកោះហៅមកបំភ្លឺនូវចំណុចខ្លះៗបន្ថែមពីលើកំណត់ហេតុដែលដើមបណ្តឹងបានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ ឬមិនទាន់បានឆ្លើយសោះនោះ តម្រូវឱ្យមកឆ្លើយបញ្ជាក់អំពីអង្គហេតុដែលខ្លួនបានដឹងឮ នឹងចង្អុលបង្ហាញជនពាក់ព័ន្ធផ្សេងៗទៀតដែលបានចូលរួមប្រព្រឹត្ត និងសាក្សីដែលបានឃើញ ឬដឹងឮនូវហេតុការណ៍នោះ។ ចៅក្រមស៊ើបសួរនូវសំនួរ ដើម្បីអាចឱ្យដើមបណ្តឹងបានរៀបរាប់ប្រាប់នូវអ្វីៗជាការពិតនិងទាក់ទងនឹងអង្គហេតុដែលបានកើតឡើងព្រមទាំងបង្ហាញនូវភស្តុតាងដែលមានការជាប់ទាក់ទងគ្នា។ ហើយសំនួរក្នុងការសួរមិនខុសពីការសួរ

[៥១] យោងតាមសៀវភៅនីតិវិធីព្រហ្មទណ្ឌរបស់ រ.ប.ស.វ.ត.ការស្តាប់ចម្លើយ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦។

[៥២] អនុលោមមាត្រា ១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

ចម្លើយជនត្រូវចោទទេ គ្រាន់តែមានលក្ខខណៈដាក់បន្ទុកទៅលើជនត្រូវចោទច្រើនជាងខុសពីការសួរចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ ដើមបណ្ដឹងត្រូវប្រាប់អំពីទំហំនៃសំណងការខូចខាត និងសំណងជំងឺចិត្ត ឬអាចបង្ហាញឆន្ទៈក្នុងការបោះបង់សិទ្ធិបេតិកភ័ណ្ឌរបស់ខ្លួននៅ ចំពោះមុខចៅក្រមស៊ើបសួរ។[៥៣] ហើយគ្រប់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវស្តាប់ចម្លើយនៅ ចំពោះមុខមេធាវីតែប៉ុណ្ណោះ។ លើកលែងតែមានករណីពិសេស ដែលមានកំណត់ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដែលបានកំណត់ ចំពោះការស្តាប់ចម្លើយដោយមិនចាំបាច់មាន វត្តមានមេធាវីអម ករណីដូចជនត្រូវចោទផងដែរ និង កំណត់ហេតុដែលធ្វើរួចត្រូវចុះហត្ថលេខាចៅក្រមស៊ើបសួរ ក្រឡាបញ្ជី មេធាវី (*ប្រសិនជាមាន*) ស្នាមម្រាមដៃរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬជនរងគ្រោះ។[៥៤]

**ករណីដែលមាន** ជនរងគ្រោះ **ក** ត្រូវជនត្រូវចោទ **ខ** បានប្រើដំបងវាយត្រូវចំដៃខាងស្តាំបណ្ដាលឱ្យរបួសបាក់ដៃមួយកំណាត់ដោយមានវិកាយប័ត្រចេញដោយមន្ទីរពេទ្យកាលម៉ែត្រ ដោយអស់ថ្លៃព្យាបាលជំងឺអស់ចំនួន *USD ១.000* (*មួយពាន់ដុល្លាអាមេរិក*)។

## ១.៣.ការស្តាប់ចម្លើយសាក្សី

ជនដែលត្រូវបានស្ថិតនៅក្នុងស្ថានភាព ដែលអាចដឹងនឹងស្ដាប់ឮ ឬឃើញនូវហេតុការណ៍ដែលត្រូវបាននគរបាលយុត្តិធម៌ ធ្វើការកសាងសំណុំរឿងមកតុលាការ និងត្រូវបានជនរងគ្រោះ ឬជនត្រូវចោទដែលបានចង្អុលបង្ហាញអត្តសញ្ញាណរបស់សាក្សីតាមមរយៈការសួរចម្លើយ។ ជនដែលត្រូវបានកោះហៅក្នុងនាមសាក្សីដោយចៅក្រមស៊ើបសួរត្រូវតែចូលខ្លួន។ ទោះបីជាសាក្សីនោះត្រូវបានភាគីណាមួយលើកឡើងក៏ដោយក៏ត្រូវតែចូលមកកាន់សាលាដំបូងនឹងឆ្លើយនូវអ្វីៗដែលខ្លួនបានដឹងស្ដាប់ឮ ឬឃើញតែប៉ុណ្ណោះ ករណីផ្ទុយពីនេះអាចជាបង្ករឱ្យមាននូវធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ "*បទផ្ដល់សក្ខីកម្មក្លែងក្លាយ*"។[៥៥] សាក្សីបានឆ្លើយចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ ឬចំពោះមុខតំណាងអយ្យការ ដោយចៅក្រមស៊ើបសួរអាចកោះហៅមកធ្វើការបញ្ជាក់បន្ថែមនៅចំពោះមុខខ្លួន ដើម្បីប្រាកដប្រជាថាអ្វីៗដែលបានឆ្លើយនៅក្នុងកំណត់ហេតុស្ដីពីការស្តាប់ចម្លើយ គឺមានភាពត្រឹមត្រូវគ្មានការបង្ខិតបង្ខំ ចំពោះហេតុការណ៍ណាមួយក្នុងការដាក់បន្ទុក ឬដោះបន្ទុកចំពោះអង្គហេតុ។ ករណីដែលចៅក្រមស៊ើបសួរ ធ្វើការកោះហៅត្រឹមត្រូវដោយមានកំណត់កាលបរិច្ឆេទតែមិនមកបង្ហាញខ្លួន នោះចៅក្រមស៊ើបសួរនឹងអាចស្នើសុំឱ្យកងកម្លាំងសាធារណៈបង្ខំសាក្សីដែលបានដឹងថាខ្លួនមានកាតព្វកិច្ច ចំពោះការចូលមកឆ្លើយនូវរាល់ហេតុទាំងឡាយដែលខ្លួនអាចបង្ហាញអំពីភាពគ្មានពិរុទ្ធ ឬមានពិរុទ្ធភាពចំពោះជនត្រូវ ឬមានការចង្អុលបង្ហាញនូវភស្តុតាងណាមួយបាន។[៥៦]

### ១.៣.១.ការធ្វើសម្បថ និងករណីលើកលែង

ជាគោលការណ៍ចំពោះជនដែលត្រូវបាន ចៅក្រមស៊ើបសួរអាចកោះហៅក្នុងឋានៈជាសាក្សីត្រូវតែធ្វើសច្ចាប្រណិធានជាមុន នឹងឆ្លើយនូវគ្រប់ហេតុការណ៍ដែលខ្លួនបានដឹងនៅចំពោះមុខចៅក្រមស៊ើបសួរ

[៥៣] អនុលោមមាត្រា ២៥ កថាខណ្ឌទី ១ ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៥៤] អនុលោមមាត្រា ១៥០ និងមាត្រា១៥៣ ការស្តាប់ចម្លើយសាក្សី នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃ១០ ខែសីហា ឆ្នាំ២០០៧។

[៥៥] អនុលោមមាត្រា ៥៤៥ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

[៥៦] អនុលោមមាត្រា ១៥៣ កថាខណ្ឌទី ៤ នៃក្រមព្រហ្មទណ្ឌនីតិវិធី ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

ដោយចម្លើយសាក្សីអាចដាក់បន្ទុក ឬដោះបន្ទុកមុននឹងឆ្លើយត្រូវតែធ្វើសម្បថនៅ ចំពោះមុខវត្ថុស័ក្តសិទ្ធិនៅតាមសាលាដំបូងនីមួយៗ ចំពោះអ្នកកាន់សាសនាព្រះពុទ្ធ ឬក្រៅពីនេះត្រូវសម្បថតាមទំនៀមទំលាប់ ឬសាសនារបស់ខ្លួនមុននឹងឆ្លើយប្រាប់អំពីហេតុការណ៍ដែលខ្លួនបានដឹងដល់ចៅក្រមស៊ើបសួរ។

***ករណីជាអញ្ញត្រកម្មចំពោះជនមួយចំនួនត្រូវបានច្បាប់មិនអនុញ្ញាតឱ្យធ្វើសម្បថដូចជាៈ***

១-ឪពុក ម្ដាយ និងបុព្វជនផ្ទាល់របស់ជនត្រូវចោទ

២-កូន ចៅ និងបច្ឆាញាតិរបស់ជនត្រូវចោទ

៣-បង ប្អូនប្រុស ស្រី របស់ជនត្រូវចោទ

៤-បងថ្លៃ ប្អូនថ្លៃរបស់ជនត្រូវចោទ

៥-ប្ដី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីជាលែងលះហើយ នឹងកុមារដែលមានអាយុតិចជាង **១៥ឆ្នាំ** មិនត្រូវបានច្បាប់ឱ្យធ្វើសម្បថឡើយ ដោយសារតែទំនាក់ទំនង និង ការស្រឡាញ់រវាងថ្នាក់ញាតិដែលមានការស្រណោះប្រណី ទោះបីជាបានដឹងហេតុពិតក៏លាក់ដែរ។ គ្រប់ការស្ដាប់ ចម្លើយរបស់ជនខាងលើគ្រាន់តែជាការបំភ្លឺដែលពុំមានតម្លៃឱ្យចៅក្រមស៊ើបសួរ ត្រូវតែជឿជាក់នូវអ្វីៗដែល បានរៀបរាប់ប្រាប់របស់ខ្លួនឡើយ។[៥៧] ដោយឡែកចំពោះអនីតិជនដែលមានអាយុតិចជាង **១៤ឆ្នាំ** ត្រូវបានទទួលស្គាល់ថាគ្រប់ចម្លើយដែលរៀបរាប់នោះគឺសុទ្ធតែជាសម្ដីដែលអាចទុកចិត្តបានកម្រិតខ្ពស់ជាងនីតិជនផ្សេងៗទៀត និងរួមមានទស្សនៈសង្គមយល់ឃើញថា មិនមានភាពសមរម្យទេ ដែលឱ្យអនីតិជនដែលមានអាយុតិចជាង **១៤ឆ្នាំ**ទៅធ្វើសម្បថសម្រាប់ហេតុការណ៍ដែលគេបានដឹង ឮឬបានឃើញអ្វីមួយដែរ។**មានដូចជាករណី គ** ជាម្ដាយរបស់ **ខ** ដែលបានដឹងថាកូនរបស់ខ្លួនបានប្រព្រឹត្តនូវ ***អំពើហិង្សា*** ទៅរូបរាងកាយ **ក** បណ្ដាលឱ្យមានរបួសស្នាមនៅខាងចំហៀងផ្ទះរបស់ខ្លួនមានតារាងវាយបាល់ទះ។

**១.៣.២.កំណាត់ហេតុស្ដីពីការស្ដាប់ចម្លើយសាក្សី**

សាក្សីគឺជាជនដែលនៅក្រៅ អំពីអង្គហេតុដែលត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ និងអាចផ្ដល់នូវប្រយោជន៍ចំពោះ កិច្ចការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរដែលកំពុងត្រូវការស្វែងរកតម្រុយពីជនមានការពាក់ព័ន្ធ និងការប្រព្រឹត្តបទល្មើសដោយជនត្រូវចោទ ឬមិនមែន។ ក្រោយពីធ្វើការសាកសួរសាក្សីចំពោះមុខចៅក្រមស៊ើបសួរ គ្រប់សំនួរដែលចៅក្រមស៊ើបសួរបានសួរ ទៅកាន់សាក្សីក្រឡាបញ្ជីត្រូវតែក្រឡាបញ្ជីតែសាកសួរសាក្សី ដែលបានចូលមក ចំពោះមុខចៅក្រមស៊ើបសួរ ត្រូវតែឆ្លើយគ្រប់សំនួរដែលបានសួរ ដោយមានក្រឡាបញ្ជីត្រូវកត់ត្រានូវគ្រប់សំនួរ និង ចម្លើយរបស់សាក្សីដែលបានរៀបរាប់ដំណើររឿងក្ដីនាពេលកើតហេតុ។ ចំពោះសាក្សីដែលមិនអាចចូលខ្លួនមកបាននៅចំពោះមុខចៅក្រមស៊ើបសួរដោយសារមានមូលហេតុនៃជំងឺ និងហេតុផ្សេងៗ ដែលចាំបាច់នោះ ចៅក្រមស៊ើបសួររួមជាមួយក្រឡាបញ្ជី អាចចុះទៅទីលំនៅឋាន របស់សាក្សី ដើម្បីស្ដាប់ចម្លើយបាន។[៥៨] ចំពោះជនណាមួយនាពេលស្ដាប់ចម្លើយបានលេចឡើងនូវតម្រុយនៃពិរុទ្ធភាព ចៅស៊ើបសួរបានសួរ តែត្រូវបញ្ឈប់ការស្ដាប់ចម្លើយ និងត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យវិញចំពោះសាក្សី នោះដែលមានការពាក់ព័ន្ធនឹងអង្គហេតុ

---

[៥៧] អនុលោមមាត្រា ១៥៦ សាក្សីដែលអនុញ្ញាតឱ្យរួចពីសម្បថ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៥៨] អនុលោមមាត្រា ១៥៨ ការចុះទៅលំនៅឋានរបស់សាក្សី នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

ដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់បន្ថែមវិញ។[៥៥]

*-ជាបទពិសោធអនុវត្តជាក់ស្តែងនៅសាលាដំបូងផ្ទាល់៖*

សាក្សីដែលបានឆ្លើយបំភ្លឺនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ចំពោះមុខតំណាងអយ្យការរួចហើយគឺ មិនសូវមានកោះហៅមកបំភ្លឺរឿងហេតុម្តងទៀតឡើយនៅចំពោះមុខ ចៅក្រមស៊ើបសួរ គឺច្រើនតែរក្សាការឆ្លើយបំភ្លឺដែលមានក្នុងកំណត់ហេតុសំណុំរឿងនោះតែម្តង។ ហើយចៅក្រមស៊ើបសួរ និងពិនិត្យផ្ទៀងផ្ទាត់ការឆ្លើយបំភ្លឺរបស់សាក្សី និង ចម្លើយដែលជនត្រូវចោទបានឆ្លើយនៅចំពោះមុខមន្ត្រីនគរយុត្តិធម៌ តំណាងអយ្យការ និង ចំពោះមុខខ្លួនថាភាពស៊ីសង្វាក់គ្នាអាចសន្និដ្ឋានថាមានពិរុទ្ធទៅលើជនត្រូវចោទ ឬគ្មាន។ ករណីលើកលែងតែមានសាក្សី ដែលចង្អុលបង្ហាញដោយដើមបណ្តឹង ឬជនត្រូវចោទតែប៉ុណ្ណោះ ដែលមិនទាន់មានការសួរចម្លើយច្រើនតែត្រូវបាន ចៅក្រមស៊ើបសួរ កោះហៅមកឆ្លើយបំភ្លឺអង្គហេតុ។ ហើយ គ្រប់កំណត់ហេតុស្តាប់ចម្លើយសាក្សី គឺត្រូវតែមានហត្ថលេខារបស់ចៅក្រមស៊ើបសួរ ក្រឡាបញ្ជី និងស្នាមម្រាមដៃរបស់ សាក្សីទុកជាភស្តុតាងនៅក្នុងសំណុំរឿងក្តី។ ចំពោះសាក្សីដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅមក នៅចំពោះមុខខ្លួននោះត្រូវតែធ្វើសម្បថ ដោយត្រូវតែដឹកនាំដោយក្រឡាបញ្ជី ឬជំនួយការនាំទៅចំពោះមុខអ្នកតាក្រហម **ក** ដោយមានការអុចទៀនធូប បន្ទាប់មកទើបក្រឡាបញ្ជីប្រាប់អំពីបែបបទ នៃការធ្វើសម្បថដល់សាក្សី ដែលបញ្ញត្តិច្បាប់តម្រូវឱ្យធ្វើសម្បថមុន ទើបធ្វើការស្តាប់ចម្លើយចំពោះមុខ ចៅក្រមស៊ើបសួរដោយមានការធ្វើកំណត់ហេតុស្តីពីការធ្វើសម្បថបន្ទាប់មកក្រឡាបញ្ជី ឬជំនួយការត្រូវអានតាមពាក្យពេជន៍ដែលមានកំណត់ហេតុក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដោយ ក្រឡាបញ្ជីបានចម្លងចេញ និងសរសេរដាក់នៅក្នុងកំណត់ហេតុរួចជាស្រេចដោយគ្រាន់តែឱ្យអ្នកនោះអាន ឬថាតាមនូវពាក្យពេជន៍ទាំងនោះ ដែលបានសរសេររួចរាល់។ បន្ទាប់ពីរួចរាល់អស់ហើយត្រូវឱ្យ អ្នកស្បថផ្តិតម្រាមដៃលើកំណត់ហេតុទុកជាភស្តុតាងក្នុងសំណុំរឿងក្តីនឹង បើសិនជាមានសាក្សីច្រើនរូបត្រូវអានសរុបតែម្តង និង ត្រូវធ្វើកំណត់ហេតុម្នាក់មួយៗ ដោយដាច់ដោយឡែកសម្រាប់សាក្សីម្នាក់។ បន្ទាប់ពីបានធ្វើសម្បថរួចមក ទើបចៅក្រមស៊ើបសួរ និងធ្វើការសាកសួរទៅលើសាក្សីម្តងម្នាក់ៗ ដាច់ដោយឡែកៗពីគ្នាមានធ្វើកំណត់ហេតុដោយ ក្រឡាបញ្ជី ដោយគ្រប់សំនួរចំពោះសាក្សីនីមួយៗ ចៅក្រមស៊ើបសួរត្រូវសួរនូវគ្រប់ហេតុការណ៍ដែលចាំបាច់សំរាប់បំភ្លឺ នូវអង្គហេតុដែលបានកើតឡើងអំពើដែលជនត្រូវចោទបានប្រព្រឹត្ត ឬមិនបានប្រព្រឹត្តដែលសំនួរត្រូវសួរ ដូចជា៖ តើអ្នកត្រូវយ៉ាងម៉េចជាមួយជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី? អ្នកបានឃើញហេតុការណ៍អ្វីខ្លះ?នៅពេលនោះ? អ្នកណាខ្លះដែលអ្នកស្គាល់? តើមានអ្នកណាទៀតដែលបានឃើញហេតុការណ៍នោះ? តើវាកើតហេតុនៅទីកន្លែងណា? ពេលវេលាណា? អ្នកណាធ្វើអំពើយ៉ាងណាខ្លះ? មានអ្នកចូលឃាត់ដែរ ឬទេ? តើ ហេតុការណ៍នោះបញ្ចប់ដោយសារអ្វី? តើអ្នកនៅចម្ងាយប៉ុន្មានម៉ែត្រពីទីកន្លែងប្រព្រឹត្តបទល្មើសដែល បានកើតឡើង? តើអ្នកស្ថិតនៅក្នុងស្ថានភាពស្រវឹង ឬស្មារតីគ្រប់គ្រាន់ដែរឬទេ? អ្នកណាខ្លះដែលអ្នកឃើញកំពុងស្ថិតក្នុងហេតុការណ៍នោះ?។ ដូចជាករណី **ក** បានដើររកត្រីនៅវាលស្រែនៅខាងក្រោយផ្ទះ របស់ឈ្មោះ **ខ** ក៏បានក្រឡេក

[៥៥] អនុលោមមាត្រា ១៥៧, និង មាត្រា១៤៣ គ្មានលទ្ធភាពស្តាប់ចម្លើយសាក្សីមួយចំនួន និងការជូនដំណឹងអំពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

មើលទៅខាងមុខ ប្រហែលជាង ៥០ ម៉ែត្រ ក៏ស្រាប់តែឃើញមានស្រមោលរាងខ្មៅៗ កំពុងតែអោនដើប នៅទីនោះពេលខ្លួនកំពុងតែរត់ទៅក៏មើលឃើញ ស្រមោលនោះបានរត់ទៅបាត់ ដោយបន្សល់ទុកនូវស្បែកជើងមួយគូរ និងសាកសពមនុស្សស្រីម្នាក់នៅទីនោះ តែបានដាច់ខ្យល់ស្លាប់បាត់រួចហើយដោយមិនដឹងថាអ្នកណាជាអ្នកប្រព្រឹត្តនូវអំពើនេះឡើយ។

**កថាខណ្ឌ២.ការឆែកឆេរ និងធ្វើកោសលវិច្ឆយ**

ក្រោយពីពេលដែលចៅក្រមស៊ើបសួរ ធ្វើការត្រួតពិនិត្យសំណុំរឿង និងព្រមទាំងបានទទួលចម្លើយទាំងជនត្រូវចោទ ជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី និង សាក្សីដែលបានធ្វើការចង្អុលបង្ហាញនូវតម្រុយខ្លះៗ មានការពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវបានតំណាងអយ្យការបានធ្វើការចោទប្រកាន់។ ចៅក្រមស៊ើបសួរ ត្រូវពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿងដែលខ្លួនមិនអាចយល់ដឹងបាន និងទីកន្លែងដែលគួរ ឱ្យសង្ស័យមានលាក់ទុកនូវវត្ថុតាង ឬស្លាកស្នាមដែលអាចបំភ្លឺនូវរាល់អង្គហេតុដែលសំដែងឱ្យឃើញនូវការពិតចាំបាច់ត្រូវតែធ្វើកិច្ចនោះ ដោយខានមិនបានដោយធ្វើការឆែកឆេរ ឬចាត់តាំងអ្នកជំនាញក្នុងការធ្វើកោសលវិច័យទៅលើវត្ថុនោះតែម្ដង។ ការធ្វើការឆែកឆេរត្រូវតែគោរពទៅតាមទម្រង់នីតិវិធីព្រហ្មទណ្ឌដែលបានកំណត់ឲ្យមានការធ្វើកោសលវិច្ឆយ និងត្រូវធ្វើការចាត់តាំងអ្នកជំនាញផ្នែកបច្ចេកទេសធ្វើកោសលវិច័យទៅលើវត្ថុតាង នៃការប្រព្រឹត្តបទល្មើសអាស្រ័យទៅលើជំនាញនីមួយៗមានដូចជា៖វិស័យជំនាញនៃក្រសួងមហាផ្ទៃ វិស័យជំនាញនៃក្រសួងសុខាភិបាលវិស័យជំនាញនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ វិស័យជំនាញនៃក្រសួងបរិស្ថាន ឬមួយវិស័យជំនាញនៃក្រសួងដែលមានការពាក់ព័ន្ធផ្សេងៗទៀត។

**ករណីដូចជា៖** គ្រឿងញៀនថ្នាំពេទ្យ របួសស្នាម សាកសព ស្នាមម្រាមដៃហត្ថលេខា ត្រា.ល.។

**ករណីដូចជា៖** មនុស្សស្លាប់នៅក្នុងហាងកាត់សក់ ក្នុងឃ្លាំងរក្សាទុកទំនិញធំៗ មន្ទីរពេទ្យ ឬទីកន្លែងដែលបិតបាំង ត្រូវតែធ្វើការឆែកឆេរដើម្បីស្វែងរកវត្ថុ ឬតម្រុយនៃការប្រព្រឹត្តបទល្មើស .ល. ។

**២.១.ការឆែកឆេរទីកន្លែងដែលពាក់ព័ន្ធនឹងបទល្មើស**

ចៅក្រមស៊ើបសួរ ដែលបានត្រួតពិនិត្យទៅលើសំណុំរឿងក្ដី ឬបានសួរចម្លើយជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងសាក្សីដែលគួរឱ្យសង្ស័យនូវតម្រុយពិរុទ្ធ ឬភាពគ្មានពិរុទ្ធភាពទៅលើជនត្រូវចោទ អាចចុះទៅធ្វើការស្រាវជ្រាវបន្ថែមនៅទីកន្លែងដែលកើតហេតុនោះ ដើម្បីពិនិត្យអំពីសភាពដើមក្រោយពីការប្រព្រឹត្តបទល្មើស ឬស្នាកស្នាមដែលអាចបន្សល់ទុកក្រោយពីការប្រព្រឹត្តបទល្មើសដែលមន្ត្រី នគរបាលមិនបានចាប់អារម្មណ៍នូវស្នាកស្នាមតូចៗ ដែលជាអាចមានប្រយោជន៍ក្នុងការបង្ហាញនូវដានពិសេសណាមួយដែលមានបន្សល់ទុកក្រោយពីការប្រព្រឹត្តបទល្មើស។[៦០]

ចៅក្រមស៊ើបសួរ អាចចុះទៅដល់គ្រប់ទីកន្លែងនៅលើវិសាលភាព ទូទាំងប្រទេសកម្ពុជាដែលខ្លួនយល់ឃើញថាទីនោះអាចមានប្រយោជន៍សម្រាប់សំដែងឱ្យ ឃើញការពិតនៃអង្គហេតុនោះ ចៅក្រមស៊ើបសួរ អាចធ្វើដំណើរចុះទៅលើដែនសមត្ថកិច្ច ឬក្រៅដែនសមត្ថកិច្ចរបស់ខ្លួនសម្រាប់ការស្រាវជ្រាវ និងស្វែងរកភស្តុតាង ក្នុងចំណាត់ការនៃការតាមដានរបស់ខ្លួន។ នៅពេលខ្លួនចុះទៅទីកន្លែងផ្ទាល់ត្រូវ

[៦០] យោងតាមសៀវភៅ នីតិវិធីព្រហ្មទណ្ឌ.វ.ប.វ.ត.ការចុះទៅដល់ទីកន្លែងកើតហេតុ ចុះថ្ងៃ២៥ ខែ សីហា ឆ្នាំ២០០៦។

មានអមដោយ ក្រឡាបញ្ជីមួយរូបសម្រាប់កត់ត្រា ដោយធ្វើកំណត់ហេតុសម្រាប់ការចុះទៅដល់ទីកន្លែងកើតហេតុរបស់ ចៅក្រមស៊ើបសួរក្នុងការបំពេញនូវកិច្ចផ្សេងៗ ដោយត្រូវតែជូនដំណឹងទៅតំណាងអយ្យការក្នុងដែនសមត្ថកិច្ច ឬក៏ក្រៅសមត្ថកិច្ចតាមករណីនីមួយៗ ដែលអាចអមដំណើរជាមួយខ្លួនចុះទៅដល់ទីកន្លែងកើតហេតុ ឬទីកន្លែងដែលខ្លួនយល់ឃើញថាមានភាពចាំបាច់ ដើម្បីធ្វើការពិនិត្យសម្ភារៈស្នាកស្នាម ដោយឆែកឆេររួម ទាំងអាចចាប់យកវត្ថុតាងនានា ដែលមានប្រយោជន៍សំរាប់បំភ្លឺដល់ការពិតនៃអង្គហេតុ។[៦១] ដូចជាករណី **ក** ជា ជនត្រូវចោទពី "***បទឃាតកម្មគិតទុកជាមុន***" បានសារភាពថាខ្លួនពិតជាបានសម្លាប់ **ខ** នៅក្នុងឃ្លាំង ទំនិញឈ្មោះ **ស** ដោយបានលាក់ដាវនៅក្នុងធុងសាំងពណ៌ក្រហមមានគូសសញ្ញាសម្គាល់រូបខ្វែង។

**២.១.១.ទីលំនៅឋាន ឬទីសំណាក់**

ចៅក្រមស៊ើបសួរ អាចធ្វើការឆែកឆេរនៅគ្រប់ទីកន្លែងទាំងអស់ដែលមានការពាក់ព័ន្ធនឹងបទល្មើសបានកើតឡើង និងទីកន្លែងដែលសង្ស័យថា អាចមានវត្ថុតាងលាក់បាំងមើលមិនឃើញ តែជាករណីលើកលែង ចំពោះទីកន្លែងពិសេសមួយចំនួនដូចជា( ***ស្ថានទូត ឬស្ថានអគ្គកុងស៊ុល...)***ចៅក្រមស៊ើបសួរមិនអាចចូលទៅធ្វើការឆែកឆេរបានឡើយ។ចៅក្រមស៊ើបសួរ អាចធ្វើការឆែកឆេរនៅទីកន្លែងដែលបិទជិតគួរឱ្យសង្ស័យថាមានអ្វីមួយដែលមិនអាចមើលឃើញថា ប្រសិនជាមិនចូលទៅរុករកនៅក្នុងទីកន្លែងនោះដោយមានអមជាមួយកម្លាំងសាធារណៈ។[៦២] ជាគោលការណ៍ ចៅក្រមស៊ើបសួរត្រូវតែធ្វើការឆែកឆេរនៅតែចំពោះមុខអ្នកកាន់កាប់ទីកន្លែង (***ទាំងកម្មសិទ្ធិ និងអ្នកកាន់កាន់ផ្ទាល់***) ប៉ុន្តែចំពោះទីកន្លែង ឬ ទីសំណាក់គ្មានអ្នកកាន់កាប់ទេ ចៅក្រមស៊ើបសួរត្រូវតែធ្វើការចាត់តាំងដោយដីកាសម្រេចចំពោះសាក្សីពីររូបដែលមិនមែន ជាអ្នករួមប្រតិបត្តិការណ៍ជាមួយខ្លួនទេ។ សាក្សីអាចជាប្រជាពលរដ្ឋដែលរស់នៅជិតខាង ឬជ្រើសរើសដូចជា ***មេភូមិនិងមេឃុំ /ចៅសង្កាត់*** តែម្តងដើម្បីធ្វើជាសាក្សីដឹងឮ នឹងធានានូវភាពត្រឹមត្រូវក្នុងការអនុវត្តច្បាប់ ដោយមិនអោយមានការប៉ះពាល់នូវទ្រព្យសម្បត្តិណាមួយដែលមិនជាប់ពាក់ព័ន្ធនឹងបទល្មើស និងការពារនូវការបាត់បង់នូវទ្រព្យសម្បត្តិឯកជន។ ជាគោលការណ៍ម៉ោងពេលវេលានៃការឆែកឆេរជារឿងចាំបាច់ ដែលច្បាប់កំណត់អំពីសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរក្នុងពេលប្រតិបត្តិការណ៍ឆែកឆេរ មិនអាចធ្វើឡើង មុនម៉ោង **៦ព្រឹក** និង**ក្រោយម៉ោង ១៨**ល្ងាច បានឡើយ។ ធានានូវការមិនរំខានការសម្រាករបស់ប្រជាពលរដ្ឋ និងសិទ្ធិស្របតាមរដ្ឋធម្មនុញ្ញក្នុងការរក្សានូវសិទ្ធិមិនឱ្យមានការរំលោភលំនៅឋាន និងការឆែកឆេរលំនៅឋានសម្ភារៈវត្ថុទៅលើរូបបុគ្គលត្រូវ ធ្វើដោយស្របតាមបញ្ញត្តិច្បាប់។[៦៣] ដូចជាករណីដែល ចៅក្រមស៊ើបសួរ បានចូលធ្វើការឆែកឆេរផ្ទះរបស់ **ក** និង **ខ** ត្រូវជាឪពុកម្តាយរបស់ជនត្រូវចោទ **គ** នៅពេលវេលាម៉ោង **១៨** និង **៣០**នាទីល្ងាច ដើម្បីស្វែងរកវត្ថុតាងដែល **គ** បានលាក់ទុក ក្រោយពីការប្រព្រឹត្តបទល្មើស "***ហិង្សា ដោយប្រើអាវុធ***" នៅទីកន្លែងរោងការមិត្តភក្តិ។ ប៉ុន្តែចំពោះការឆែកឆេរ គឺគោរពតែពេលវេលានៃការចូលឆែកឆេរតែប៉ុណ្ណោះ មិនបានកំណត់

---

[៦១] អនុលោមមាត្រា ១៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការចុះដល់ទីកន្លែង ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៦២] អនុលោមមាត្រា ១៥៩ វិធានអនុវត្តចំពោះការឆែកឆេរ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៦៣] អនុលោមមាត្រា ៤០ កថាខណ្ឌទី ៣ និងទី ៤,អំពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៣។

នូវរយៈពេលនៃកិច្ចឆែកឆេរត្រូវបញ្ចប់ពេលណាឡើយ។ ហើយយើងអាចបកស្រាយថាទោះបីជាការឆែកឆេរនោះ បានហួសម៉ោងដែលច្បាប់កំណត់ក៏អាចបន្តនូវកិច្ចការរបស់ខ្លួនបានដដែលគឺ នៅតែអាចបន្តការស្រាវជ្រាវ និងស្វែងរកភស្តុតាង។ លើកលែងតែមានករណីផ្ទុយពីនេះ ចៅក្រមស៊ើបសួរអាចបញ្ជាឱ្យកងកម្លាំងសាធារណៈធ្វើការហ៊ុំព័ទ្ធទីកន្លែងនោះ រហូតដល់ពេលដែលច្បាប់ ត្រូវបានអនុញ្ញាតឱ្យធ្វើការឆែកឆេរបាន។ ដូចជាករណី ម៉ោង *១៧ ល្ងាច* ចៅក្រមស៊ើបសួរបាននាំកម្លាំង ចូលឆែកឆេរក្នុងលំនៅឋានរបស់ជនត្រូវចោទ ក្រោយមួយម៉ោងគឺដល់ម៉ោង *១៨ល្ងាច* នោះកិច្ចនៅតែបន្តរហូតដល់ចប់កិច្ចនៃការឆែកឆេររបស់ខ្លួនដែលបានសង្ស័យនូវវត្ថុតាងណាមួយ និងអាចដកហូតបាន។

ជាអញ្ញត្រកម្មចំពោះករណីដែល ចៅក្រមស៊ើបសួរ មិនចាំបាច់គោរពថេរវេលាមុនម៉ោង ***៦ព្រឹក*** និងក្រោយម៉ោង ***១៨ល្ងាច*** បានក្នុងករណីដែលមានៈ

***-ទីកន្លែងដែលបើកចំហរដល់សាធារណៈជន*** គឺជាកន្លែងដែលអាចបើកទាំងយប់ទាំងថ្ងៃ ឬបើកតែពេលយប់ ចៅក្រមស៊ើបសួរ គឺអាចចូលឆែកឆេរដោយមិនចាំបាច់គោរពនូវពេលវេលាដែលច្បាប់បាន ហាមឃាត់ឡើយដោយសារតែទីកន្លែងនោះគឺមិនមែនជាទីកន្លែងឯកជន និងសាធារណៈជនចេញចូលបាន។ ដែលមានករណីដូចជាទីកន្លែងដែលជាៈ***ភោជនីយដ្ឋានក្លឹបកំសាន្ត ការស៊ីណូ.ល.***។

***-ទីកន្លែងមានការផលិតរក្សាទុក ជួញដូរ ចែកចាយ និងការប្រើប្រាស់គ្រឿងញៀន***

ជាករណីពិសេស ដែលមិនអាចគោរពថេរវលាដោយសារតែវត្ថុតាងងាយនឹងត្រូវបំផ្លាញ និងងាយស្រួលក្នុងការលាក់បាំងដែលមិនអាចរង់ចាំរយៈពេលត្រឹមត្រូវក្នុងការឆែកឆេរទេ គឺកិច្ចនេះត្រូវតែធ្វើជាការប្រញាប់បំផុត និងមិនអោយជនត្រូវចោទ ឬជនពាក់ព័ន្ធដឹងខ្លួនជាមុនទេ។

**ដូចជាករណីៈ** ធ្វើការឆែកឆេរនៅទីតាំងផលិតគ្រឿងញៀន ក្នុងផ្ទះរបស់ជនត្រូវចោទរួមទាំងលើខ្លួនជនត្រូវចោទដែលរត់គេចខ្លួនទើបចាប់បាន រថយន្តរបស់ជនត្រូវចោទដែលជនត្រូវចោទលាក់ទុក ឬបន្ទប់សម្ងាត់ក្រោមដីរបស់ជនត្រូវចោទ.ល.។

**២.១.២.ការិយាល័យ ឬក្រុមហ៊ុនមេធាវី**

ចៅក្រមស៊ើបសួរ អាចចូលទៅឆែកឆេរក្នុងការិយាល័យមេធាវី ឬក្រុមហ៊ុនមេធាវី ក្រោយពីមានបទល្មើស បានកើតឡើងរួចមកហើយ ចៅក្រមស៊ើបសួរធ្វើការពិនិត្យនូវស្លាកស្នាមបន្ថែម ដើម្បីជាក់ច្បាស់ និងការស្វែងរកតម្រុយនៃពិរុទ្ធភាពរបស់ជនត្រូវចោទ។ ការឆែកឆេរនៅក្នុងការិយាល័យមេធាវី ឬក្រុមហ៊ុនមេធាវី មិនអាចធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ឡើយ។ មានតែចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីតែប៉ុណ្ណោះទើបអាចចូលទៅធ្វើការឆែកឆេរ និង រុករកនូវវត្ថុតាងដែលបានបន្សល់ទុកក្រោយពីបទល្មើស កើតឡើងក្នុងការិយាល័យ ឬក្រុមហ៊ុនមេធាវីដោយមានការចូលរួមពីប្រធានគណៈមេធាវី ឬប្រតិភូតរបស់ ប្រធានគណៈមេធាវីតាមការចាត់តាំងជំនួស។ ដោយសារតែក្នុងការការិយាល័យមេធាវី ឬក្រុមហ៊ុនមេធាវី ជាកន្លែងទុកនូវឯកសារនានារវាងអថិតិជន និងមេធាវីដែលត្រូវបានច្បាប់ការពារមិនឱ្យមានការយកឯកសាររបស់មេធាវីមកធ្វើជាភស្តុតាងឡើយ។[៦៤]

ចៅក្រមស៊ើបសួរ មិនអាចយកឯកសារណាមួយដែលមិនមានការពាក់ព័ន្ធនឹងកិច្ចស្រាវជ្រាវ

[៦៤]អនុលោមមាត្រា១៥៩កថាខណ្ឌទី៤ការឆែកឆេរ និងការចាប់យកវត្ថុតាងនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ខែសីហាឆ្នាំ២០០៧។

របស់ខ្លួនមកប្តឹងបរិហារបានឡើយ។ ដោយសារតែមេធាវីជាវិជ្ជាជីវៈសេរី និងរក្សាការសម្ងាត់ជូនអតិថិជន ដូចមាននៅក្រមសីលធម៌វិជ្ជាជីវៈមេធាវី ទើបមិនអនុញ្ញាតអោយមន្ត្រីនគរបាលយុត្តិធម៌ចូលទៅធ្វើការឆែកឆេរខ្លាច បារម្ភមានការលេចឡើងនូវឯកសារណាមួយ ដែលជាបទល្មើសក្នុងការស៊ើបអង្កេតបឋមរបស់មន្ត្រីនគរបាលយុត្តិធម៌ និងបារម្ភអំពីការផ្សព្វផ្សាយជាសាធារណៈនូវរាល់ពត៌មានរបស់អតិថិជន។ មិនតែប៉ុណ្ណោះច្បាប់ ក៏បានទាមទារជាដាច់ខាតចំពោះចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរបានលុះត្រាតែមានការចូលរួមពី ប្រធានគណៈមេធាវី ឬប្រតិភូតរបស់គណៈមេធាវី។[៦៥]

**ដូចជាករណី-** **ក** ជាមេធាវីដែលការពារក្តីឱ្យជនត្រូវចោទ **ខ** និងកូនក្តីរបស់ខ្លួនបានមកពិភាក្សាផ្លូវច្បាប់ក្នុងការិយាមេធាវីរបស់ **ក** ស្រាប់ពេលនោះ មានការទាស់សម្តីគ្នាយ៉ាងខ្លាំងឈានរហូតដល់មេធាវី **ក** បានដកកាំភ្លើងរបស់ខ្លួនបាញ់សម្លាប់ **ខ** តែម្តង។

***-ជាបទពិសោធអនុវត្តជាក់ស្តែងនៅសាលាដំបូងផ្ទាល់៖***

មិនសូវមានចៅក្រមស៊ើបសួរ រូបណាដែលបានចុះទៅធ្វើការស្រាវជ្រាវ និងឆែកឆេរផ្ទាល់ទេលុះត្រាតែជារឿងសំខាន់ និងមានភាពចាំបាច់ខ្លាំងដែលមិនអាចរំលងបានទើបចុះទៅដោយផ្ទាល់។ ប្រសិនជាមិន សូវមានភាពចាំបាច់ទេ ចៅក្រមស៊ើបសួរច្រើនតែធ្វើការចាត់តាំងឱ្យស៊ើបសួរជំនួស ដែលអាចប្រគល់ឱ្យទៅសមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌។ ចៅក្រមស៊ើបសួរក្រោយបានធ្វើសិក្សាទៅលើសំណុំរឿង និងចំណាត់ការកន្លងមកដោយយល់ឃើញថាមានភាពសង្ស័យនៅត្រង់ចំណុចណាមួយ ឬវត្ថុតាង និងស្លាកស្នាមដែល ជារបស់ជនត្រូវចោទបានបន្សល់ទុក ឬជនត្រូវចោទបានឆ្លើយចង្អុលបង្ហាញ ឬដើមបណ្តឹងបានឆ្លើយប្រាប់ នូវវត្ថុតាងសំខាន់ៗ ដែលអាចបង្ហាញពីពិរុទ្ធភាពរបស់ជនត្រូវចោទចៅក្រមស៊ើបសួរ អាចចុះទៅធ្វើការឆែកឆេរនៅទីកន្លែងនោះតែម្តង ដើម្បីស្វែងរកវត្ថុតាងឱ្យប្រាកដថាពិតមែនដូចជាជនត្រូវចោទបានឆ្លើយប្រាប់សម្រាប់ដោះបន្ទុក ឬដើមបណ្តឹងសម្រាប់ភស្តុតាងដាក់បន្ទុក ក្នុងការបង្ហាញនូវភាពត្រឹមត្រូវ នៃអង្គហេតុដែលបាន កើតឡើងថាតើវាយ៉ាងណាឱ្យពិតប្រាកដចំពោះអង្គដែលខ្លួនបានស្រាវជ្រាវ។

**<u>នីតិវិធីនៃការអនុវត្ត</u>** ចៅក្រមស៊ើបសួរ មុននឹងចុះធ្វើការឆែកឆេរ ឱ្យត្រឹមត្រូវតាមច្បាប់នោះត្រូវតែជូនដំណឹងដល់តំណាងអយ្យការ ទទួលបន្ទុកក្នុងការចោទប្រកាន់ឱ្យបានមុនថ្ងៃចុះទៅធ្វើការឆែកឆេរ និង បុគ្គលដែលមានការពាក់ព័ន្ធផ្សេងទៀត។ ដែលដីកាទាំងនោះមានដីកាបញ្ជូនឱ្យឆ្លើយទៅតំណាងអយ្យការ (***ដើម្បីឱ្យព្រះរាជអាជ្ញាទទួលដំណឹង និងឆ្លើយតបចូលរួម ឬមិនចូលរួម***) និងលិខិតអញ្ជើញដល់កងកម្លាំងសាធារណៈ ដើម្បីចូលរួមក្នុងកិច្ចការឆែកឆេរជាមួយខ្លួន និងរួមទាំងក្រឡាបញ្ជីខ្លួនចំពោះករណីចុះទៅដល់ទីកន្លែងលំនៅឋានឯកជន និងធ្វើការឆែកឆេរ។ ចំពោះការឆែកឆេរនៅការិយាល័យមេធាវី ឬក្រុមហ៊ុនមេធាវី ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅតំណាងអយ្យការទទួលបន្ទុក ប្រធានគណៈមេធាវី (***អាចប្រធាន គណៈ មេធាវី ឬចាត់តាំងប្រតិភូត***) និងលិខិតអញ្ជើញកងម្លាំងសាធារណៈចូលរួមប្រតិបត្តិការឆែកឆេរបាន ប៉ុន្តែកងកម្លាំងសាធារណៈមិនអាចចូលទៅក្នុងការិយាល័យ ឬក្រុមហ៊ុនមេធាវីបានឡើយ គឺនៅចាំខាងក្រៅដើម្បី ទុបស្កាត់នូវស្ថានភាពចំបាច់។ អ្នកដែលមានសិទ្ធិចូលរួមមានចៅក្រមស៊ើបសួរ

[៦៥] យោងតាមសៀវភៅមេរៀននីតិវិធីព្រហ្មទណ្ឌ វ.ប.វ ត,ចំណុច ខ កថាខណ្ឌទី ៣ ការឆែកឆេរ ចុះថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០០៦។

តំណាងអយ្យការ ប្រធាន គណៈមេធាវី ឬប្រតិភូគណៈមេធាវី និងក្រឡាបញ្ជីចូលទៅធ្វើការពិនិត្យ និងរុករកវត្ថុតាងព្រមទាំងដកហូត នូវវត្ថុតាងដោយផ្ទាល់ក្នុងការិយាល័យមេធាវី ឬក្រុមហ៊ុនមេធាវីតែម្តង ដោយមានធ្វើកំណត់ហេតុសម្រាប់ ដកហូតសម្ភារៈ។

***<u>របៀបបញ្ជូនដីកាផ្សេងៗ</u>*** ចំពោះការបញ្ជូលទៅព្រះរាជអាជ្ញាដែលទទួលបន្ទុកក្នុងការចោទប្រកាន់(***សំដៅដល់ព្រះរាជអាជ្ញាជាអ្នកចោទប្រកាន់បទបទល្មើស***) ដោយមានបញ្ជូនដីកាបញ្ជូនពតិមានដែលដីកា នេះមានឈ្មោះរបស់ចៅក្រមស៊ើបសួរ អត្តសញ្ញាណរបស់ជនត្រូវចោទ ទីកន្លែងប្រព្រឹត្តបទល្មើស កាលបរិច្ឆេទ និងមាត្រាកំណត់បទល្មើសព្រមទាំងទីកន្លែងដែលបំពេញឈ្មោះរបស់ព្រះរាជអាជ្ញា និង ការផ្តល់យោបល់នៅខាងក្រោមរួមទាំងមានការចុះកាលបរិច្ឆេទ ហត្ថលេខា ត្រារបស់ចៅក្រមស៊ើបសួរ និង តំណាងអយ្យការផងដែរនៅក្នុងដីកានោះសម្រាប់បញ្ជាក់អំពីឆន្ទះរបស់តំណាងអយ្យការ និងភាពត្រូវច្បាប់។

***<u>របៀបបញ្ជូនដីកា</u>*** ទៅកងកម្លាំងសាធារណៈ ដែលមានលិខិតអញ្ជើញចូលរួម របាយការស្តីពីការបញ្ជូន (***ករណីក្រៅដែនសមត្ថកិច្ច***) និងដីកាបញ្ជូនដោយផ្ទាល់ទៅអង្គភាពនគរបាលជាតិ ឬមេបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ក្នុងករណីក្រៅពីដែនសមត្ថកិច្ចដីការបញ្ជូនផ្ញើទៅព្រះរាជអាជ្ញាអមសាលាដំបូងនាទីកន្លែងដែលត្រូវធ្វើការឆែកឆេរនោះតែម្តង។

***<u>របៀបបញ្ជូនដីកា</u>*** ទៅប្រធានគណៈមេធាវីមាន លិខិតអញ្ជើញ ឯកឧត្តមប្រធានគណៈមេធាវី ដីកាបញ្ជូន មានរបាយការណ៍ស្តីពីការបញ្ជូន (***ករណីក្រៅដែនសមត្ថកិច្ច***) ឬដោយបញ្ជូនតាមប្រៃសណីយ៍។

### ២.១.៣.កំណត់ហេតុចាប់យកវត្ថុតាង និងការស្តាប់នូវស័ព្ទ

ចៅក្រមស៊ើបសួរត្រូវកំណត់ទីកន្លែងត្រូវឆែកឆេរ និងម៉ោងត្រូវចាប់ផ្តើម និងទីកន្លែងចាប់ផ្តើមមកជួបជុំសមាសភាពដែលត្រូវចូលរួមក្នុងការឆែកឆេរ មានករណីកិច្ចមកបង្ហាញខ្លួនតាមពេលវេលា និងទីកន្លែងដែលចៅក្រមស៊ើបសួរ បានបញ្ជាក់នៅក្នុងលិខិតដែលបានផ្ញើចេញទៅបុគ្គលពាក់ព័ន្ធ។

ពេលចូលដល់ទីន្លែងដែលត្រូវឆែកឆេរ ចៅក្រមស៊ើបសួរត្រូវបង្ហាញប្រាប់កម្មសិទ្ធិករ ឬអ្នកកាន់កាប់ទីកន្លែងអំពីការបំពេញកិច្ចឆែកឆេរ ដើម្បីធ្វើការឆែកឆេរករណីកម្មសិទ្ធិករ ឬអ្នកកាន់កាប់ទីកន្លែងមិនយល់ព្រម ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចពេញលេញក្នុងបញ្ជាឱ្យកងកម្លាំងសាធារណៈ បង្ខំចូលធ្វើការឆែកឆេរ ចំពោះមុខកម្មសិទ្ធិករ ឬអ្នកកាន់កាប់ទីកន្លែងនោះតែម្តង។ ចំពោះករណីដែលគ្មានកម្មសិទ្ធិករ ឬអ្នកកាន់កាប់ទេ ចៅក្រមស៊ើបសួរអាចធ្វើការចាត់តាំងសាក្សីពីររូប ដែលមានសមត្ថភាពតាមផ្លូវច្បាប់ (***អាចជាអ្នកជិតខាង ឬមេភូមិ មេឃុំ/ចៅសង្កាត់***) និងអាចបញ្ជាដោយផ្ទាល់ឱ្យកងកម្លាំងធ្វើការរុសរើសម្ភារៈដែលបិទបាំង ឬមិន អាចបើកបានក្នុងកម្រិតការខូចខាតអប្បរមាដោយមានការសង្ស័យថា មានលាក់ទុកនូវវត្ថុតាង។[៦៦] គ្រប់កិច្ចដែល ចៅក្រមស៊ើបសួរធ្វើការដកហូតនូវវត្ថុតាងណាមួយត្រូវតែ មានធ្វើកំណត់ហេតុដោយក្រឡាបញ្ជី ដោយ មានបញ្ជាក់នូវអត្តសញ្ញណនឹងធ្វើបញ្ជីសារពើភ័ណ្ឌ ព្រមទាំងមានបិទស្លាកនិងបោះត្រាផងដែរនៅចំពោះភាគីពាក់ព័ន្ធ។[៦៧] កំណត់ហេតុស្តីពីការឆែកឆេរត្រូវតែមានការ ចុះ

[៦៦] អនុលោមមាត្រា ៧0 សេចក្តីបង្គាប់បញ្ជាពីអាជ្ញាធរតុលាការ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១0 ខែសីហា ឆ្នាំ២00៧។

[៦៧] អនុលោមមាត្រា ១៦0 ការបិទស្លាកបោះត្រាលើវត្ថុតាង នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១0 ខែសីហា ឆ្នាំ២00៧។

ហត្ថលេខាតាមករណីនីមួយៗមានដូចជា៖ ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញា ប្រធានគណៈមេធាវី ឬប្រតិភូ ក្រឡាបញ្ជី និងអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ តាមការកំណត់របស់ក្រមនីតិវិធីព្រហ្មទណ្ឌ។ ដែលមានករណីដូចជា៖ ផ្ទះក្រោមដីដែលបានលាក់ ទុកនូវគ្រឿងញៀនចៅក្រមស៊ើបសួរ ធ្វើការបញ្ជាឱ្យកងកម្លាំងវាយកម្ទេចនូវមេសោដែលបានចាក់មាត់ទ្វារ ខាងក្រៅ និងចូលទៅធ្វើការត្រួតពិនិត្យ និងស្វែងរកវត្ថុតាង ឬជាករណីដែលការឆែកឆេរ លំនៅឋានរបស់ជនត្រូវ ចោទ ដើម្បីស្វែងរកកាំភ្លើងដែលបានបាញ់សម្លាប់ជនរងគ្រោះដែលបានលាក់ទុកនៅក្នុងផ្ទះ។ មួយវិញ ទៀតអាចធ្វើការឆែកឆេរនៅការិយាល័យ ឬក្រុមហ៊ុនមេធាវី មានការសង្ស័យថាក្រោយពីមានការ ប្រព្រឹត្តបទល្មើសអាចបន្សល់ទុកនូវតម្រុយពិរុទ្ធ ឬស្លាកស្នាម និងឧបករណ៍ផ្សេងៗ ដែលមានប្រយោជន៍ ក្នុងការបង្ហាញការពិតដែលមានតម្រុយដែលកើតចេញការឆែកឆេរ និងបង្ហាញយុត្តិធម៌បាន។

*-ការស្តាប់ទូរស័ព្ទដោយចៅក្រមស៊ើបសួរ៖*

ជាគោលការណ៍ចៅក្រមស៊ើបសួរ អាចធ្វើការលបស្តាប់នូវការឆ្លើយឆ្លងគ្នា រវាងជនត្រូវចោទ អ្នកសមគំនិត និងអ្នកផ្តើមគំនិតដើម្បីតាមដាន ដោយយកសំលេងមកធ្វើជាភស្តុតាងសម្រាប់ដាក់បន្ទុកលើជនត្រូវចោទ និង តាមស្វែងរកជនដែលមានតម្រុយពិរុទ្ធ។[៦៨] ចៅក្រមស៊ើបសួរអាចស្នើសុំឱ្យមន្ត្រីរាជការតាំងឧបករណ៍ ដើម្បីធ្វើការថត និងចម្លងសំលេងជាលាយលក្ខណ៍អក្សរជូនមកខ្លួន។ ទោះបីជាទីកន្លែងណាក៏ដោយមិនអាចហាមឃាត់ដោយយកមូលហេតុអ្វីមកប្រឆាំងជាមួយនឹងចៅក្រមស៊ើបសួរបានដែរ។

គ្រប់ពេលវេលាចៅក្រមស៊ើបសួរ អាចចុះទៅដល់ទីកន្លែងតាំងឧបករណ៍ ដើម្បីថតសំលេងឆ្លើយឆ្លងតាមប្រភេទណាក៏ដោយ និង ទោះបីជាកន្លែងយោធាក៏ដោយ។ ការស្តាប់ទូរស័ព្ទនេះចៅក្រមស៊ើបសួរអាចចេញដីកាចាត់តាំងឱ្យស៊ើបសួរជំនួស និង ឱ្យមន្ត្រីដែលទទួលភារកិច្ចត្រូវតែអនុវត្តតាម ។ គ្រប់ការជួបឧបសគ្គត្រូវតែរាយការណ៍ជូនចៅក្រមស៊ើបសួរជាបន្ទាន់ រួមទាំងក្រោយបញ្ចប់កិច្ចការត្រូវតែផ្ញើជូនចៅក្រមស៊ើបសួរទាំង សំលេង និងកំណត់ហេតុដែលចម្លងសំលេងជាលាយលក្ខណ៍អក្សរមកចៅក្រមស៊ើបសួរ។[៦៩]

**ដូចជាករណី**-ស្តាប់ទូរស័ព្ទឆ្លើយឆ្លងគ្នារវាងជនត្រូវចោទ និងបក្សពួកក្នុងសំណុំរឿងពុករលួយ។

## ២.២.ការធ្វើកោសលវិច្ឆយវត្ថុតាងចាប់យក

វត្ថុតាងទាំងឡាយណាដែលចៅក្រមស៊ើបសួរ មិនអាចវាយតម្លៃដោយខ្លួនឯងបាន ឬមានភាពចាំបាច់ក្នុងការចាត់តាំងអ្នកជំនាញ ដើម្បីធ្វើការវាយតម្លៃជំនួសខ្លួនបាន។ អ្នកជំនាញត្រូវតែបានចាត់តាំងដោយចៅក្រមស៊ើបសួរដែលមានលក្ខខណៈ ជាបច្ចេកទេសសុទ្ធសាធក្នុងការធ្វើតេស្ត៍ និងផ្តល់នូវលទ្ធផលមកចៅក្រមស៊ើបសួរវិញក្នុងការវិនិច្ឆយចំណាត់ការបន្ត។ អ្នកជំនាញទាំងនោះអាចមានពីរប្រភេទគឺជាអ្នកជំនាញមាននៅក្នុងបញ្ជីថ្នាក់ជាតិដោយសេចក្តីប្រកាសរបស់ក្រសួងយុត្តិធម៌។[៧០] ចំពោះអ្នកជំនាញដែលក្រៅពីបញ្ជីថ្នាក់ជាតិ ចៅក្រមស៊ើបសួរអាចជ្រើសតាំងបាន។ ចំពោះករណីដែលមានភាពចំបាច់ក្នុង

---

[៦៨] អនុលោមមាត្រា ១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៦៩] អនុលោមមាត្រា ១៧២ កថាខណ្ឌទី៣ និងទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[៧០] អនុលោមមាត្រា ១៦៣ បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

ការធ្វើកោសល វិច័យទៅលើស្លាកស្នាម ឬវត្ថុតាងណាមួយដែលចៅក្រមស៊ើបសួរ មិនអាចវិនិច្ឆ័យដោយខ្លួនឯងបានទៅលើវត្ថុតាងទាំងនោះ។ ការចាត់តាំងអ្នកជំនាញក្រៅពីបញ្ជីថ្នាក់ជាតិ ចៅក្រមស៊ើបសួរ ត្រូវតែឱ្យអ្នកជំនាញនោះ ធ្វើការសម្បថទៅតាមសាសនា ឬជំនឿរបស់ខ្លួននៅចំពោះមុខវត្ថុស័កសិក្តិ។[៧១] ករណីចាត់តាំងអ្នកជំនាញថ្នាក់ ជាតិមិនចាំបាច់ធ្វើស្បថម្តងទៀតឡើយ។ ដូចជាករណីសារធាតុគ្រឿងញៀន ស្នាមម្រាមដៃ សរសៃសក់ ស្នាមបាត់ជើង ឈាម ឬស្បែកមធ្យោបាយ នៃការប្រព្រឹត្តបទល្មើស .ល.។

**២.២.១.ដីកាសម្រេចចាត់តាំងអ្នកជំនាញ**

នៅពេលដែលវត្ថុដែលជាកម្មវត្ថុ នៃការធ្វើកោសលវិច័យដែលមាននៅក្នុងសំណុំរឿងចៅក្រមស៊ើបសួរ ត្រូវតែចេញដីកាសម្រេចចាត់តាំងអ្នកជំនាញ ដែលមាននៅក្នុងប្រកាសរបស់ក្រសួងយុត្តិធម៌ ឬ អ្នកជំនាញក្រៅបញ្ជីថ្នាក់ជាតិចំពោះតែលក្ខខណៈបច្ចេកទេសរបស់ អ្នកជំនាញពិសេសក្នុងការធ្វើកោសលវិច័យទៅលើ វត្ថុនោះតែម្តង ដែលគ្មានអ្នកជំនាញក្នុងបញ្ជីថ្នាក់ជាតិ។ ការធ្វើកោសលវិច័យទៅលើវត្ថុតាងត្រូវតែបញ្ជូនវត្ថុ តាងនោះភ្ជាប់ទៅជាមួយនឹងដីកាសម្រេចចាត់តាំងអ្នកជំនាញ។[៧២]

**២.២.២.លទ្ធផលនៃការធ្វើកោសលវិច័យ**

ចៅក្រមស៊ើបសួរ ដែលបានចាត់តាំងអ្នកជំនាញឱ្យបំពេញនូវកិច្ចបច្ចេកទេសផ្នែកកោសលវិច័យទៅលើវត្ថុតាង ឬស្លាកស្នាមអ្វីមួយដែលខ្លួនបានសង្ស័យថាមានការពាក់ព័ន្ធនឹងបទល្មើស និងសំណុំរឿងដែលកំពុងមានចំណាត់ការនោះ។ ម្យ៉ាងទៀតដោយខ្លួនមិនអាចវិនិច្ឆ័យបានដោយប្រើភ្នែកទទេថា តើវត្ថុតាងនោះ ឬស្លាកស្នាមនោះមានភាពត្រូវគ្នាជាមួយនឹងអំពើជនត្រូវចោទបានប្រព្រឹត្ត ឬមិនមែនទេ? ដើម្បីបញ្ជាក់អំពីពិរុទ្ធរបស់ជនត្រូវចោទ ។ ដោយសារតែវត្ថុតាងមួយចំនួនមានតែវិទ្យាសាស្ត្រ និងឯកទេសផ្នែកនោះតែប៉ុណ្ណោះដែលអាចមានចំណេះដឹង និង បទពិសោធន៍អំពីកម្មវត្ថុដែលត្រូវធ្វើ កោសលវិច័យ។[៧៣]

អ្នកជំនាញដែលត្រូវបានខ្លួនចាត់តាំង ឱ្យបំពេញកិច្ចផ្នែកបច្ចេកទេសក្រោយពីការបំពេញភារកិច្ចរួច ហើយត្រូវតែបញ្ជូននូវរះ របាយការណ៍ស្តីពីការធ្វើកោសលវិច័យ សេចក្តីសន្និដ្ឋាននិងវត្ថុតាងដែលនៅសល់នោះ ខ្លួនវិញតាមការកំណត់ពេលវេលាជាក់លាក់របស់ខ្លួនក្នុងដីកាសម្រេចចាត់តាំងអ្នកជំនាញ។ នៅពេលដែលដល់កាលកំណត់អ្នកជំនាញត្រូវតែ បញ្ជូនលទ្ធផលនោះមកចៅក្រមស៊ើបសួរវិញ ករណីមិនឃើញ ចៅក្រមស៊ើបសួរ អាចធ្វើការដាស់តឿន អ្នកជំនាញឱ្យបំពេញកិច្ចរបស់ឱ្យចប់ និងប្រគល់នូវលទ្ធផលមក ខ្លួនឱ្យបានឆាប់រហ័ស។[៧៤] ក្រោយពេលដែលបានទទួលនូវលទ្ធផល និង សេចក្តីសន្និដ្ឋានពីអ្នកជំនាញនោះ ចៅក្រមស៊ើបសួរ អាចនឹងវាយតម្លៃបានគ្រប់គ្រាន់នូវវត្ថុតាងនោះនិងបង្ហាញភាពស៊ីចង្វាក់នៃអំពើដែលជនត្រូវ ចោទថាបានប្រព្រឹត្ត ឬមិនបានប្រព្រឹត្តបទល្មើស ដូចដែលតំណាងអយ្យការបានធ្វើការចោទប្រកាន់និងការ វិនិច័យផ្ទាល់ខ្លួនឈានរហូតដល់ការសម្រេចសេចក្តីមួយត្រឹមត្រូវចំពោះ

---

[៧១] អនុលោមមាត្រា ១៦៤ ការចាត់តាំងអ្នកជំនាញដែលមិនស្ថិតក្នុងបញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៧២] យោងតាមឧបសម្ពន្ធលេខ ៣០ និង ៣៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។

[៧៣] អនុលោមមាត្រា ១៦៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៧៤] អនុលោមមាត្រា ១៦៩ របាយការណ៍របស់អ្នកជំនាញ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

ជនត្រូវចោទ។ ដូចជាករណី **ក** ជា ជនត្រូវចោទពីបទ *"ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន"* ក្រោយពីសមត្ថកិច្ចធ្វើការកសាងសំណុំរឿង និងព្រះរាជអាជ្ញាបានបើកការស៊ើបសួរមក ចៅក្រមស៊ើបសួរដោយមានការសង្ស័យថាជា សារធាតុគ្រឿងញៀន ដែលមានចំនួន **០៣** កញ្ចប់មធ្យមជារបស់ **ក** ចៅក្រមស៊ើបសួរ ត្រូវតែធ្វើកោសលវិច័យដោយចាត់តាំង អ្នកជំនាញផ្នែកគ្រឿងញៀន និងបញ្ជូននូវវត្ថុតាងទៅអ្នកជំនាញ ក្រោយពីអ្នកជំនាញបំពេញភារកិច្ចរួច ត្រូវតែបញ្ជូលលទ្ធផលនោះត្រឡប់មកចៅក្រមស៊ើបសួរ វិញដើម្បីធ្វើការវិនិច្ឆ័យ និងសម្រេចអំពីបទល្មើសដែល តំណាងអយ្យការបើកការស៊ើបសួរ។ ក្នុងគោលបំណងបំភ្លឺនូវការពិតនៃការដាក់បន្ទុកដោយចោទពីបទល្មើស គ្រឿងញៀនប្រសិនជារកឃើញសារធាតុញៀនមែន។ ការធ្វើកោសលវិច័យត្រូវតែឱ្យបានឆាប់រហ័ស និងទាន់ពេលវេលា ដើម្បីឱ្យចៅក្រមស៊ើបសួរមាន មូលដ្ឋានគ្រប់ឱ្យសមស្របគោលការណ៍គ្មានបទល្មើសបើគ្មានចេតនាប្រព្រឹត្តបទល្មើស។ [៧៥]

### ផ្នែកទី២.ការផ្ទេរសិទ្ធិអំណាចឲ្យស្រាវជ្រាវបទល្មើសជំនួស

បន្ទាប់ពីចៅក្រមស៊ើបសួរ បានប្រឹងប្រែងក្នុងការស្រាវជ្រាវបទល្មើសដោយខ្លួនឯង នឹងប្រើនូវគ្រប់មធ្យោបាយ ដើម្បីបង្ហាញនូវការពិតក្នុងសំណុំរឿង ដែលខ្លួនបានខិតខំតាមដានស្វែងរកសញ្ញាណនៃមូលហេតុក្នុងការប្រព្រឹត្តបទល្មើស។ ហើយខ្លួនយល់ឃើញថាពិសេសស្ថានភាពតម្រូវដែលមានសភាពឬកាលៈទេសៈបង្ខំណាមួយនោះ ចៅក្រមស៊ើបសួរអាចធ្វើការចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ ឬចៅក្រមផ្សេងឱ្យបំពេញ កិច្ចការណាមួយដែលមាន កំណត់ក្នុងដីកាចាត់តាំងឱ្យស៊ើបសួរជំនួសបានដោយសារតែមានការចាំបាច់ណាមួយសំរាប់បំភ្លឺនូវអង្គហេតុដែលបានកើត (*កម្រិតចំពោះមន្ត្រីនគរបាលដោយកំណត់បំពេញកិច្ចអ្វីមួយ ច្បាស់លាស់*)។[៧៦]

#### កថាខណ្ឌ១.ដីកាសម្រេចចាត់តាំងឲ្យស៊ើបសួរជំនួស

ចៅក្រមស៊ើបសួរ ដែលកំពុងតែបំពេញការស្រាវជ្រាវសំណុំរឿងក្តីដែលមាននៅក្នុងដៃខ្លួនហើយយល់ឃើញថាមានភាពចាំបាច់សំរាប់ធ្វើកិច្ចអ្វីមួយ ដើម្បីបំភ្លឺដល់អង្គហេតុ ឬភាពសង្ស័យរបស់ខ្លួនដែលខ្លួនមិនអាចចុះទៅបំពេញកិច្ចនោះបានទេដោយសារតែស្ថានភាព និង កាលៈទេសៈពិសេសដែលធ្វើឱ្យចៅក្រមស៊ើបសួរ ពិបាកក្នុងការធ្វើដំណើរ និងត្រូវចំណាយច្រើនក្នុងការ ចុះទៅទីកន្លែងឆ្ងាយៗ ពីទីកន្លែងប្រព្រឹត្តបទល្មើស ឬមានឧបសគ្គចំពោះការធ្វើដំណើរទៅមកនោះ ចៅក្រមស៊ើបសួរអាចពឹងពាក់បុគ្គលដែលច្បាប់បានផ្តល់នូវសម្បទាក្នុងការធ្វើកិច្ចការនេះ មកជំនួសខ្លួនដែលមានបញ្ញត្តិក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌដែលអាចជាចៅក្រមសាលាដំបូង ឬជាមន្ត្រីនគរបាលយុត្តិធម៌។[៧៧]

**ដូចជាករណី** បទល្មើសចរាចរណ៍កើតឡើងនៅ ***ខេត្តរតនៈគីរី*** តែក្រោយមកជនត្រូវចោទបាន រត់មករស់នៅ ***ខេត្តកណ្តាល*** ចៅក្រមស៊ើបសួរនៅ ***ខេត្តរតនៈគីរី*** អាចធ្វើការចាត់តាំងចៅក្រមសាលាដំបូងខេត្តកណ្តាលឱ្យស៊ើបសួរជំនួស និង***បញ្ជូនកំណត់ហេតុទៅសាលាដំបូងខេត្តរតនៈគីរីវិញតែម្តង***។

---

[៧៥] អនុលោមមាត្រា ៨ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។

[៧៦] អនុលោមមាត្រា ១៧៤វាក្យខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[៧៧] អនុលោមមាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

## ១.១.ការចាត់តាំងចៅក្រមផ្សេងឲ្យស្រាវជ្រាវជំនួស

ចៅក្រមស៊ើបសួរក្រោយពីសិក្សាសំណុំរឿង និងបានស្រាវជ្រាវតាមស្វែងរកតម្រុយដំណើររឿងក្តីកន្លងមកហើយ មានចំណុចណាមួយដែលគិតថាសង្ស័យថា នឹងអាចនាំទៅរកនូវការពិតរឿងហេតុបានក្រោយពីមានបទល្មើសព្រហ្មទណ្ឌបានកើតឡើង។ ចៅក្រមស៊ើបសួរអាចចាត់ចៅក្រមសាលាដំបូងណាម្នាក់ឱ្យបំពេញកិច្ចការណាមួយជំនួសខ្លួនក្នុងលក្ខខណៈជាការសម្ងាត់ ដើម្បីអាចបង្ហាញនូវភាពត្រឹមត្រូវដែលកើតចេញពីបទល្មើសនោះ។[៧៨] ក្នុងករណីពិសេសដែលចៅក្រមស៊ើបសួរយល់ឃើញថាមានភាពបន្ទាន់ អាចធ្វើការចាត់តាំង ចៅក្រមស៊ើបសួរជំនួសដែលមានសមត្ថកិច្ចកំពុងស្ថិតទីតាំងឬទីកន្លែងដែលត្រូវចុះទៅបំពេញនោះ ឱ្យធ្វើកិច្ចការស្រាវជ្រាវនោះតាមរយៈដីកាសម្រេចចាត់តាំងឱ្យស៊ើបសួរជំនួសត្រូវចេញឱ្យចៅក្រមស៊ើបសួរជំនួស ដោយប្រើប្រាស់វិធានគ្រប់បែបយ៉ាងដែលមានចែងក្នុងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ដើម្បីសម្រេចនូវគោលបំណងដែលចៅក្រមស៊ើបសួរចង់បានក្រោយពីការប្រតិបត្តិការណ៍ក្នុងការស្រាវជ្រាវជំនួស ប៉ុន្តែលើកលែងចំពោះករណីពិសេសដែលចៅក្រមស៊ើបសួរជំនួស មិនអាចធ្វើបានឡើយ (*ចេញដីសម្រេចផ្សេងៗ ដែលទាក់ទង និងសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ*) ដោយសារតែការស៊ើបសួរជំនួស មានគោលបំណងតែផ្តល់អំណាចនៃការស្រាវជ្រាវបទល្មើសតាមការណែនាំដោយ ចៅក្រមស៊ើបសួរ។ **ដូចជាករណី-** ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល បានចេញដីកាចាត់តាំងចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ ឱ្យស៊ើបសួរជំនួសក្នុងបទល្មើស"*ហិង្សាដោយចេតនា*"ប្រព្រឹត្តដោយជនត្រូវចោទ **គ** ដែលកំពុងរស់នៅខេត្តខាងលើ ដោយណែនាំឱ្យចៅក្រមសាលាដំបូងចេញដីកាបង្គាប់ឱ្យចូលខ្លួនធ្វើកំណត់ហេតុសួរចម្លើយ និងបញ្ជូនសំណុំឯកសាររបស់ជនត្រូវចោទមកសាលាដំបូងខេត្តកណ្តាល យ៉ាងឆាប់តាមការដែលអាចធ្វើបាន។

### ១.១.១.ចៅក្រមសាលាដំបូងក្នុងសមត្ថកិច្ច

អាចចាត់តាំងចៅក្រមសាលាដំបូងដែលខ្លួនកំពុងស្ថិតតែនៅជាមួយគ្នា អាចធ្វើទៅបានដោយសារតែមានភាពចាំបាច់ ក្នុងករណីដែលខ្លួនមិនអាចបំពេញកិច្ចការស្រាវជ្រាវ ណាមួយនោះ។ ជាករណីនេះនៅតាមសាលាដំបូងនីមួយៗ គឺមានចៅក្រមដែលបម្រើការងារនៅទីនោះច្រើនដែលមិនអាចចាត់តាំងដោយមានការចង្អុលឈ្មោះ ចៅក្រមដោយផ្ទាល់នោះឡើយ ច្រើនតែបញ្ជូនទៅប្រធានសាលាដំបូងតាមបែបបទរដ្ឋបាលដោយប្រធានអាចធ្វើការចាត់តាំងបន្ត ចូលមកដល់ចៅក្រមណាមួយដែលទទួលបន្ទុកក្នុងការចំណាត់ ការទៅលើដីកាសម្រេចចាត់តាំងឱ្យស៊ើបសួរជំនួសនោះតែម្តង។

### ១.១.២.ចៅក្រមសាលាដំបូងផ្សេងទៀត

ដោយសារតែ កាលៈទេសៈដែលតម្រូវក្នុងការស្រាវជ្រាវនូវតម្រុយ ឬស្វែងរកនូវចំណុចសំខាន់ណា មួយដែលចាំបាច់ធ្វើការស្រាវជ្រាវជំនួសដោយចៅក្រមស៊ើបផ្សេងទៀត ក្រៅសមត្ថកិច្ចដែនដីផ្សេងគ្នាឱ្យ បំពេញកិច្ចស្រាវជ្រាវជំនួសខ្លួន ប្រសិនជាយល់ឃើញថាមានភាពចាំបាច់សំរាប់បង្ហាញនូវពិរុទ្ធភាពនៃ ជន ត្រូវចោទនោះ អាចធ្វើការចាត់តាំងបានទៅកាន់ចៅក្រមសាលាដំបូង ដែលខ្លួនចង់ឱ្យបំពេញកិច្ចស្រាវជ្រាវ នោះក្នុងនាមខ្លួនបាន។

[៧៨] អនុលោមមាត្រា ១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧។

### ១.២.ការចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ស្រាវជ្រាវជំនួស

តាមត្រូវការជាក់ស្តែង ដើម្បីភាពងាយស្រួលក្នុងការស្រាវជ្រាវបទល្មើសមួយផ្នែកនោះចៅក្រមស៊ើបសួរ ច្រើនតែចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ឱ្យបំពេញកិច្ចស្រាវជ្រាវណាមួយដែលមានលក្ខណៈមិនសូវមានភាពស្មុគស្មាញ និងបច្ចេកទេសខ្លាំងក្នុងការស្វែងរកតម្រុយមានសមត្ថភាពសមល្មមដែលមន្ត្រីនគរបាលយុត្តិធម៌អាចធ្វើបាន ហើយមិនមានភាពចាំបាច់ណាស់ណាទេត្រូវតែធ្វើនោះឡើយ និងត្រូវបានកម្រិតភារកិច្ចឱ្យបំពេញកិច្ចស្រាវជ្រាវទៅលើផ្នែកណាមួយដោយកំណត់ច្បាស់លាស់ ក្នុងខ្លឹមសារនៃដីកាសម្រេច ចាត់តាំងឱ្យស៊ើបសួរ ជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌មិនអនុវត្តផ្ទុយពីខ្លឹមសារទេ។[៧៩]

#### ១.២.១.មន្ត្រីនគរបាលជាតិ ឬកងរាជអាវុធហត្ថ

ការចាត់តាំងឱ្យស៊ើបសួរជំនួស ដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវមានលក្ខខណៈល្អិតល្អន់នឹងជាក់លាក់ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចដែលមន្ត្រីនោះតាំងនៅ។ ទោះបីជាមានបញ្ញត្តិបើកចំហ និងការអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចក្នុងការពន្លាតដែនសមត្ថកិច្ចតាមការអនុញ្ញាត របស់ចៅក្រមស៊ើបសួរ យ៉ាងណាក៏ដោយលុះត្រាតែចៅក្រមស៊ើបសួរយល់ឃើញគួរអនុញ្ញាត។[៨០] ចំពោះការចាត់តាំងឱ្យស៊ើបសួរ ជំនួសក្នុងករណីនេះជាជម្រើសរបស់ចៅក្រមស៊ើបសួរឱ្យទៅមន្ត្រីនគរបាលជាតិ ឬកងរាជអាវុធហត្ថ ដើម្បីបំពេញកិច្ចស៊ើបសួរជំនួសនេះ។ ការរំពឹងអំពីលទ្ធផលក្រោយពីដាក់ភារកិច្ចឱ្យបំពេញដែលសមស្រប និងមានសមត្ថភាពរបស់កងរាជអាវុធហត្ថ ឬមន្ត្រីនគរបាលជាតិដោយសារតែការស្រាវជ្រាវច្រើនតែបច្ចេកទេសក្នុងការតាមដាន។ សមត្ថភាពកងរាជអាវុធ និងមន្ត្រីនគរបាលយុត្តិធម៌មានសមត្ថភាពមិនដូចគ្នាទាំងស្រុងឡើយ។ ការប្រើប្រាស់បច្ចេកទេសអាវុធ និង សម្ភារៈគឺកងរាជអាវុធមានភាពទំនើបជាង និងរហ័សជាងមន្ត្រីនគរបាលជាតិទាំងប្រព័ន្ធទំនាក់ទំនង ហើយមានភាពរហ័សទៅកិច្ចប្រតិបត្តិការណ៍ក្នុងការតាមដានគ្រប់សកម្មភាពក្នុងសង្គម។ ចំណែកមន្ត្រីនគរបាលយុត្តិធម៌បំពេញគោលដៅបានច្បាស់លាស់ និងមានភ្នាក់ងារច្រើន នៅគ្រប់ទីកន្លែងដែលមានបទពិសោធន៍ច្រើនក្នុងស្នាដៃដែលអាចបង្ក្រាបទល្មើសគ្រប់ប្រភេទនិង វែកមុខជនសង្ស័យដែលសម្ងំលាក់ខ្លួន។ កម្លាំងនគរបាលជាតិធ្វើការវែកមុខជនសង្ស័យដែលសម្ងំលាក់ការជាក្រុមដែលមាន (*ក្រុមខ្លាហោះ*) ជាកងកម្លាំងស្នូលក្នុងការចុះបង្ក្រាបគ្រប់ទីកន្លែងដែលមានស្ថានភាព ពិបាកៗ ក្នុងការវាយប្រហារ និងរំដោះជនរងគ្រោះមានប្រសិទ្ធិភាពខ្លាំងជាពិសេសកម្លាំងម៉ូតូប្រដេញរបស់នគរបាលជាតិដែលអាចធ្វើការប្រដេញ និង ចាប់ជនត្រូវចោទដែលបានដឹងខ្លួននិងកំពុងតែព្យាយាមរត់គេច ចេញពីទីកន្លែងដែលត្រូវចុះទៅឆែកឆេរ។

#### ១.២.២.មន្ត្រីរាជការសាធារណៈដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីដែលមិនមែនជានគរបាលជាតិ ឬកងរាជអាវុធហត្ថ ដែលច្បាប់ដោយឡែកបានផ្តល់នីតិសម្បទាឱ្យក្លាយជា មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការបំពេញកិច្ចស្រាវជ្រាវនោះ ណាមួយដែលមានលក្ខខណៈបច្ចេកទេសពិសេសទៅលើបទល្មើសនោះ ។[៨១] ចៅក្រមស៊ើបសួរ ដែលយល់ឃើញថាមានភាព

---

[៧៩] អនុលោមមាត្រា ១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៨០] អនុលោមមាត្រា ៦៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៨១] អនុលោមមាត្រា ៥៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

ចាំបាច់ ដើម្បីបំពេញកិច្ច ស្រាវជ្រាវ អាចធ្វើការចាត់តាំងមន្ត្រីដែលមានសមត្ថកិច្ចខាងបទល្មើសនោះឱ្យជួយស្រាវជ្រាវ និងតាមដានទៅលើផ្នែកណាមួយមានប្រយោជន៍បង្ហាញនូវការពិត ឬស្វែងរកភស្តុតាងមកបញ្ជាក់អំពីអំពើរបស់ជនត្រូវចោទ ដែលបានប្រព្រឹត្តបទល្មើសនោះ។ ដូចជាករណី៖ ***បទល្មើសនេសាទ បទល្មើសពុករលួយ បទល្មើសគេចពន្ធ បទល្មើសព្រៃឈើ.ល.*** ។

**កថាខណ្ឌ២.សិទ្ធិអំណាចនៃការស្រាវជ្រាវបទល្មើសជំនួស**

ក្រោយពីមន្ត្រីនគរបាលយុត្តិធម៌ដែលបានទទួលការចាត់តាំងពី ចៅក្រមស៊ើបសួររួចហើយនោះអំណាចទាំងអស់ ត្រូវតែស្ថិតនៅក្រោមចៅក្រមស៊ើបសួរដែលបានផ្តល់សិទ្ធិអំណាច ក្នុងការបំពេញកិច្ចស្រាវជ្រាវដែលបានណែនាំក្នុងដីកាចាត់តាំងដោយចៅក្រមស៊ើបសួរ ចេញដល់មន្ត្រីដែលបានទទួលដីកាហើយមិនអាចធ្វើកិច្ចអ្វីដោយ គ្មានការអនុញ្ញាតរបស់ចៅក្រមស៊ើបសួរ ឡើយ។ គ្រប់ការលំបាកនៅពេលបំពេញមុខងាររបស់ខ្លួនត្រូវរាយការណ៍នោះដល់ ចៅក្រមស៊ើបសួរជាបន្ទាន់។[៨២] ក្នុងករណីបន្ទាន់អាចរាយការណ៍ តាមគ្រប់មធ្យោបាយតាមការកាលដែលអាចធ្វើទៅបាន ដើម្បីជូនដំណឹងដល់ចៅក្រមស៊ើបសួរ ដែលស្ថិតនៅក្រោម និង ក្រោយពីការរាយការណ៍រួចដល់ចៅក្រមស៊ើបសួរ គ្រប់ការអនុញ្ញាតត្រូវតែមានការចុះនៅកំណត់ហេតុរបស់ខ្លួន។[៨៣] ត្រូវធ្វើការឆែកឆេរ តែម្ចាស់កម្មសិទ្ធិករ ឬអ្នកកាន់កាប់មិនឱ្យចូលខាងក្នុង។

**២.១.សិទ្ធិអំណាចដែលផ្តល់ជូនចៅក្រមស៊ើបសួរជំនួស**

ការផ្តល់ជូនអំណាចក្នុងការស្រាវជ្រាវបទល្មើសដល់ ចៅក្រមផ្សេងទៀតឱ្យស៊ើបសួរជំនួសខ្លួននោះអាចប្រើប្រាស់អំណាចទាំងអស់ដែលចៅក្រមស៊ើបសួរ មានក្នុងគោលបំណងស្រាវជ្រាវស្វែងរកការពិតតែប៉ុណ្ណោះ មិនមែនមានន័យថាអំណាចទាំងអស់ដែលក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់ជូនចៅក្រមស៊ើបសួរជំនួសទេ ទោះបីជាច្បាប់ចែងថាអាចប្រើប្រាស់អំណាចទាំងអស់នោះយ៉ាងណាក៏ដោយតែក្នុងគោលបំណងនៃការស្រាវជ្រាវបទល្មើសប៉ុណ្ណោះ អំណាចក្នុងការសម្រេចមួយចំនួនចៅក្រមស៊ើបសួរជំនួសមិនធ្វើបានឡើយ។ ដីកាចាត់តាំងឱ្យស៊ើបសួរជំនួសមិនមានលក្ខខណៈទូលាយឡើយគឺចៅក្រមស៊ើបសួរតែចង្អុលបង្ហាញ និង ស្នើសុំឱ្យបំពេញកិច្ចណាមួយជាក់លាក់ដែលជាតម្រូវការនៃការដាក់បន្ទុក ឬដោះបន្ទុកពិរុទ្ធភាព របស់ជនត្រូវចោទ ដែលចៅក្រមស៊ើបសួរបានសម្រេចឱ្យបំពេញកិច្ចស៊ើបសួរជំនួសខ្លួនមិនអាចធ្វើកិច្ចនោះដោយឯងបានក្នុង កាលៈទេសៈណាមួយជាពិសេសណាមួយ។ **ដូចជាករណី** ការសួរចម្លើយជនត្រូវចោទ ការឆែកឆេរនៅទីកន្លែងណាមួយ ការស្តាប់ចម្លើយសាក្សីមួយ ឬច្រើននាក់។

**២.១.១.ការកំណត់កិច្ចស៊ើបសួរជំនួសមួយផ្នែក**

ក្នុងដីកាចាត់តាំង ចៅក្រមសាលាដំបូងឱ្យស្រាវជ្រាវជំនួសនូវកិច្ចណាមួយ ឬមួយផ្នែកត្រូវតែកំណត់ជាក់លាក់ទៅលើកិច្ចស្រាវជ្រាវនោះ ចំពោះចៅក្រមស៊ើបសួរជំនួសដែលបានទទួលការស្នើសុំ។ ដោយសារតែចៅក្រមស៊ើបសួរជំនួស មិនបានដឹងជាមុនអំពីរឿងហេតុដែលមាននៅក្នុង សំណុំរឿងដែលគេចាត់តាំងខ្លួនឱ្យស្រាវជ្រាវជំនួសឡើយ និងជាភាពងាយស្រួលមួយផងដែរ ដើម្បីបំពេញកិច្ចស្រាវជ្រាវ

[៨២] អនុលោមមាត្រា ១៧៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៨៣] អនុលោមមាត្រា ១៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

មួយនោះឱ្យបានទាន់ពេលវេលាតាមការស្នើសុំដែលមាននៅក្នុង ដីកាចាត់តាំងរបស់ចៅក្រមស៊ើបសួរ។ នៅក្នុងដីកាសម្រេចចាត់តាំងរបស់ចៅក្រមស៊ើបសួរច្រើនតែ បង្គាប់យ៉ាងជាក់លាក់តាមកាលដែលខ្លួនយល់ឃើញថាគួរចាប់ផ្តើមឱ្យស្រាវជ្រាវពីណាទៅណា? ចំពោះចៅក្រមស៊ើបសួរជំនួសដែលភាគច្រើនត្រូវតែ បង្គាប់ដោយមានចង្អុលឈ្មោះ ជនដែលត្រូវបានស្នើសុំឱ្យធ្វើកិច្ចអ្វីមួយដូចជា៖ ចេញដីកាបង្គាប់ឱ្យ ចូលខ្លួនអត្តសញ្ញាណជនត្រូវចោទ ធ្វើកំណត់ហេតុបង្ហាញខ្លួនលើកដំបូង កំណត់ហេតុពិភាក្សាដេញដោល និង កំណត់ហេតុសួរចម្លើយជនត្រូវចោទចេញដីកាសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្ន និងចេញដីកាដាក់ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជាអាទិ៍។[៨៤]

### ២.១.២.ប្រើប្រាស់អំណាចដែលចៅក្រមស៊ើបសួរមាន

អំណាចដែលចៅក្រមស៊ើបសួរជំនួសទទួលបានតាមរយៈ ដីកាចាត់តាំងឱ្យស្រាវជ្រាវជំនួសមានគោលដៅតែមួយគត់គឺ ការជួយសម្រួលកិច្ចការស្រាវជ្រាវបទល្មើសឱ្យមានភាពឆាប់រហ័សដោយប្រើប្រាស់អំណាចដែលខ្លួន មានក្នុងការស្រាជ្រាវបទល្មើសដែលក្រមនីតិវិធីបានផ្តល់ឱ្យនោះសម្រាប់តែបង្ហាញនូវការពិតនៃអង្គហេតុដែលចៅក្រមស៊ើបសួរបានស្នើសុំឱ្យជួយបំពេញកិច្ច។ ត្រូវតែធ្វើកិច្ចនោះជាប្រញាប់កុំឱ្យមានភាពយឺតយ៉ាវ **ដូចជាករណី៖** ចៅក្រមស៊ើបសួរជំនួសត្រូវតែចេញដីកាបង្គាប់ឱ្យចូលខ្លួនដោយកំណត់ពេលវេលាដូចដែលខ្លួនបានធ្វើពីសំណុំរឿងក្តីមុនៗ ដោយបញ្ជាទៅមន្រ្តីនគរបាលយុត្តិធម៌ឱ្យប្រគល់ដីកាបង្គាប់ឱ្យចូលខ្លួនដល់ដៃជនត្រូវចោទ និង ឱ្យមកបង្ហាញខ្លួននៅសាលាដំបូងដែលខ្លួនស្ថិតនៅដោយត្រូវធ្វើកំណត់ហេតុតាមការស្នើសុំរបស់ចៅក្រមស៊ើបសួរដែលបានចាត់តាំងខ្លួន។ ពេលដែលជនត្រូវចោទចូលបង្ហាញខ្លួននៅចំពោះមុខ ខ្លួនជាចៅក្រមស៊ើបសួរជំនួសត្រូវតែប្រាប់ នូវសិទ្ធិសំខាន់ៗ មុនធ្វើការធ្វើសួរចម្លើយជនត្រូវចោទ។ ក្នុងករណីគ្មានការជំទាស់អ្វីទេចៅក្រមស៊ើបសួរ ត្រូវប្រាប់អំពីឋានៈរបស់ខ្លួនក្នុងនាមជាចៅក្រមស៊ើបសួរជំនួស ដោយធ្វើការសួរជំនួសចៅក្រមស៊ើបសួរ សាលាដំបូងខេត្តឈ្មោះ និងបទចោទប្រកាន់ដែលមាននៅក្នុងឯកសារភ្ជាប់ជាមួយដីកាសម្រេចចាត់ តាំងឱ្យស៊ើបសួរជំនួស។ បន្ទាប់ពីការសួរចម្លើយជនត្រូវចោទ ហើយត្រូវតែប្រាប់នូវអំពីសិទ្ធិសម្រេចដែល ចៅក្រមស៊ើបសួរបានស្នើសុំបន្តបន្ទាប់រហូតដល់គ្រប់នូវការស្នើសុំ។ ក្រោយពីបញ្ចប់កិច្ចដែលបានស្នើសុំរួចហើយ ត្រូវតែបញ្ជូនទៅចៅក្រមស៊ើបសួរ ដោយលើកំណត់ហេតុមានចៅក្រមស៊ើបសួរជំនួស និងក្រឡាបញ្ជីចុះហត្ថលេខា និងស្នាមម្រាមដៃជនត្រូវចោទនៅក្នុងកំណត់ហេតុទាំងឡាយចៅក្រមស៊ើបសួរ ជំនួសត្រូវធ្វើដីកាអម និងមានឯកសារពាក់ព័ន្ធនិងកិច្ចស្រាវជ្រាវជំនួសនោះទៅចៅក្រមស៊ើបសួរវិញតែម្តង។[៨៥]

### ២.២.សិទ្ធិអំណាចដែលបានកំណត់ឱ្យមន្ត្រីនគរបាលយុត្តិធម៌

ចំពោះមន្ត្រីនគរបាលយុត្តិធម៌វិញ មិនមានសិទ្ធអំណាចដូចជាការចាត់តាំងចៅក្រមសាលាដំបូងផ្សេងៗទៀតឡើយ គឺមានភាពខុសគ្នាទៅតាមកាលៈទេសៈនីមួយៗក្នុងការស្រាវជ្រាវបទល្មើស។ ជាពិសេសនោះគឺការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងជនត្រូវចោទគឺមិនអាចធ្វើបានឡើយ។ ដោយសារតែច្បាប់ការពារនូវផលប្រយោជន៍ស្របច្បាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី និង ជនត្រូវចោទដែលមិន

---

[៨៤] យោងឧបសម្ព័នលេខ ២៧ របស់សាលាដំបូងខេត្តកណ្តាល។

[៨៥] អនុលោមមាត្រា ១៣០ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

អនុញ្ញាតឱ្យ មន្ត្រីនគរបាលយុត្តិធម៌ធ្វើកិច្ចនេះទេ។ ជាគោលការណ៍ជនត្រូវចោទ និងដើមបណ្តឹងត្រូវបានសួរ នឹងស្តាប់ចម្លើយដោយចៅក្រមស៊ើបសួរប៉ុណ្ណោះ។[៨៦] កាលដែលក្រមនីតិវិធីហាមឃាត់បែបនេះគឺមន្ត្រីនគរបាលយុត្តិធម៌ធ្វើកិច្ចការស្រាវជ្រាវបទល្មើសច្រើនតែមានភាពជាក់បន្ទុកទៅជនត្រូវចោទ ឬមិនអាចធ្វើការវិនិច្ឆ័យ អំពីពន្យសនកម្មដែលកើតលើរូបរាងកាយផ្លូវអារម្មណ៍ ឬសម្ភារៈរបស់ជនរងគ្រោះ និងដើមដើមបណ្តឹងរដ្ឋប្បវេណី[៨៧] ឬដោយសារតែមន្ត្រីនគរបាលយុត្តិធម៌ អាចមានភាពលំអៀងណាមួយដែលអាចជាការត្រូវគ្នារវាង ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដោយមិនអាចសួរចម្លើយជនត្រូវចោទបានត្រឹមត្រូវ ឬដើមបណ្តឹងរដ្ឋប្បវេណី។

**២.២.១.ចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរច្បាស់លាស់**

នៅក្នុងដីកាសម្រេចចាត់តាំងមន្ត្រីនគរបាលយុត្តិធម៌ ច្រើនតែចេញឱ្យមន្ត្រីនគរបាលយុត្តធម៌ដែលជានគរបាលជាតិ ច្រើនជាងកងរាជអាវុធហត្ថដោយសារតែភាពជំនឿទុកចិត្ត និងបទពិសោធន៍ដែលធ្លាប់ធ្វើកិច្ចប្រតិបត្តិការណ៍កន្លងមកក្នុងការស្រាវជ្រាវស្វែងរកអត្តសញ្ញាណជនត្រូវចោទ។ ជាពិសេសចំពោះករណី ដែលត្រូវចុះទៅឆែកឆេរនៅទីកន្លែងដែលបិទបាំងបាននឹងសង្ស័យថា មានលាក់ទុកនូវវត្ថុតាងនិងតាម ដានជនដែលមានវិមតិសង្ស័យចូលរួមប្រព្រឹត្តបទល្មើស។ បទល្មើសដែលមានលក្ខណៈសកម្មនៅក្នុងសង្គម ឬត្រូវប្រើប្រាស់អាវុធ ដើម្បីចូលឆែកឆេរនោះច្រើនតែស្នើសុំកងកម្លាំងរាជអាវុធហត្ថធ្វើការស្រាវជ្រាវជំនួស។ ហើយចៅក្រមស៊ើបសួរត្រូវតែចង្អុលបង្ហាញ យ៉ាងជាក់លាក់អំពីកិច្ចដែលត្រូវធ្វើចំពោះការប្រតិបត្តិការណ៍ ស្រាវជ្រាវជំនួសចៅក្រមស៊ើបសួរ។[៨៨] ដែលអាចប្រាប់អំពីកិច្ចឆែកឆេរស្វែងរកវត្ថុតាងប្រភេទមួយណាឱ្យជាក់លាក់នៅទីកន្លែងណា? និង ស្តាប់ចម្លើយសាក្សីរូបណាឱ្យបានច្បាស់លាស់តាមការកំណត់នៅក្នុង ដីកាសម្រេចចាត់តាំងឱ្យស៊ើបសួរជំនួស ករណីផ្ទុយពីនេះមិនអាចធ្វើបានឡើយ ប្រសិនគ្មានការអនុញ្ញាតជាមុនពីចៅក្រមស៊ើបសួរ ចំពោះករណីដែលត្រូវធ្វើការឆែកឆេរ និងស្វែងរកវត្ថុតាងត្រូវគោរពថេរវេលាដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់ និងមានលក្ខខណ្ឌផ្សេងៗត្រូវបានយកមកអនុវត្តដូចគ្នា និងមន្ត្រីនគរជាតិ។ គ្រប់ការលំបាកទាំងឡាយដែលកើតមានក្នុងពេលឆែកឆេរត្រូវរាយការណ៍ទៅចៅក្រមស៊ើបសួរតែប៉ុណ្ណោះ។[៨៩]

ចំពោះការស្តាប់ចម្លើយសាក្សីដែលចៅក្រមស៊ើបសួរបាន ចាត់តាំងឱ្យស្តាប់ចម្លើយជំនួសអាចធ្វើការកោះហៅសាក្សីឱ្យចូលមកចំពោះមុខខ្លួនបាន តែក្នុងករណីរឹងទទឹងមិនព្រមចូលខ្លួនមន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំបញ្ជាឱ្យចូលខ្លួនពី ចៅក្រមស៊ើបសួរបាន។ ករណីដែលស្តាប់ចម្លើយសាក្សីណាមួយហើយបានលេចឡើងតម្រុយពិរុទ្ធភាពលើជននោះគឺត្រូវបញ្ឈប់ និង រាយការណ៍ជាបន្ទាន់ដល់ចៅក្រម ស៊ើបសួរ។ ករណីដែលត្រូវធ្វើការឃាត់ខ្លួនជនណាម្នាក់ត្រូវអនុវត្តដូចសិទ្ធិអំណាច ដែលមានក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងបានផ្តល់ឱ្យខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌តែគ្រប់ការអនុវត្តដោយមាន

---

[៨៦] អនុលោមមាត្រា ១៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៨៧] អនុលោមមាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៨៨] អនុលោមមាត្រា ៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៨៩] អនុលោមមាត្រា ៨១ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

ព្រះរាជអាជ្ញាត្រូវប្តូរមកសុំពីចៅក្រមស៊ើបសួរវិញ និងគ្រប់ការបំពេញនូវកិច្ចការស្រាវជ្រាវជំនួសត្រូវតែមានធ្វើកំណត់ហេតុជានិច្ចចំពោះកិច្ចប្រតិបត្តិរបស់ខ្លួន។[៦០]

**២.២.២.ករណីពិសេសដែលមិនអាចស៊ើបសួរជំនួស**

ចំពោះការចាត់តាំងឱ្យ ស៊ើបសួរមួយចំនួនមិនអាចធ្វើបានទេដូចជាករណីត្រូវធ្វើការឆែកឆេរដោយជំនួសក្នុងការិយាល័យ ឬក្រុមហ៊ុនមេធាវី ដែលជាទីកន្លែងលាក់នូវវត្ថុតាងណាមួយ ឬបទល្មើសមានបន្សល់ទុកស្នាកស្នាម។ ចៅក្រមស៊ើបសួរធ្វើការថ្លឹងថ្លែងអំពីអំពើដែលមានលក្ខខណៈធ្ងន់ធ្ងរដែលត្រូវតែធ្វើការស្រាវជ្រាវបទល្មើសដោយខ្លួនឯង ឬចំពោះលក្ខខណៈបច្ចេកទេសខ្លាំងក្នុងការការស្រាវជ្រាវត្រូតែធ្វើកិច្ចប្រតិបត្តិការណ៍នេះតែម្តងមិនអាចប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ឡើយ។[៦១]

ក្រោយពេលដែលមន្ត្រីនគរបាលយុត្តិធម៌ដែលត្រូវបាន ចាត់តាំងបានបំពេញគ្រប់នូវកិច្ចការរបស់ខ្លួនរួចរាល់ត្រូវតែធ្វើកំណត់ហេតុនូវអ្វីៗ ដែលច្បាប់តម្រូវ និងត្រូវបញ្ជូនមកឱ្យចៅក្រមស៊ើបសួរ ជាប្រញាប់ ដើម្បីស្វែងរកការពិតនៃសំណុំរឿងដែលបានកើតឡើង និងផ្តល់នូវភាពយុត្តធម៌ជូនចំពោះគូរភាគី។ ចំពោះកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលធ្វើឡើង ក្នុងក្របខណ្ឌនៃការស៊ើបសួរជំនួសមិនមែនជាកាតព្វកិច្ចដែលតម្រូវឱ្យចៅក្រមស៊ើបសួរត្រូវតែទទួលស្គាល់ជានិច្ចនោះទេ គឺចៅក្រមស៊ើបសួរ ត្រូវពិចារណានិងធ្វើការវិនិច្ឆ័យក្នុងការពិនិត្យនូវគ្រប់ភស្តុតាងនានា ដែលមាននៅក្នុងសំណុំរឿង ដើម្បីពិចារណា និង សម្រេចសេចក្តីទៅលើសំណុំរឿងក្តីដែលខ្លួនកំពុងតែកាន់ ក្នុងគោលបំណងបង្ហាញនូវការពិតដែលកើតមាននៅក្នុងហេតុការណ៍ដែលត្រូវបាន តំណាងអយ្យការប្តឹងចោទប្រកាន់មកខ្លួនក្នុងនាម ជាចៅក្រមស៊ើបសួរ និងភាពយុត្តិធម៌ដល់គ្រប់ភាគីដែលគ្មានកំហុស។

***-ជាបទពិសោធអនុវត្តជាក់ស្តែងនៅសាលាដំបូង៖***

នៅពេលដែលចៅក្រមស៊ើបសួរ យល់ឃើញថានៅក្នុងសំណុំរឿងក្តីដែល ខ្លួនកំពុងចាត់ការនោះមានភាពខ្វះចន្លោះប្រហោងត្រង់ចំណុចណាមួយនឹង ដើម្បីបង្គ្រាប់កិច្ចដែលបានធ្វើនោះច្រើនតែចាត់តាំងឱ្យស៊ើបសួរជំនួស ដូចជាការចាត់តាំងឱ្យស្រាវជ្រាវសាវតាជាតិរបស់ជនត្រូវចោទបញ្ជាទៅមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស្រាវជ្រាវនូវផ្នែកណាមួយ នៃបទល្មើសព្រហ្មទណ្ឌដែលកំពុងតែតាមដាន និងព្យាយាមបង្ហាញនូវអ្វីជាការពិតក្រោយពីការលាក់បាំង។ ជាពិសេសនោះពេលអនុវត្តការចាត់តាំងឱ្យស៊ើបសួរជំនួសច្រើនតែប្រគល់ភារកិច្ចឱ្យមន្ត្រីនគរបាលជាតិ ឬកងរាជអាវុធហត្ថដែលបានកសាង និងបញ្ជូនសំណុំរឿងមកតំណាងអយ្យការបានបើកការស៊ើបសួរ ដូច្នេះចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចតាំងឱ្យមន្ត្រីនគរបាលយុត្តិធម៌ឱ្យធ្វើការស្រាវជ្រាវ និងបំពេញសាវតាជាតិរបស់ជនត្រូវចោទការឆែកឆេរតាមករណីនីមួយៗ ដែលបានកសាងនិងបញ្ជូនសំណុំរឿងមកជាដើម.ល.។

---

[៦០] អនុលោមមាត្រា ១៧៩ កថាខណ្ឌទី៣ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[៦១] អនុលោម មាត្រា ៩១ កថាខណ្ឌទី ៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

# ជំពូកទី៣
# ការបញ្ចប់កិច្ចការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ

ការបញ្ចប់កិច្ចស្រាវជ្រាវបទល្មើស បើសិនជាចៅក្រមស៊ើបសួរយល់ឃើញថាគ្មានប្រយោជន៍អ្វី ដល់កិច្ចនីតិវិធីដែលតម្រូវឱ្យចៅក្រមស៊ើបសួរស្វែងរកនូវភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកទៀតទេ និងគ្មានលទ្ធផលអ្វីលើសពីកិច្ចដែលបានធ្វើកន្លងមកហើយ ចៅក្រមស៊ើបសួរអាចបិទស៊ើបសួរត្រឹមតែកិច្ចដែលខ្លួនបានធ្វើកន្លងមកនោះ។ ការបញ្ចប់កិច្ចស៊ើបសួរដែលមានលក្ខខណៈពិសេសជាងគេគឺការទទួលមរណៈភាពរបស់ជនត្រូវចោទ ការស៊ើបសួរបានកន្លងហួស **០១ឆ្នាំ** ដែលភាគីពាក់ព័ន្ធបានស្នើសុំ និងការយល់ឃើញរបស់ខ្លួនផ្ទាល់ដល់ពេលវេលាដែលត្រូវបញ្ចប់។[៥២]

ចំពោះការបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសអាចផ្ដល់នូវគុណសម្បត្តិ ច្រើនជាងបន្តក្នុងការស្រាវជ្រាវដែលគ្មានសង្ឃឹមថាអាចបង្ហាញអ្វីៗលើសពីភស្តុតាងដែលមានក្នុងសំណុំរឿង។ ការផ្ដល់នូវយុត្តិធម៌ដល់ជនដែលជាភាគីព្រហ្មទណ្ឌផងដែរ ដោយសារគោលការណ៍មួយបានលើកឡើងថាភាពយឺតយ៉ាវ នៃការចាត់ការរឿងក្ដីជាភាព "*ភាពអយុត្តិធម៌*" ដែលចៅក្រមស៊ើបសួរ គួរតែបិទការស្រាវជ្រាវរបស់ខ្លួនដើម្បីអាច បញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬលើកលែងការចោទ និងសម្រេចអំពីការប្រគល់វត្ថុតាងដែលបានចាប់យក (*ប្រសិនជាមាន*) ដល់ភាគីដែលមានសិទ្ធិលើវត្ថុតាង ករណីវត្ថុតាងមានលក្ខខណៈគ្រោះថ្នាក់ដល់សង្គម ឬមានភាពចាំបាច់សំរាប់ដាក់បន្ទុកជនត្រូវចោទមិនអាចប្រគល់វិញបានឡើយ។[៥៣]

## កថាខណ្ឌ១.នីតិវិធីដើម្បីបញ្ចប់កិច្ចស្រាវជ្រាវបទល្មើស

ដើម្បីអាចបញ្ចប់នូវកិច្ចស្រាវជ្រាវបទល្មើសដែលចៅក្រមស៊ើបសួរ បានបំពេញកន្លងមកក្នុងភាពជាតួអង្គនៅកណ្ដាលនៃភាគី ដើម្បីបង្ហាញនូវការពិតដែលបានលាក់បាំងពីក្រោយហេតុការណ៍ផ្សេងៗដែលបានកើតឡើងហើយដល់ពេលដែលការពិតត្រូវបានបង្ហាញចៅក្រមស៊ើបសួរ ត្រូវតែបង្ហាញការពិតដោយផ្អែកទៅភស្តុតាងដែលខ្លួនស្រាវជ្រាវនេះ។ ដើម្បីអាចបង្ហាញនូវការពិតបានចៅក្រមស៊ើបសួរត្រូវតែបញ្ចប់នូវកិច្ចរបស់ខ្លួនហើយនោះ និង ប្រមូលគ្រប់ភស្តុតាងដែលបានស្រាវជ្រាវនោះធ្វើកន្លងមកដើម្បីធ្វើជាមូលដ្ឋាន ក្នុងការពិចារណានិងសម្រេចសេចក្ដី។[៥៤] ចៅក្រមស៊ើបសួរមុននឹងសម្រេចបញ្ចប់កិច្ចស្រាវជ្រាវរបស់ខ្លួន ត្រូវតែជូនដំណឹងទៅគ្រប់ភាគីនៃបទល្មើសដែលមាននៅក្នុងសំណុំរឿងក្នុងគោលបំណងដើម្បីប្រាប់អំពីសិទ្ធិដែលអាចស្នើសុំឱ្យចៅក្រមស៊ើបសួរ បំពេញកិច្ចស្រាវជ្រាវបន្ថែម ឬយល់ស្របជាមួយអ្វីដែលចៅក្រមស៊ើបសួរ បានសម្រេចបញ្ចប់កិច្ចស្រាវជ្រាវដោយផ្អែកទៅលើភស្តុតាងដែលបានរកឃើញក្នុងការស្រាវជ្រាវ បទល្មើសព្រហ្មទណ្ឌកន្លងមក។

### ១.១.នីការបញ្ជូនពត៌មាន និងលិខិតជូនដំណឹងបញ្ចប់កិច្ចស្រាវជ្រាវ

ដោយអនុលោមក្រមនីតិវិធីព្រហ្មទណ្ឌបាន តម្រូវឱ្យចៅក្រមស៊ើបសួរត្រូវតែធ្វើការជូនដំណឹងធ្វើជាលាយលក្ខណ៍អក្សរ ទៅភាគីក្នុងកិច្ចស្រាវជ្រាវរបស់ខ្លួន ជាពិសេសតំណាងអយ្យការជនត្រូវចោទ

[៥២]អនុលោមមាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[៥៣] អនុលោមមាត្រា ១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[៥៤]អនុលោមមាត្រា ២៥៧ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្ម ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៣។

និងដើមបណ្តឹងរដ្ឋប្បវេណី ឬជនរងគ្រោះ។ ដោយមានដីកាបញ្ជូនពត៌មានទៅតំណាងអយ្យការដែលធ្វើការចោទប្រកាន់ លិខិតជូនដំណឹងអំពីការបិទស៊ើបសួរ (***ទាំងជនត្រូវចោទ ដើម្បីបណ្តឹង ឬជនរងគ្រោះ ឬជនរងគ្រោះ និងមេធាវីការពារសិទ្ធិ និងតំណាងដោយអាណត្តិ***)។[៩៥]

**១.១.១.ដីកាបញ្ជូនពត៌មានទៅអយ្យការ**

កាលណាដែលចៅក្រមស៊ើបសួរ សម្រេចចិត្តក្នុងការបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសដែល បើកការស្រាវជ្រាវដោយព្រះរាជអាជ្ញាដែលជាម្ចាស់បណ្តឹងអាជ្ញា មកខ្លួនជាចៅក្រមស៊ើបសួរត្រូវតែជូនដំណឹងអំពីកិច្ចដែលខ្លួនបម្រុង នឹងបញ្ចប់តាមរយៈដីកាបញ្ជូនពត៌មានទៅព្រះរាជអាជ្ញា។ ដើម្បីទទួលយោបល់ពីគេវិញថាតើការសម្រេចចិត្តរបស់ខ្លួននោះមានលក្ខខណ:គ្រប់គ្រាន់ហើយ ឬនៅសំរាប់បញ្ចប់កិច្ចស្រាវជ្រាវនោះ ឬព្រះរាជអាជ្ញាដែលធ្វើការចោទប្រកាន់នោះអាចយល់ឃើញថាសំណុំរឿងមិនទាន់ពេញលេញហើយមាន ការបញ្ចេញយោបល់មិនឯកភាព និងអាចស្នើសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស្រាវជ្រាវបន្ថែមទៅលើចំណុចណាមួយឡើងវិញ។ ករណីដែលព្រះរាជអាជ្ញាដែលបានចោទប្រកាន់ បានឯកភាពនឹងការសម្រេចរបស់ចៅក្រមស៊ើបសួរ នោះមានន័យថាចៅក្រមស៊ើបសួរ និង បន្តនីតិវិធីដើម្បីបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌរបស់ខ្លួនបានហើយ។[៩៦]

**១.១.២.លិខិតជូនដំណឹងទៅភាគី**

ភាគីក្នុងរឿងក្តីព្រហ្មទណ្ឌអាចជាដើមបណ្តឹងរដ្ឋប្បវេណី ឬជាជនរងគ្រោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណី និង ជនត្រូវចោទជាដើម។[៩៧] កាលណានីតិវិធីនៃការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌបានដល់ទីបញ្ចប់ចៅក្រមស៊ើបសួរត្រូវតែជូនដំណឹងទៅភាគីពាក់ព័ន្ធ ដើម្បីទទួលដំណឹងអំពីការបញ្ចប់ការស៊ើបសួរ របស់ខ្លួនក្នុងគោលបំណងឱ្យភាគីអាចស្នើសុំ ឬធ្វើកិច្ចអ្វីមួយដែលខ្លួនយល់ឃើញថាមានប្រយោជន៍មុនពេលចៅក្រមស៊ើបសួរ បញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យនិងធ្វើដីកាសន្និដ្ឋានស្ថាពរមកចៅក្រមស៊ើបសួរវិញ រួចបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសត្រឹមដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរដែលអាចជាដីកាលើកលែងការចោទប្រកាន់ ឬបញ្ជូនទៅជំនុំជម្រះ។[៩៨]

**១.១.៣.ពត៌មានបញ្ជូនត្រឡប់មកវិញ**

គ្រប់ពត៌មានដែលបានទទួល ត្រលប់មកវិញមានសារសំខាន់សំរាប់ជា ភស្តុតាងមួយដែលបញ្ជាក់អំពីភាពត្រឹមត្រូវក្នុងការអនុវត្តមុខងារ របស់ខ្លួនក្នុងឋានៈជាចៅក្រមស៊ើសួរ។ ម្យ៉ាងវិញទៀតធ្វើឱ្យ កិច្ចស្រាវជ្រាវរបស់ខ្លួនបានទទួលនូវជោគជ័យតាមរយៈភាពគ្មានការជំទាស់ ឬអាចឱ្យដឹងអំពីការស្នើសុំផ្សេងៗក្រោយពីបញ្ជូនពត៌មានទៅភាគីរួចរាល់។ ករណីដែលមានការជំទាស់ ឬការស្នើសុំចៅក្រមស៊ើបសួរត្រួតពិនិត្យនិងសម្រេចឡើងវិញ តែបើគ្មានទេចៅក្រមស៊ើបសួរត្រូវរងចាំរយៈពេលពីរថ្ងៃក្រោយពីការជូនដំណឹងអំពីការបញ្ចប់កិច្ចស្រាវជ្រាវ និង បញ្ជូនសំណុំរឿងឱ្យព្រះរាជអាជ្ញាពិនិត្យបន្ទាប់មកធ្វើ

---

[៩៥] យោងឧបសម្ព័ន្ធលេខ ៥១ និង ៥២ របស់សាលាដំបូងខេត្តកណ្តាល។

[៩៦] អនុលោមមាត្រា ២៤៦ ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[៩៧] អនុលោមមាត្រា ២៤៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[៩៨] អនុលោមមាត្រា ២៤៧ ថ្មី ច្បាប់ស្តីពីវិសោធនកម្ម ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៨។

ដីកាសន្និដ្ឋានស្ថាពរ មកខ្លួនវិញដើម្បីខ្លួនជាចៅក្រមស៊ើបសួរសម្រេចវិនិច្ឆ័យតាមដីកាដំណោះស្រាយ។

### ១.២.ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ

ការបញ្ជូនសំណុំរឿងឱ្យពិនិត្យធ្វើនៅពេលដែលដីកាបញ្ជូនពត៌មាន អំពីការបិទស៊ើបសួរបានកន្លងផុតពីរថ្ងៃមកចៅក្រមស៊ើបសួរត្រូវតែចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅ ព្រះរាជអាជ្ញាឱ្យពិនិត្យ និងតំណាង អយ្យការត្រូវតែធ្វើដីកាសន្និដ្ឋានស្ថាពរមួយត្រឡប់មកចៅក្រមស៊ើបសួរវិញ។ ដែលដីកានោះគឺជាការបញ្ចេញមតិយោបល់ របស់ព្រះរាជអាជ្ញាទៅលើសំណុំរឿងក្ដីដែល ចៅក្រមស៊ើបសួរបានចំណាត់ការគន្លងមក ។ ក្រោយពេលដែលបានសិក្សាសំណុំរឿង ដែលចៅក្រមស៊ើបសួរបានស្រាវជ្រាវ និងភស្តុតាង មានក្នុងដំណាក់កាលចៅក្រមស៊ើបសួរដែលអាចធ្វើដីកាសន្និដ្ឋានស្ថាពរនោះមកចៅក្រមស៊ើបសួរ ដើម្បី ជាមូលដ្ឋានឱ្យចៅក្រមស៊ើបសួរបានដឹងអំពីមូលដ្ឋាននៃការស្នើសុំ ឬសំណូមពររបស់តំណាងអយ្យការដែលអាចជាការស្នើសុំធ្វើការចោទប្រកាន់ កែប្រែបទចោទ ឬលើកលែងការចោទប្រកាន់។[99]

### ១.២.១.មន្ត្រីអនុវត្តបញ្ជូនសំណុំរឿង

ការអនុវត្តមន្ត្រីដែលបញ្ជូនសំណុំរឿងជាបន្ទុករបស់ ក្រឡាបញ្ជីនីមួយៗដែលនៅក្រោមអធិនភាពរបស់ចៅក្រមស៊ើបសួរ ដែលជាលេខាធិការរបស់ចៅក្រមស៊ើបសួរ ក្នុងការធានារ៉ាប់រងរក្សាទុកសំណុំរឿង ដោយមានភាពទទួលខុសត្រូវខ្ពស់ចំពោះការបាត់បង់។ នៅក្នុងកិច្ចស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ ដោយ ក្រឡាបញ្ជី ជាអ្នកបញ្ជូនសំណុំរឿងទៅក្រឡាបញ្ជីរបស់អយ្យការ ឬព្រះរាជអាជ្ញា ដើម្បីដំណើរការការងារដោយប្រុងប្រយ័ត្ន និង ធានានូវការទទួលយកមកវិញនៅពេលដែល ក្រឡាបញ្ជីអយ្យការបានបញ្ជូនត្រឡប់ មកវិញ និងត្រូវរាយការណ៍អំពីដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ ជូនចៅក្រមស៊ើបសួរ ដើម្បីឱ្យចៅក្រមស៊ើបសួរពិនិត្យ និង សម្រេចសេចក្ដីតាមដីកាដំណោះស្រាយរបស់ខ្លួន ឬអាចហៅម្យ៉ាងទៀតដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងបទចោទ។[100]

**ដូចជាករណី** ក្រឡាបញ្ជី **ក** បានបញ្ជូនសំណុំរឿង "***រំលោភលើទំនុកចិត្ត***" តាមដីកាសម្រេច បញ្ជូនសំណុំរឿងឱ្យពិនិត្យលេខ **០៣០៨** ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៨ ទៅក្រឡាបញ្ជីឈ្មោះ **ខ** ដែលមានព្រះរាជអាជ្ញារងឈ្មោះ **គ** និងក្រឡាបញ្ជី **ខ** បានចុះហត្ថលេខាទទួលលើសៀវភៅបញ្ជូនសំណុំរឿង (***សៀវភៅផ្ទាល់ខ្លួនរបស់ក្រឡាបញ្ជី***)។

### ១.២.២.រយៈពេលបញ្ជូនត្រឡប់វិញ

ជាគោលការណ៍ រយៈពេលឱ្យបញ្ជូនសំណុំរឿងត្រឡប់មកចៅក្រមស៊ើបសួរវិញ ដែលមានរយៈពេល **១៥ថ្ងៃ** ប្រសិនជាជនត្រូវចោទក្នុងឃុំ ឬក្នុងអំឡុងពេល **០១ ខែ** ប្រសិនជាជនត្រូវចោទនៅក្រៅឃុំ សម្រាប់ឱ្យតំណាងអយ្យការធ្វើសេចក្ដីសន្និដ្ឋានស្ថាពរ និង ត្រូវតែបញ្ជូនសំណុំរឿងត្រឡប់មកវិញ ឱ្យបានឆាប់រហ័សបំផុតតាមកាលដែលធ្វើបាន។ ការបញ្ជូនសំណុំរឿងដែលបានទទួល និង ត្រូវភ្ជាប់នូវដីកាសន្និដ្ឋានស្ថាពរមួយនៅក្នុងសំណុំរឿងនោះ ដោយមានភាពទទួលខុសត្រូវខ្ពស់ របស់ព្រះរាជអាជ្ញា និង ក្រឡាបញ្ជីធ្វើយ៉ាងណាកុំឱ្យមានបាត់បង់នូវឯកសារផ្សេងៗនៅក្នុងសំណុំរឿង និង ត្រូវតែបញ្ជូន

---

[99] អនុលោមមាត្រា ២៤៦ កថាខណ្ឌទី ៤ វាក្យខណ្ឌទី ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[100] អនុលោមមាត្រា ២៤៤ វិធានដោយឡែក នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

ត្រឡប់មកវិញឱ្យលឿនបំផុតតាមកាលដែលធ្វើបាន ក្រោយពីតំណាងអយ្យការ បានធ្វើដីកាសន្និដ្ឋានស្ថាពររួចរាល់*(ដីកាសន្និដ្ឋានស្ថាពររបស់ ព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង)*។[១០១]

*-ជាបទពិសោធអនុវត្តជាក់ស្តែងនៅសាលាដំបូង៖*

នៅពេលដែលចៅក្រមស៊ើបសួរពិនិត្យទៅសំណុំរឿង និងរយៈពេលព្រមទាំងកាលៈទេសៈតម្រូវហើយ យល់ឃើញថា គ្មានប្រយោជន៍ផ្លូវច្បាប់អ្វីសម្រាប់បន្តនូវកិច្ចស៊ើបសួរទៀតទេ គឺចៅក្រមស៊ើបសួរតែងតែបិទការស៊ើបសួរតែម្តង។ ជាពិសេសតាមបែបបទនៃសំណុំរឿងក្តី ប្រសិនសំណុំរឿងមិនសូវមានភាពស្មុគស្មាញទេ ហើយភស្តុតាងគ្រប់គ្រាន់រួចហើយគឺបិទស៊ើបសួរ និង ធ្វើលិខិតជូនដំណឹងក្នុងពេលតែមួយតែម្តង គឺមានលិខិតជូនដំណឹងទៅភាគី (*ក្រៅពីព្រះរាជអាជ្ញា*) ដីកាបញ្ជូនពត៌មាន និងដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យតែម្តង។ ប៉ុន្តែត្រូវចេញតាមដំណាក់កាលនៃលិខិតនីមួយៗ ត្រូវយកលេខនៃលិខិតទាំងនោះនៅក្នុងសៀវភៅ ពិសេសស៊ើបសួរនៅតាមបន្ទប់ចៅក្រមនីមួយៗ។ ដែលជាដំបូងត្រូវតែចេញលិខិតមុនគេគឺមានលិខិតជូន ដំណឹងអំពីការបិទស៊ើបសួរ រួមទាំងដីកាបញ្ជូនពត៌មាន និង ពីរថ្ងៃក្រោយមកដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ (*ក្រឡាបញ្ជីកាន់សំណុំរឿងទាំងមូលឱ្យទៅក្រឡាបញ្ជីអយ្យការ ឬព្រះរាជអាជ្ញាតែម្តង*) និងរងចាំខាងតំណាងអយ្យការដែលជាម្ចាស់បណ្តឹងអាជ្ញា ធ្វើការបញ្ជូនសំណុំរឿងមកវិញដោយមានភ្ជាប់ជាមួយដីកាសន្និដ្ឋានស្ថាពរក្នុងសំណុំរឿងតែម្តង។

### ១.៣.ដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ

ដីកាសន្និដ្ឋានស្ថាពរជាការបញ្ចេញមតិក្នុងការវិនិច្ឆ័យទៅអង្គហេតុ និងអង្គច្បាប់ផ្ទាល់ខ្លួនរបស់តំណាងអយ្យការនីមួយៗ ដែលបានធ្វើការចោទប្រកាន់ និងបើកការស៊ើបសួរមកកាន់ចៅក្រមស៊ើបសួរដើម្បីធ្វើការស្រាវជ្រាវបទល្មើសឱ្យមានលក្ខខណៈពេញលេញ។ ការយល់ឃើញថាយ៉ាងណាជាគំនិតរបស់តំណាងអយ្យការ គ្មានអានុភាពដាក់កាតព្វកិច្ច ឱ្យចៅក្រមស៊ើបសួរសម្រេចតាមឡើយ។[១០២] ជាករណីពិសេសបញ្ញត្តិច្បាប់បានតម្រូវឱ្យចៅក្រមស៊ើបសួរ ត្រូវតែទទួលដីកាសន្និដ្ឋានស្ថាពរ ជាមុនសិនទើបអាចបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសបាន។ បើគ្មានដីកាសន្និដ្ឋានស្ថាពរទេគឺចៅក្រមស៊ើបសួរមិនអាចបញ្ចប់កិច្ចស្រាវជ្រាវរបស់ខ្លួនបានឡើយតែ តំណាងអយ្យការគ្មាន អានុភាពបដិសោធមិនធ្វើដីកាសន្និដ្ឋានស្ថាពរមកចៅក្រមស៊ើបសួរនោះទេ មានន័យថាតំណាងអយ្យការត្រូវតែធ្វើ ដីកាសន្និដ្ឋានស្ថាពរមកចៅក្រមស៊ើបសួរ។ ដីកាសន្និដ្ឋានស្ថាពរជាផ្នែកមួយ ដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើជាមូលដ្ឋានក្នុងការពិចារណាតែប៉ុណ្ណោះ ចំពោះការវិនិច្ឆ័យទៅបទល្មើសដែលខ្លួនបានស្រាវជ្រាវ និង ការសម្រេចជាឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ។[១០៣] យើងអាចសន្និដ្ឋានបានថាតំណាងអយ្យការអាចធ្វើសន្និដ្ឋានស្ថាពររបស់ខ្លួនមានបីទម្រង់ជា៖ ទម្រង់ស្នើសុំលើកលែងបទចោទប្រកាន់ ជាទម្រង់កែប្រែបទចោទ ជាទម្រង់រក្សាការចោទប្រកាន់ដោយមានការស្នើសុំបញ្ជូនជនត្រូវចោទ ឬវត្ថុតាងទៅជំនុំជម្រះ។

---

[១០១] អនុលោមមាត្រា ២៤៦ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[១០២] អនុលោមមាត្រា ២៤៧ថ្មី កថាខណ្ឌទី ១ នៃច្បាប់ស្តីពីការវិសោធនកម្មមាត្រា ២៤៧ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៣។

[១០៣] យោងតាមសៀវភៅនីតិវិធីព្រហ្មទណ្ឌ របស់ រុន ពុណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត ឆ្នាំ២០១៥ និងឆ្នាំ២០១៦។

**១.៣.១.ម៉្តឹងសុំឱ្យលើកលែងការចោទប្រកាន់**

ដីកាសន្និដ្ឋានស្ថាពរលើកលែងការចោទប្រកាន់ ជាកាលៈទេសៈពិសេសដែលតំណាងអយ្យការបានបើកការស៊ើបសួរ តែក្រោយពេលដែលចៅក្រមស៊ើបសួរ រកមិនឃើញថាមានពិរុទ្ធភាពរបស់ជនត្រូវចោទ ឬគ្មានសារតាជាតិគ្រប់គ្រាន់និងជនត្រូវចោទបានទទួលមរណៈភាពដែលមូលហេតុបណ្តឹងអាជ្ញាត្រូវរលត់។ តំណាងអយ្យការមិនអាចធ្វើការប្តឹងសុំឱ្យចៅក្រមស៊ើបសួរ បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ដោយតែភាពស្របច្បាប់កំណត់ដែលមិនអាចចោទប្រកាន់បានឡើយ។ តែមានករណីខ្លះដែលតំណាង អយ្យការធ្វើដីកាសន្និដ្ឋានលើកលែងបទចោទ ទោះបីជាបទល្មើសក៏ដោយតែបទល្មើសនោះមានព្យាសនកម្ម តិចតួចក្រោយពីពេលដែល ចៅក្រមស៊ើបសួរបានធ្វើការស្រាវជ្រាវ និង មានភស្តុតាងគ្រប់គ្រាន់ដែលអាចបញ្ជាក់អំពីអំពើរបស់ជនត្រូវចោទបាន។[១០៤] **ដូចជាករណី** ដែលជនត្រូវចោទ **ក** បានព្រឹត្តបទល្មើស "***ឆបោក***" តំណាអយ្យការបានចោទប្រកាន់តាមបញ្ញត្តិមាត្រា **៣៧៧** និងមាត្រា **៣៧៨** និងបើកការស៊ើបសួរ មកចៅក្រមស៊ើបសួរ **ខ** តែក្រោយមកចៅក្រមស៊ើបសួរ រកឃើញថាដោយផ្អែកទៅលើភស្តុតាងជាកិច្ចសន្យាជារឿងក្តី រដ្ឋប្បវេណីទៅវិញ។

**១.៣.២.ម៉្តឹងសុំឲ្យកែប្រែបទចោទ**

ដីកាសន្និដ្ឋានស្ថាពរដែលស្នើសុំឱ្យចៅក្រមស៊ើបសួរកែប្រែបទចោទខុសពីអ្វីៗ ដែលខ្លួនបានចោទប្រកាន់ពីមុនដំបូងដោយសារតែខ្លួនបានពិនិត្យ និងសិក្សាសំណុំរឿងដែលចៅក្រមស៊ើបសួរបានធ្វើការស្រាវជ្រាវឃើញថា វាមិនមានធាតុផ្សំគ្រប់គ្រាន់សំរាប់ដាក់បន្ទុកទៅលើជនត្រូវចោទ ដែលបានធ្វើការចោទប្រកាន់ និង ការបើកការស៊ើបសួរមកចៅក្រមស៊ើបសួរ។ តែវាជាបែរជាបទល្មើសផ្សេងទៅវិញអង្គហេតុដំបូងជាអង្គហេតុដែលតំណាងអយ្យាការសន្មត់ថា ជាអំពើអ្វីមួយដែលមានបញ្ញត្តិនៅច្បាប់ព្រហ្មទណ្ឌតែក្រោយ មកយល់ឃើញថាវាមិនមែនជាបទល្មើស ដូចការចោទប្រកាន់ពីដំបូងដោយផ្អែកទៅលើភស្តុតាងដោយអាចជាសម្តីជនត្រូវចោទ សាក្សី ជនរងគ្រោះភស្តុតាងកោសលវិច្ឆយផ្សេងៗទៀតជាដើម។[១០៥] ដូចជាករណី **ក** ត្រូវបានតំណាងអយ្យការចោទប្រកាន់បទល្មើស "***ប្រទូស្តកេរ្ខាស***" តែក្រោយពីការស៊ើបសួរឃើញថា "***អំពើប៉ុនប៉ុងរំលោភសេពសន្ថវៈ***" តាមបញ្ញត្តិមាត្រា ២៧ និង២៣៩ នៃក្រមព្រហ្មទណ្ឌទៅវិញ។

**១.៣.៣.ម៉្តឹងសុំឱ្យបញ្ជូនទៅជំនុំជម្រះ**

ដីកាសន្និដ្ឋានស្ថាពរដែលបានប្តឹងសុំទៅចៅក្រមស៊ើបសួរ បញ្ជូនជនត្រូវចោទទៅជំនុំជម្រះជាការស្នើសុំឱ្យចៅក្រមស៊ើបសួរ សម្រេចចេញដីកាដំណោះស្រាយបញ្ជូនសំណុំរឿង ដែលខ្លួនបានចោទប្រកាន់នោះទៅចៅក្រមជំនុំជម្រះ ដោយគ្មានការកែប្រែការចោទប្រកាន់អ្វីឡើយ។ មានន័យថាតម្កល់ទុកដូចជាការបញ្ជូនដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឱ្យស៊ើបសួរ។ ម្យ៉ាងទៀតដោយសារតែការបើកការស៊ើបសួររបស់ ចៅក្រមស៊ើបសួរដែលមានភស្តុតាងនៅក្នុងសំណុំរឿងដែលខ្លួនបានពិនិត្យ និងការ

---

[១០៤] អនុលោមមាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[១០៥] អនុលោមមាត្រា ២៤៦ កថាខណ្ឌទី៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

សិក្សារបស់ខ្លួនឃើញថា មិនមានអ្វីប្រែប្រួលទេគឺប្តឹងសុំឱ្យបញ្ជូនជនត្រូវចោទទៅជំនុំជម្រះតែម្តង។[១០៦] ដូចជាករណីដែល ព្រះរាជអាជ្ញា **ក** បានធ្វើការចោទ **ខ** ពីបទ"***ហិង្សាដោយចេតនាមានស្ថានទោស*** " ទៅចៅក្រមស៊ើបសួរ តែក្រោយពីការ រកឃើញក្រោយការស្រាវជ្រាវ និង តាមដាន ឬបានប្រមូលភស្តុតាងព្រមទាំងជនត្រូវចោទបានឆ្លើយមានភាពស៊ីចង្វាក់គ្នា ពិតជាបានយកកំបិតកាំត្រូវចំខ្នងរបស់ជនរងគ្រោះប្រាកដមែនដែលអំពើនេះ ពិតជាបានបង្កើតបានជាបទល្មើសព្រហ្មទណ្ឌស្របតាមបទប្បញ្ញត្តិមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវតែបញ្ជូនខ្លួនជនត្រូវចោទ និងវត្ថុតាងនានាដែលមាននៅក្នុងសំណុំរឿងនោះត្រូវធ្វើការជំនុំជម្រះនៅដំណាក់កាលចៅក្រមជំនុំជម្រះតែម្តង។

### កថាខណ្ឌ២.ការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

ចៅក្រមស៊ើបសួរ ក្រោយពីបានទទួលសំណុំរឿងបញ្ជូនត្រឡប់មកវិញពីតំណាងអយ្យការត្រូវតែពិនិត្យទៅលើដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ។ ក្នុងគោលបំណងពិនិត្យទៅការស្នើសុំ និងការយល់ឃើញរបស់តំណាងអយ្យការដែលបានសម្រេចប្តឹងសុំ ក្នុងដីកាសន្និដ្ឋានស្ថាពរក្នុងទម្រង់អាចណាមួយជាមុនសិន ទើបចៅក្រមស៊ើបសួរត្រូវតែធ្វើការសម្រេចវិនិច្ឆ័យថាត្រូវតែចេញដីកាដំណោះស្រាយសម្រេចយ៉ាងណាចំពោះអំពើនោះ។ ទោះបីជាសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា សន្និដ្ឋានបែបណានោះគឺ មិនមែនជាកាតព្វកិច្ចចងជើងចៅក្រមស៊ើបសួរទេ។ ម្យ៉ាងទៀតបើសិនជាចៅក្រមស៊ើបសួរសម្រេចផ្ទុយពីការយល់ឃើញរបស់តំណាងអយ្យការនោះ ព្រះរាជអាជ្ញាអាចបន្តប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ដែលប្រឆាំងនឹងដីកាដំណោះស្រាយចំពោះជនត្រូវចោទ ឬដើមរដ្ឋប្បវេណីវេណីឬជនរងគ្រោះអាចប្តឹងដែលមានរយៈពេលនៃការប្តឹងមានកំណត់របស់ច្បាប់។[១០៧]

### ២.១.ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ

ដីកាដំណោះស្រាយជាការវិនិច្ឆ័យនូវរាល់ភស្តុតាង និងតម្រុយផ្សេងៗ ដែលមានការពាក់ព័ន្ធរួមទាំង ដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ ដែលជាមូលដ្ឋានក្នុងការពិចារណាសេចក្តីសម្រេចជាចុងក្រោយនៃការបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ។ ជាគោលការណ៍ដីកាដំណោះស្រាយត្រូវតែមានសំអាងហេតុ (***ការយល់ឃើញ***) ដោយចៅក្រមស៊ើបសួរ មុននឹងឈានទៅដល់ការវិនិច្ឆ័យក្នុងសេចក្តីសម្រេចក្នុងដីការបស់ខ្លួនដោយទៅលើពិនិត្យទៅលើកំណត់ហេតុផ្សេង តាំងពីដំណាក់កាលនគរបាល និងដំណាក់ កាលរបស់អយ្យការរួមទាំងយោងតាមកំណត់ហេតុធ្វើតេស្តិ៍កោសលវិនិច័យ និងភស្តុតាងផ្សេងៗដែលមាន នៅក្នុងសំណុំរឿងដែលខ្លួនបានធ្វើការស្រាវជ្រាវកន្លងមក។ ការសម្រេចសេចក្តីមួយប្រកបដោយភាពយុត្តិធម៌ និង ក្រោយពីការយល់ឃើញនានារួចមក រួមទាំងពិចារណាទៅលើអំពើដែលជនត្រូវចោទបានព្រឹត្ត ឬមិនបានប្រពឹត្តដោយផ្អែកទៅភស្តុតាងចៅក្រមស៊ើបសួរអាចវិនិច្ឆ័យសម្រេចដូចជាៈដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងបទចោទ។[១០៨]

---

[១០៦] យោងតាមសៀវភៅ នីតិវិធីព្រហ្មទណ្ឌរបស់ រ.ប.សរ.ត. ដីកាបញ្ជូនទៅជំនុំជម្រះ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦។

[១០៧] អនុលោមមាត្រា ២៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧។

[១០៨] អនុលោមមាត្រា ២៤៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ២០១៣។

**២.១.១.លើកលែងការចោទប្រកាន់**

ការលើកលែងចោទប្រកាន់ចំពោះជនត្រូវចោទ ចៅក្រមស៊ើបសួរអាចធ្វើក្នុងការបញ្ចប់កិច្ចស្រាវជ្រាវរបស់ខ្លួនដោយច្បាប់បានចែងយ៉ាងជាក់សម្រាប់ការចេញដីកាដំណោះស្រាយ។ មូលហេតុដែលមានបញ្ញត្តិក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌក្នុងការនាំឱ្យបណ្តឹងអាជ្ញារលត់។ កាលណាមានមូលហេតុនោះនាំឱ្យការរំលត់បណ្តឹងអាជ្ញា អាចតំណាងអយ្យការធ្វើដីកាសន្និដ្ឋានលើកលែងបទចោទ ចៅក្រមស៊ើបសួរត្រូវតែលើកលែងបទចោទ ដោយចេញដីកាសម្រេចលើកលែងការចោទប្រកាន់។ ករណីក្រៅពីនេះចៅក្រមស៊ើបសួរ ត្រូវតែមានភស្តុតាងជាក់លាក់ដោយមានសំអាងនៅក្នុងដីការបស់ខ្លួន និង សម្រេចលើកលែងបទចោទដោយអាចយកមូលហេតុទាំងនេះ អាចជាជនត្រូវចោទទទួលមរណភាព ជនត្រូវចោទមិនត្រូវបានស្គាល់អត្តសញ្ញាណ និង អង្គហេតុដែលតំណាងអយ្យការធ្វើការចោទប្រកាន់តែវាមិនមែនជាបទល្មើស ឬគ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ចំពោះជនត្រូវចោទដោយចៅក្រមស៊ើបសួរអាចចេញដីកាលើកលែងបទចោទចំពោះ ជនត្រូវចោទ ទោះបីជាគ្មានការឯកភាពពីតំណាងអយ្យការយ៉ាងណាក៏ដោយ។ ដូចជាករណី ជនត្រូវចោទ **ក** ត្រូវបានតំណាងអយ្យការ **ខ** ចោទប្រកាន់ពីបទ *"លួច"* តាមបញ្ញត្តិមាត្រា **៣៥៣** និងមាត្រា **៣៥៦** នៃក្រម នីតិវិធីព្រហ្មទណ្ឌ តែក្រោយមកចៅក្រមស៊ើបសួររកឃើញថាអំពើលួចរបស់ **ក** គឺបានលួចទ្រព្យសម្បត្តិ របស់បុព្វញាតិលោហិតខ្សែផ្ទាល់របស់ខ្លួនទៅវិញ។

**២.១.២.កែប្រែឬ រក្សាការចោទប្រកាន់របស់តំណាងអយ្យការ**

ការសម្រេចតាមដីកាដំណោះស្រាយបញ្ជូនសំណុំរឿងព្រហ្មទណ្ឌទៅជំនុំជម្រះ ចំពោះអង្គហេតុជាបទល្មើសព្រហ្មទណ្ឌទៅ ចៅក្រមជំនុំជម្រះគឺតាមការប្តឹងសុំ របស់តំណាងអយ្យការតាមរយៈដីកាសន្និដ្ឋានស្ថាពរមួយ។ នៅក្នុងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះចៅក្រមស៊ើបសួរ អាចមានការយល់ឃើញថាអំពើដែលបង្កើតបានជាបទល្មើសផ្សេងគ្នា ដោយផ្អែកទៅលើភស្តុតាង ឬការបកស្រាយអង្គច្បាប់ និងរួមទាំងអង្គហេតុផ្សេងពីតំណាងអយ្យការ។ ក្នុងករណីចៅក្រមស៊ើបសួរអាចសម្រេចបញ្ជូនសំណុំរឿងក្តីទៅជំនុំជម្រះដោយយល់ឃើញថា ដូចនឹងការយល់ឃើញរបស់តំណាងអយ្យការ ឬក៏អាចមានការយល់ឃើញដោយខ្វែងគំនិតគ្នាទៅលើបទល្មើសដែលកំណត់ ច្បាប់ព្រហ្មទណ្ឌក្នុងអង្គហេតុជាបទល្មើសដូចគ្នា។

ទោះបីជាមានការយល់ឃើញខុសគ្នាយ៉ាងណាទៅ អំពើដែលជាបទល្មើសដែលខុសពីការចោទប្រកាន់នឹងប្តឹងសុំតាមដីកាសន្និដ្ឋានស្ថាពរ ក៏គ្មានកាតព្វកិច្ចចងជើងចៅក្រមស៊ើបសួរនោះឡើយ។ មាន **ដូចជាករណី៖** ជនត្រូវចោទ **ក** ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទល្មើស *"ឆបោក"* តាមបញ្ញត្តិមាត្រា **៣៧៧** និងមាត្រា **៣៣៧៨** តែក្រោយមកចៅក្រមស៊ើបសួរផ្អែកទៅលើភស្តុតាង និង អង្គហេតុឃើញថា មិនមែនជាបទល្មើសទេតែជាបទល្មើស*"រំលោភលើទំនុកចិត្ត"* តាមបញ្ញត្តិមាត្រា **៣៩១** និងមាត្រា **៣៩២** នៃក្រមព្រហ្មទណ្ឌ។

**២.១.៣.សម្រេចអំពីសិទ្ធិជនត្រូវចោទក្នុងឃុំ និងវត្ថុតាង**

ជាគោលការណ៍ការឃុំខ្លួនបណ្តោះអាសន្នត្រូវបានបញ្ចប់នៅពេលដែល ដីកាដំណោះស្រាយបានចេញ ក្រោយពីការវិនិច្ឆ័យទៅលើវត្ថុតាង និងរបាយការណ៍ ឬដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការ ដែលបានសម្រេច និងបញ្ចេញយោបល់តាមបែបណានោះ គឺត្រូវតែសម្រេចដោយភក្តីភាព

របស់ចៅក្រមស៊ើបសួរ បានសម្រេចបញ្ជូនសំណុំរឿងព្រហ្មទណ្ឌទៅជំនុំជម្រះ។[109] តែចៅក្រមស៊ើបសួរត្រូវតែសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន(***ប្រសិនជាមាន***) និងសម្រេចអំពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ រហូតដល់ជនត្រូវចោទ ត្រូវបានបង្ហាញខ្លួននៅចំពោះមុខចៅក្រមជំនុំជម្រះ។ ក្រោយពីរយៈ **០៤ ខែ** កន្លងផុតត្រូវតែបានដោះលែងឱ្យជនត្រូវចោទមានសេរីភាពវិញ លើកលែងតែមានការសម្រេចផ្សេងពីនេះ។ ការសម្រេចអំពីការឃុំខ្លួន ឬប្រគល់វត្ថុត្រូវធ្វើឡើងនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួនទាំងអស់តែម្តង។[110]

**ដូចជាករណី** នៅក្នុងសេចក្តីវិនិច្ឆ័យសម្រេច **ចំនុចទី១** សម្រេចបញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ **០០២** អ.ក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ និងជនត្រូវចោទឈ្មោះ **ក** ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ ជាប់ចោទពីបទ "***ឃាតកម្មគិតទុកជាមុន***"តាមបញ្ញត្តិមាត្រា **២០០** នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ ឈើខ្មៅ ឃុំឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល ទៅជនុំជម្រះតាមនីតិវិធីច្បាប់។ **ចំនុចទី២** សម្រេចបង្គាប់ឱ្យប្រគល់ ម៉ូតូម៉ាក ហុងដាឌ្រីម ពណ៌ **ស** ឆ្នាំ២០១៨ ទៅឱ្យម្ចាស់កម្មសិទ្ធិឈ្មោះ **ខ** វិញ និងចំនុច **ទី៣** រក្សាទុកជនត្រូវ ចោទដែលមាននៅក្នុងការឃុំខ្លួនលើជាបណ្តោះអាសន្នរហូតមានសម្រេចផ្ទុយពីនេះ។

### ២.២.របៀបនៃការបញ្ជូនសំណុំរឿងរបស់ចៅក្រមស៊ើបសួរ

ក្រោយពេលដែលចៅក្រមស៊ើបសួរ បានជូនដំណឹងទៅគ្រប់ភាគីដែលមាននៅក្នុងសំណុំរឿងរួចរាល់ហើយអំពីការបិទស៊ើបសួរ និង បានចេញដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះ។ ចៅក្រមស៊ើបសួរត្រូវតែជូនដំណឹង ដូចនឹងការជូនដំណឹងអំពីការបិទស៊ើបសួរ ដោយត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យគ្រប់ភាគីបានដឹងអំពីការបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬក៏លើកលែងបទចោទចំពោះជនត្រូវចោទ។ ដែលគ្រប់ភាគីមានសិទ្ធិប្តឹងនឹងដីកាដំណោះស្រាយ របស់ខ្លួនដែលបានចេញតាមរយៈពេលដែលច្បាប់បានកំណត់សម្រាប់ធ្វើបណ្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍។[111]

#### ២.២.១.ការជូនដំណឹងទៅគ្រប់ភាគីពាក់ព័ន្ធ

គ្រប់លិខិតត្រូវតែជូនដំណឹង ជាលាយលក្ខណ៍អក្សរដែលធ្វើឡើងតាមរយៈអាជ្ញាសាលាតាមប្រៃសណីយ៍ និងក្រឡាបញ្ជី ធ្វើយ៉ាងណាឱ្យបានដល់ដៃភាគីព្រហ្មទណ្ឌកាន់តែល្អ ដើម្បីឱ្យពួកគាត់ត្រៀមខ្លួនបន្តនីតិវិធី។ ចំណែកឯជនត្រូវចោទ ដែលមាននៅក្នុងពន្ធនាគារត្រូវតែបានទទួលដំណឹងតាមរយៈមន្ត្រីទទួលបន្ទុក បញ្ជូនដីកាដែលមានសមត្ថកិច្ច ចំពោះជនត្រូវចោទដែលមិនជាប់ឃុំខ្លួនបណ្តោះអាសន្ន ឬគេចខ្លួន គឺជូនដំណឹងទៅលំនៅឋានចុងក្រោយគេតាមរយៈរដ្ឋបាល។[112] ដូចជាករណីជនត្រូវចោទ **ក** និង **ខ** ជាប់ពន្ធនាគារជាបណ្តោះអាសន្ននៅពន្ធនាគារខេត្តកណ្តាលដែលត្រូវបាន ចៅក្រមស៊ើបសួរសម្រេចបញ្ជូនសំណុំទៅជំនុំជម្រះ និងបានចេញលិខិតជូនដំណឹងអំពីដីកាដំណោះស្រាយនេះទៅមន្ត្រីទទួលបន្ទុកបញ្ជូនយកទៅប្រគល់ ឬអានឱ្យស្តាប់ជាការគ្រប់គ្រាន់។

---

[109] អនុលោមមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។

[110] អនុលោមមាត្រា ២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៣។

[111] អនុលោមមាត្រា ៣៦៨ថ្មី ,មាត្រា៣៧២ថ្មី,មាត្រា ៣៨២ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៣។

[112] យោងតាម សៀវភៅនីតិវិធីព្រហ្មទណ្ឌ របស់ រ.ប.វ.ត.,កិច្ចជាបឋមនៃការបិទស៊ើបសួរ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦។

ជាគោលការណ៍ច្បាប់ក្រោយពីដីកាដំណោះស្រាយបានចេញរួច ហើយនឹងបានជូនដំណឹងទៅគ្រប់ភាគីព្រហ្មទណ្ឌ ដើម្បីការពារសិទ្ធិ និង ផលប្រយោជន៍ស្របច្បាប់ក្នុងការប្ដឹងសភាស៊ើបសួរនៃសាលាឧទ្ធរណ៍។ កាលណាមានជនណាមួយ មានបំណងធ្វើបណ្ដឹងប្រឆាំងនឹងដីកាដំណោះស្រាយជាការវិនិច្ឆ័យសេចក្ដីសម្រេច ចៅក្រមស៊ើបសួរ និងបានបំពាននូវសិទ្ធិរបស់ខ្លួនអាចប្ដឹងមកចៅក្រមស៊ើបសួរដែលបានចេញ ដីកាដំណោះស្រាយនោះតែម្ដង។[១១៣] ចំពោះជនដែលមានបំណងប្ដឹងនឹងដីកាដំណោះស្រាយរបស់ ចៅក្រមស៊ើបសួរអាចដើមបណ្ដឹង ឬជនរងគ្រោះចំពោះដីកាដំណោះស្រាយលើកលែងបទចោទ និងចំពោះ ជនត្រូវចោទអាចដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះជាអាទ៍។

**២.២.២.បញ្ជូនសំណុំរឿងទៅរដ្ឋបាលជម្រះ**

ដោយយោងទៅតាមកាលទេសៈថ្មី និង ការកំណែទម្រង់ទៅលើវិស័យយុត្តិធម៌ និងតុលាការបានរៀបចំឱ្យមានមន្ត្រីរដ្ឋបាល នៃលេខាធិការដ្ឋានតុលាការទទួលនូវសំណុំរឿងស៊ើបសួរដែល ចៅក្រមស៊ើបសួរ បានសម្រេចបញ្ចប់កិច្ចស្រាវជ្រាវបទល្មើស និងបានបញ្ជូនមកធ្វើការជំនុំជម្រះ។ ដោយចៅក្រមស៊ើបសួរ ត្រូវតែបញ្ជូនសំណុំរឿងជំនុំជម្រះដោយមានភ្ជាប់ជាមួយនឹងដីកាដំណោះស្រាយដើម្បីដាក់ជូនទៅរដ្ឋបាលជំនុំជម្រះ ដើម្បីឱ្យមន្ត្រីរដ្ឋបាលធ្វើការបែងចែកសំណុំរឿងក្ដីដែលត្រូវជំនុំជម្រះនេះតាមលេខរៀងនៃស្ទីត និងដាក់ឱ្យប្រធានសាលាដំបូងចេញដីកាសម្រេចចាត់តាំងចៅក្រមណាមួយឬក្រុមប្រឹក្សាជំនុំជម្រះណាមួយ ដើម្បីចាត់ការសំណុំរឿងក្ដីក្នុងនីតិវិធីជំនុំជម្រះ។

*-ជាបទពិសោធអនុវត្តជាក់ស្ដែងនៅសាលាដំបូងផ្ទាល់ ៖*

ក្រោយពេលដែលមាន ដីកាសន្និដ្ឋានស្ថាពររបស់តំណាងអយ្យការរួចមកចៅក្រមស៊ើបសួរ តែងតែចេញដីកាដំណោះស្រាយស្របជាមួយនឹងតំណាងអយ្យការ ឬមានការខុសគ្នាដោយត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគ្រប់ភាគី។ លើកលែងតែតំណាងអយ្យការគឺទទួលដំណឹងដោយមានកំណត់នៅខាងក្រោមដីកាដំណោះស្រាយ ដាក់បានទទួលដំណឹងដោយ ព្រះរាជអាជ្ញាតែម្ដង។ ក្រោយពីចៅក្រមស៊ើបសួរបានចុះហត្ថលេខា និងយកលេខលិខិតរួចគឺក្រឡាបញ្ជីរបស់ចៅក្រមស៊ើបសួរកាន់ដីកាដំណោះស្រាយ យកទៅឱ្យតំណាងអយ្យការចុះហត្ថលេខា និងបោះត្រាតែម្ដង។ ដីកាដំណោះស្រាយ ច្រើនតែធ្វើឡើងជា ០៥ ច្បាប់ ដោយមានការចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និង មានការចុះហត្ថលេខារបស់ តំណាងអយ្យការបានទទួលដំណឹងអំពីដីកាដំណោះស្រាយ។ គ្រប់ដីកាដំណោះស្រាយត្រូវតែយកលេខ នៃក្បាលលិខិតនៅរដ្ឋបាលស៊ើបសួរ និងដកទុកទីនោះមួយច្បាប់បន្ទាប់មកត្រូវយកឱ្យតំណាងអយ្យការចុះហត្ថលេខា និង យកទៅរដ្ឋបាលរបស់អយ្យការបោះត្រា រួមទាំងដកទុកចំនួន **០២ ច្បាប់** និង នៅសល់ត្រឡប់មកវិញចំនួន **០២** ដកទុកក្នុងបន្ទប់ចៅក្រមស៊ើបសួរ ០១ច្បាប់និងនៅសល់ ០១ ច្បាប់ដាក់ទុកក្នុងសំណុំរឿង និងធ្វើការបញ្ជូនសំណុំរឿងឱ្យទៅរដ្ឋបាលជំនុំជម្រះតែម្ដងដោយមានសៀវភៅកំណត់ត្រាថាបានបញ្ជូន សំណុំចេញដៃរបស់ចៅក្រមស៊ើបសួររួចរាល់។

៚៙៚

[១១៣] យោងតាមសៀវភៅនីតិវិធីព្រហ្មទណ្ឌ របស់ រ.ប.វ.ត.,អត្ថន័យនៃដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦។

## សេចក្ដីសន្និដ្ឋាន

ជាសរុបមក ការស្រាវជ្រាវនេះបានផ្ដោតសំខាន់តែទៅលើកិច្ចដែលចៅក្រមស៊ើបសួរប្រឹងប្រែងក្នុងការអនុវត្តវិធានទាំងឡាយដែលបានផ្ដល់សិទ្ធិ និងអំណាចក្នុងការស្រាវជ្រាវ ឬបំបែករឿងក្ដីឱ្យឃើញនូវការពិតផ្ដល់នូវយុត្តិធម៌ជូនគ្រប់ភាគីក្នុងសំណុំរឿងក្ដី។ មានន័យថាចៅក្រមស៊ើបសួរប្រៀបដូចជាអាជ្ញាកណ្ដាលសម្រាប់ដោះស្រាយសំណុំរឿងក្ដីព្រហ្មទណ្ឌ និងដែលជាតួអង្គឯករាជ្យមិនអគតិទៅលើភាពប្រក្រតីនៃការពិត។ ដោយឈរលើមូលដ្ឋានច្បាប់និងសម្បជញ្ញៈក្នុងការវិនិច្ឆ័យនូវយុត្តិធម៌ និងធ្វើឱ្យសង្គមទទួលបាននូវសន្តិសុខ។ ចៅក្រមស៊ើបសួរត្រូវតែព្យាយាមឱ្យសំណុំរឿងក្ដីដែលខ្លួនមានចំណាត់ការដោយស្វែងរកនូវភស្តុតាងគ្រប់យ៉ាងជារួមភស្តុតាងដោះបន្ទុក និងភស្តុតាងដាក់បន្ទុក។

ភាពមិនយុត្តិធម៌ និង ការធ្វេសប្រហែសក្នុងការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ ដោយមិនយកចិត្តទុកដាក់ និង ធ្វើតាមតែឯកសារមួយចំនួនកសាងដោយមន្ត្រីនគរបាលយុត្តិធម៌ដោយផ្អែកទាំងស្រុងតាមទំលាប់ដដែលៗ ក្នុងការស៊ើបសួររឿងក្ដី។ ម្យ៉ាងវិញទៀតនោះ ចៅក្រមស៊ើបសួរតែងតែប្រើប្រាស់ក្រឡាបញ្ជីឱ្យធ្វើកិច្ចការជំនួសខ្លួនរួចទើបខ្លួនចុះហត្ថលេខាតាមក្រោយ (***ភាពទំនេរនៃការងារស្លាប់នូវភាពសោកសៅរបស់សង្គម***)។ នៅគ្រប់រឿងក្ដីទាំងអស់ ចៅក្រមស៊ើបសួរត្រូវតែមានវត្តមាន និងស្រាវជ្រាវដោយខ្លួនឯងផ្ទាល់ ដោយអមដោយក្រឡាបញ្ជីក្នុងការធ្វើកំណត់ហេតុ និងកិច្ចព្រៀងឯកសារផ្សេងៗសម្រាប់បន្តនីតិវិធី។ ដោយការទាមទារបែបនេះ គឺបង្ហាញនូវឆន្ទៈរបស់ចៅក្រមស៊ើបសួរ ខិតខំនឹងស្វែងយល់នូវទុក្ខលំបាក (***ទាំងជនត្រូវចោទ និងជនរងគ្រោះ***)ជាភាគីរឿងក្ដីព្រហ្មទណ្ឌ។ ជាករណីពិសេសដែលចៅក្រមស៊ើបសួរ តែតែងសម្រេចចំពោះសិទ្ធិជនត្រូវចោទដែលបានមកបង្ហាញខ្លួន នៅចំពោះមុខខ្លួនដោយតែងតែធ្វើតាមការដីកាសន្និដ្ឋាន ស្នើសុំឱ្យឃុំខ្លួនជាបណ្ដោះអាសន្នរបស់តំណាងអយ្យការ ដែលភ្ជាប់ជាមួយនឹងដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឱ្យស៊ើបសួរមក ចៅក្រមស៊ើបសួរ។ ដែលជាការសម្រេចនោះបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិសេរីភាពរបស់ជនត្រូវចោទ។

ចៅក្រមស៊ើបសួរគួរសិក្សា និងប្រើប្រាស់យន្តការនានា ដែលច្បាប់បានអនុញ្ញាតជៀសពីការឃុំខ្លួនជាបណ្ដោះអាសន្នទៅលើ ជនត្រូវចោទដែលបានប្រព្រឹត្តល្មើស និងធ្វើឱ្យមានការកើនឡើងនៃឃុំខ្លួនជនត្រូវចោទ។ ក្នុងដំណើររឿងក្ដីព្រហ្មទណ្ឌជាគោលការណ៍ចៅក្រមស៊ើបសួរ គ្មានកាតព្វកិច្ចក្នុងការស្រាវជ្រាវបទល្មើសណាមួយដែលគ្មាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឱ្យស៊ើបសួរ ពីតំណាងអយ្យការ បានឡើយលែកលែងតែករណីអង្គហេតុដែលជាស្ថានទម្ងន់ទោសនៃកម្មវត្ថុបញ្ជូនសំណុំរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ។នៅពេលកំពុងតែបំពេញកិច្ចស្រាវជ្រាវបទល្មើស ចៅក្រមស៊ើបសួរគឺអាចប្រើប្រាស់អំណាចទាំងអស់ដែលមានបញ្ញត្តិនៅក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌនេះ សម្រាប់ការបំពេញភារកិច្ចរបស់ខ្លួនធ្វើយ៉ាងណាឱ្យសមស្របនឹងគោលបំណងបង្ហាញនូវការពិតក្នុងសំណុំរឿងក្ដី។

ក្រោយពីការស្រាវជ្រាវរួចមកប្រសិនជាចៅក្រមស៊ើបសួរយល់ឃើញថា គ្មានប្រយោជន៍អ្វីអាចសម្រេចបញ្ចប់កិច្ចស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ និងធ្វើការសម្រេចវិនិច្ឆ័យដោយមានដីកាដំណោះស្រាយតែម្ដង។

៙៚🕮៙៚

## អនុសាសន៍

**យោង:**-សំណុំរឿងព្រហ្មទណ្ឌលេខ...................ចុះថ្ងៃទី.....ខែ.......ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល។

-លិខិតបញ្ជាក់របស់លោកមេឃុំ................ចុះថ្ងៃទី.......ខែ.............ឆ្នាំ២០១៧។

តបតាមកម្មវត្ថុនិងយោងខាងលើនាងខ្ញុំសូមជម្រាបជូន **លោកចៅក្រម** មេត្តាជ្រាបថាកាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៧ ប្រហែលជាវេលាម៉ោង ១១ និង ៣០នាទីនេះ

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

...........................................................................................................។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម លោក**ចៅក្រម** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះដល់រូបនាងខ្ញុំ។

សូមលោក**ចៅក្រម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ធ្វើនៅ..................ថ្ងៃទី.......ខែ............ឆ្នាំ២០១៧

**ស្នាមម្រាមដៃ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**
សំណុំរឿងព្រហ្មទណ្ឌលេខៈ១០៣៤
ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧
លេខៈ......................

**<u>ដីកាបញ្ជូនឲ្យឆ្លើយ</u>**

**យើង** ...................... ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល

បញ្ជាឲ្យបញ្ជូនសំណុំរឿងស៊ើបសួរទាក់ទងនឹងឈ្មោះ .................... ភេទប្រុស អាយុ ៥៥ឆ្នាំ ជាតិខ្មែរ ត្រូវចោទពីបទ៖ "**បើកកន្លែងលេងល្បែងស៊ីសងខុសច្បាប់**"និងឈ្មោះ ................... ភេទប្រុស អាយុ៥១ ឆ្នាំ ត្រូវចោទពីបទ៖ "**លេងល្បែងស៊ីសងដោយខុសច្បាប់**" ដែលអំពីទាំងពីរបានប្រព្រឹត្តនៅភូមិព្រែកត្រែង ឃុំសំរោងធំ ខេត្តស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងនិងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៥** និង**៤** នៃច្បាប់ស្ដីពីការបង្ក្រាបល្បែងស៊ីសង។

ទៅព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្ដីសន្និដ្ឋាន ឬផ្ដល់យោបល់លើ **ពាក្យស្នើសុំម៉ូតូ** ចុះថ្ងៃទី១៧ ខែសីហាឆ្នាំ២០១៧ របស់ឈ្មោះ ............................. ។

កណ្ដាល,ថ្ងៃទី.....ខែ.........ឆ្នាំ២០១៧

**ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

**យោបល់របស់តំណាងអយ្យការ**
យើង............................ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល។
បានឃើញដីកាបញ្ជូនពត៌មានខាងលើ
បានឃើញសំណុំរឿងស៊ើបសួរលើឈ្មោះ........................................................
ក្រោយពីបានពិនិត្យសំណុំរឿងស៊ើបសួរចប់ ស្នើសុំ៖........................................
................................................................................................

កណ្ដាល,ថ្ងៃទី......ខែ.........ឆ្នាំ២០១...
**តំណាងអយ្យការ**

សាលាដំបូងខេត្តកណ្តាល

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ដីកាសម្រេចប្រគល់វត្ថុចាប់យក

លេខៈ....................

**យើង .............................. ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល**

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៨៣១ អក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ។

-បានឃើញ ដីកាបញ្ជូនរឿងអោយស៊ើបសួរលេខៈ៨៣១ ដក.សស ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញ កំណត់ចាប់យកវត្ថុតាងចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលស្រុកស្អាង និងកំណត់ហេតុទទួលវត្ថុតាងរបស់អយ្យការអមសាលាដំបូងខេត្តកណ្តាល ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ។

-បានឃើញ ពាក្យស្នើសុំម៉ូតូរបស់ឈ្មោះ ..................... ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ។

-បានឃើញ ប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ និងលិខិតបញ្ជាក់របស់លោកមេឃុំស្អាងភ្នំលេខ ១៦៧៤/១៦ សក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ ។

## យល់ឃើញថា

**១**-ពាក្យស្នើសុំរបស់ឈ្មោះ .......... ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ដែលអាចអោយតុលាការយកមកពិនិត្យ និងសម្រេច បានហើយដោយស្របតាមបញ្ញត្តិមាត្រា ១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**២**-តាមកំណត់ហេតុដកហូតសម្ភារះរបស់អធិការដ្ឋាននគរបាលស្រុកអធិការស្រុកស្អាង ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៦សមត្ថកិច្ចបានធ្វើការចាប់យកម៉ូតូចំនួន០១គ្រឿងម៉ាកហុងដាសេ១២៥ពណ៌ខ្មៅ ស្លាក់លេខកណ្តាល១B៥២៧៩។

**៣**-តាមពាក្យស្នើសុំរបស់ឈ្មោះ ............ បានបញ្ជាក់ថាៈ ម៉ូតូមួយគ្រឿងម៉ាក ហុងដាសេ ១២៥ ពណ៌ខ្មៅ ស្លាក់លេខ កណ្តាល ២B ៥២៧៩ ជារបស់ឈ្មោះ រស់ សារ៉ាត់ ពិតប្រាកដមែន ហើយត្រូវបានអធិការដ្ឋាននគរបាលស្រុកស្អាងធ្វើការដកហូត នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៦ និងត្រូវបានរក្សាទុកនៅសាលាដំបូងខេត្តកណ្តាល នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ពាក់ព័ន្ធករណី **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៦ នៅពេលនេះ ខ្លួនបានស្នើសុំសម្ភារះខាងលើមកវិញ ដោយសារមុខរបរចិញ្ចឹមជីវិតគ្រួសារខ្លួន ពឹងផ្អែកលើម៉ូតូនេះទាំងស្រុងក្នុងការផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ទើបខ្លួនដាក់ពាក្យស្នើសុំមកលោកចៅក្រមពិនិត្យនិងសម្រេចដោយក្តីអនុគ្រោះ។

**៤**-តាមការពិនិត្យកស្តុតាង មានកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៦ របស់អធិការដ្ឋាននគរបាលស្រុកស្អាង ប័ណ្ណសម្គាល់យានយន្ត ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ និងតាមពាក្យសុំរបស់ឈ្មោះ ........... ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ បានបញ្ជាក់ឲ្យឃើញថាៈម៉ូតូមួយគ្រឿង ម៉ាក ហុងដាសេ ១២៥ ពណ៌ខ្មៅ ស្លាក់លេខ កណ្តាល ២B ៥២៧៩ ជារបស់ឈ្មោះ ................ ពិតប្រាកដមែន ។

**៥**-តាមការពិនិត្យកស្តុតាងខាងលើ គប្បីប្រគល់ រថយន្ត ដែលបានចាប់យកខាងលើនេះ ទៅឲ្យម្ចាស់ដើមវិញ អោយស្របតាមបញ្ញត្តិមាត្រា ១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

-ប្រគល់វត្ថុដែលចាប់យកមាន ម៉ូតូមួយគ្រឿង ម៉ាក ហុងដាសេ ១២៥ ពណ៌ខ្មៅ ស្លាក់លេខ កណ្តាល ២B ៥២៧៩ ទៅឲ្យឈ្មោះ ................ ដែលជាម្ចាស់ដើមវិញ ។

កណ្តាល,ថ្ងៃទី........ខែវិច្ឆិកា ឆ្នាំ២០១..

**ចៅក្រមស៊ើបសួរ**

**បានទទួលដំណឹង**

កណ្តាល,ថ្ងៃទី........ខែ.......... ឆ្នាំ២០១៦

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**************

**សាលាដំបូងខេត្តកណ្ដាល**

លេខ ៖ 1495 ដកស

ស្នងការដ្ឋាន នគរបាលខេត្តកណ្ដាល
ចូល ថ្ងៃទី 19 ខែ 12 ឆ្នាំ 17
ម៉ោង 3
លេខ 505

## ដីកាសម្រេច

**************

យើង [illegible] ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៖១៩២៣ អក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៖ ១២០៤ ដកសស ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

បានឃើញ ដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន លេខ ៣១០០ ដកសឃខ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

បានឃើញ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ៣១០១ ដកបឃខ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល។

បានឃើញ របាយការណ៍សរុបការស៊ើបអង្កេតលេខ ១៩៧/១៧ រ.ប.ក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ របស់នាយការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល។

បានឃើញ លិខិតលេខ ៤០៣/១៧ សណ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៧ របស់ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាល។

### យល់ឃើញថា

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៩២៣អក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៧ ដែលមានជនត្រូវចោទឈ្មោះ [illegible] ហៅ ម៉ាប់ ភេទប្រុស កើតឆ្នាំ១៩៧២ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ បើកកន្លែងលេងល្បែងស៊ីសងខុសច្បាប់ ប្រព្រឹត្តនៅឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ០៩ នៃច្បាប់ស្ដីពីការបង្ក្រាបល្បែងស៊ីសង។

-នៅក្នុងប្រតិបត្តិការចុះបង្ក្រាបទីតាំងលេងល្បែងស៊ីសងខុសច្បាប់ (ជល់មាន់) នោះ សមត្ថកិច្ចបានដកហូតនូវវត្ថុតាងមួយចំនួន ដែលក្នុងនោះក៏រួមមានមាន់ជល់ចំនួន ៩២ក្បាល ផងដែរ និងរក្សាទុកនៅស្នងការដ្ឋាននគរបាលខេត្តកណ្តាល។

-ការថែរក្សានូវមាន់ជល់ចំនួន ៩២ក្បាល មានការលំបាក និងចំណាយសោហ៊ុយផ្សេងៗ និងដើម្បីបង្ការកុំឱ្យមានបទល្មើសកើតមានជាថ្មី និងដើម្បីពន្លឿននូវនីតិវិធីនៃការស៊ើបសួរឱ្យបានឆាប់រហ័ស គប្បីចៅក្រមស៊ើបសួរសម្រេចកម្ទេចចោលនូវមាន់ចំនួន៩២ក្បាលខាងលើនេះ។

**ហេតុដូច្នេះ សម្រេច**

អនុញ្ញាតឱ្យធ្វើការកម្ទេចចោលនូវមាន់ជល់ចំនួន ៩២ក្បាល ចាប់ពីពេលនេះតទៅ។

កណ្តាល, ថ្ងៃទី..19... ខែធ្នូ ឆ្នាំ ២០១៧

**ចៅក្រមស៊ើបសួរ**

..................................

ថ្ងៃទី....19...ខែធ្នូ ឆ្នាំ ២០១៧

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

លេខ............................

# លិខិតជូនដំណឹងអំពីការបិទការស៊ើបសួរ

**យើង ................................ ចៅក្រមស៊ើបសួរនៃសាលាដំបុងខេត្តកណ្ដាល**

សូមជូនដំណឹងដល់ឈ្មោះ ........................ ជាដើមបណ្ដឹងរដ្ឋប្បវេណី មានទីលំនៅភូមិទួលរកា សង្កាត់ចាក់ក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ជ្រាបថា: ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល បានបិទការស៊ើបសួរនៃសំណុំរឿងព្រហ្មទណ្ឌលេខ ៣៧៧ អក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ពីបទ: **ធ្វើឲ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិកំពុងតាឡុង ឃុំបឹងខ្យាង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

អាស្រ័យហេតុនេះ សូមលោក-លោកស្រីជ្រាបជាដំណឹង ។

កណ្ដាល, ថ្ងៃទី............ខែ.............ឆ្នាំ២០១៤
**ចៅក្រមស៊ើបសួរ**

យើង.......................................បានប្រគល់លិខិត ជូនដំណឹង
នេះដល់ឈ្មោះ..............................................................................
ទីលំនៅភូមិ.............................ឃុំ..........................ស្រុក
.....................................ខេត្ត.............................
នៅថ្ងៃទី.....ខែ...........ឆ្នាំ.........ផ្ទាល់ដៃរួចហើយ ។
ធ្វើនៅថ្ងៃទី............ខែ.................ឆ្នាំ២០....
អ្នកទទួល អ្នកប្រគល់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

លេខ............................

## លិខិតជូនដំណឹងអំពីការបិទការស៊ើបសួរ

**យើង** ................................. ចៅក្រមស៊ើបសួរនៃសាលាដំបុងខេត្តកណ្តាល

សូមជូនដំណឹងដល់ឈ្មោះ ...................ជាជនត្រូវចោទ មានទីលំនៅភូមិកំពុងតាឡុង ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ជ្រាបថា: ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល បានបិទការស៊ើបសួរនៃសំណុំរឿងព្រហ្មទណ្ឌលេខ ៣៦៣ អក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ពីបទ: **ធ្វើឲ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិកំពុងតាឡុង ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។

អាស្រ័យហេតុនេះ សូមលោក-លោកស្រីជ្រាបជាដំណឹង ។

កណ្តាល, ថ្ងៃទី............ខែ.............ឆ្នាំ២០១៤
**ចៅក្រមស៊ើបសួរ**

យើង.......................................បានប្រគល់លិខិត ជូនដំណឹង
នេះដល់ឈ្មោះ...................................
ទីលំនៅភូមិ.............................ឃុំ..........................ស្រុក
...............................ខេត្ត.............................
នៅថ្ងៃទី.....ខែ...........ឆ្នាំ.........ផ្ទាល់ដៃរួចហើយ ។

ធ្វើនៅថ្ងៃទី............ខែ.................ឆ្នាំ២០....

អ្នកទទួល អ្នកប្រគល់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**
លេខ ៖..................................

# ដីកាបញ្ជូនព័ត៌មាន

យើង .........................................ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល

**បានឃើញ** សំណុំរឿងព្រហ្មទណ្ឌលេខ ០១៥ អក ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៤ ។

បញ្ជាឱ្យបញ្ជូនសំណុំរឿងស៊ើបសួរទាក់ទងនឹងឈ្មោះ ............ ភេទប្រុស អាយុ២១ឆ្នាំ ជាជនត្រូវចោទ **(ក្នុងឃុំ)** នៅក្នុងការស៊ើបសួរពីបទ: **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាសទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

ទៅព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្ដីសន្និដ្ឋាន ឬផ្ដល់យោបល់លើ ការបិទការស៊ើបសួរ ស្របតាមមាត្រា ២៤៦ និង មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

កណ្ដាល, ថ្ងៃទី .........ខែ................ឆ្នាំ២០១...

**ចៅក្រមស៊ើបសួរ**

**យោបល់របស់តំណាងអយ្យការ**

បានទទួលព័ត៌មានរួចហើយ

កណ្ដាល . ថ្ងៃទី..........ខែ...........ឆ្នាំ២០១......

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

លេខ ៖..........................................

## ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ

យើង ............................... ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល

-បានឃើញមាត្រា ២៤៦ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ០៩២ អក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-បានឃើញសំណុំរឿងស៊ើបសួរទាក់ទិននឹងជនត្រូវចោទ ៖

-ឈ្មោះ................ ភេទប្រុស អាយុ២១ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិលេខ១ សង្កាត់ផ្សារអូឬស្សី២ ខណ្ឌប្រាំពីរមករា រាជធានីភ្នំពេញ ខេត្តកណ្ដាល ។

ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

បញ្ជាឱ្យបញ្ជូនសំណុំរឿងស៊ើបសួរនេះទៅព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋាន ឬ ផ្តល់យោបល់ទៅតាម ក្រមនីតិវិធីព្រហ្មទណ្ឌ ។

កណ្ដាល, ថ្ងៃទី...........ខែ...........ឆ្នាំ២០១....

**ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

### យោបល់របស់តំណាងអយ្យការ

យើង.................................ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តកណ្ដាល

បានឃើញដីកាបញ្ជូនពត៌មានខាងលើ

បានឃើញសំណុំរឿងស៊ើបសួរលើឈ្មោះ..........................................

...................................................................................................

ក្រោយពីបានពិនិត្យសំណុំរឿងស៊ើបសួរចប់ ស្នើសុំ ៖

...................................................................................................

កណ្ដាល, ថ្ងៃទី..........ខែ............ឆ្នាំ២០១៥

**ព្រះរាជអាជ្ញា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តកណ្ដាល

# ដីកាសន្និដ្ឋានស្ថាពរ

សំណុំរឿងព្រហ្មទណ្ឌលេខ ៦៦៣ អ.ក
ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧
លេខ៖ ៦៣៦ ដកសព

យើង [redacted] តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៥១១ ដកសស ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ។

-បានឃើញសំណុំរឿងស៊ើបសួរលេខ ៣៧៧ សស ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ។

-បានឃើញដីកាបញ្ជូនឱ្យឆ្លើយដើម្បីបញ្ចប់ការស៊ើបសួរលេខ ៨៧៤ /១៧ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ ។

-បានឃើញដីកាបញ្ជូនរឿងទៅពិនិត្យលេខ ៨៧៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរ។

## ក្រោយ ពីបានពិនិត្យឯកសារខាងលើ

**យល់ឃើញថា ៖**

១-នាមត្រកូល [redacted] នាមខ្លួន [redacted] ភេទប្រុស ជាជនសង្ស័យ
អាយុ ៖ អាយុ២២ឆ្នាំ(កើតឆ្នាំ១៩៩៥)
ទីកន្លែងកំណើត ៖ នៅភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។
លំនៅបច្ចុប្បន្ន ៖ នៅភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល។
មុខរបរ ៖ កម្មករសំណង់
នៅលីវ ☑ ឬ រៀបការ ☐
សញ្ជាតិ ៖ [redacted]
ឪពុកឈ្មោះ [redacted] "រស់" ម្ដាយឈ្មោះ [redacted] "រស់" ។
ទោសពីមុខ ៖ ជាប់ពន្ធនាគារ១៨ខែ ពីបទ លួច កម្រិតវប្បធម៌ ៖ ថ្នាក់ទី៧



អាស័យដ្ឋានៈ ផ្លូវជាតិលេខ២ ភូមិតាខ្មៅ២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល
Address: National Road2, Phum Takhmao2, Sangkat Takhmao, Takhmao City, Kandal P...

| | |
|---|---|
| ២-នាមត្រកូល | នាមខ្លួន ៖ ភេទប្រុស ជាជនសង្ស័យ |
| អាយុ | ៖ អាយុ២៤ឆ្នាំ(កើតឆ្នាំ១៩៩៣) |
| ទីកន្លែងកំណើត | ៖ នៅភូមិបាក់ដាវ ឃុំបាក់ដាវ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ |
| លំនៅបច្ចុប្បន្ន | ៖ នៅភូមិបាក់ដាវ ឃុំបាក់ដាវ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ |
| មុខរបរ | ៖ កម្មករសំណង់ |
| នៅលីវ ☑ ឬ រៀបការ ☐ | |
| សញ្ជាតិ | ៖ ខ្មែរ |
| ឪពុកឈ្មោះ | ៖ ... រស់" ម្ដាយឈ្មោះ ៖ ... ប់" ។ |
| ទោសពីមុន | ៖ ជាប់ពន្ធនាគារ៨ខែ ពីបទ លួច កម្រិតវប្បធម៌ ៖ ថ្នាក់ទី៨ |

**ឃើញថា**[១] ៖ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោង០៨ និង០០ នាទី ឈ្មោះ ... ជិតម៉ូតូ ម៉ាកវីវ៉ា ឌុបឈ្មោះ ... តាមផ្លូវលេខ១១០ (ត្រើយខាងកើតទន្លេទបាសាក់) មកដល់ចំណុចភូមិព្រែកតានប់ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ក៏ប្រទះឃើញឈ្មោះ ... កំពុងជិះម៉ូតូ ម៉ាកសង់កូរ៉េពណ៌ក្រហមពីទិសខាងជើងទៅទិសខាងត្បូងស្របទិសគ្នា ពេលជាមួយគ្នានោះឈ្មោះ ... បានឆក់កាបូបដៃពីដៃខាងឆ្វេងឈ្មោះ ... រួចជិះម៉ូតូសំដៅមកឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល ពេលនោះជនរងគ្រោះបានស្រែកថាចោរៗ ទើបនគរបាលប៉ុស្តិ៍ស្វាយប្រទាល កំពង់ល្បាតតាមភូមិសាស្រ្តបានដេញតាម ភ្លាមនោះជនសង្ស័យទំលាក់កាបូបលុយចោលហើយបន្តដេញជនសង្ស័យដោយសហការជាមួយនគរបាលប៉ុស្តិ៍ត្រើយ ... ធ្វើការឃាត់ជនសង្ស័យទាំងពីរនាក់រួមវត្ថុតាង(ម៉ូតូ)នៅភូមិថ្កុល ឃុំត្រើយស្លា ស្រុកស្អាង រួចបញ្ជូនមកអធិការដ្ឋាននគរបាលស្រុកស្អាង ដើម្បីបន្តអនុវត្តតាមនីតិវិធី។

**ឃើញថា ៖ នៅដំណាក់កាលស៊ើបអង្កេតរបស់អធិការដ្ឋាននគរបាលស្រុកស្អាង ៖**

-ជនត្រូវចោទឈ្មោះ ... បានឆ្លើយសារភាពថា ៖ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោងប្រហែលប្រាំពីរព្រឹក ខ្លួន និងឈ្មោះ ... ជាមិត្តភក្តិនឹងគ្នាធ្វើការជាកម្មករសំណង់ដូចគ្នាបានជិះម៉ូតូម៉ាកវីវ៉ាពណ៌ខ្មៅ ចេញពីតាខ្មៅឆ្លងស្ពានព្រែកសំរោង រួចជិះតាមផ្លូវត្រើយខាងកើតទន្លេបាសាក់ឆ្ពោះមកទិសខាងត្បូង ដោយឈ្មោះ ... បើកម៉ូតូរបស់ខ្លួន។ លុះពេលខ្លួនជិះម៉ូតូចេញពីស្ពានតាខ្មៅមកទិសខាងត្បូងឆ្ងាយដល់មុំដែលខ្លួនមិនស្គាល់តាមផ្លូវក្រាលកៅស៊ូ ក៏បានឃើញមនុស្សស្រីប្រហែលពីរទៅបីនាក់ជិះម៉ូតូក្នុងទិសដៅពីជើងទៅត្បូងដូចខ្លួនដែរ ហើយអ្នកបើកម៉ូតូមានកាបូបដាក់សម្ភារៈនៅនឹងដៃខាងឆ្វេងផង និងដៃម៉ូតូផង ខ្លួនប្រាប់ឲ្យឈ្មោះ ... បើកម៉ូតូអែបទៅខាងឆ្វេងម៉ូតូរបស់មនុស្សស្រីនោះ រួចខ្លួនប្រើដៃខ្លួនខាងស្ដាំលូកចាប់កាបូបពីមនុស្សស្រីម្នាក់

[១] រៀបរាប់សង្ខេបអង្គហេតុ និងរាល់ចំណាត់ការនៃនីតិវិធីតាមលំដាប់ (ឧទាហរណ៍ អង្គហេតុដែលបានកើតឡើង ចំណាត់ការរបស់មន្ត្រីនគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួរ)

នោះបានសម្រេច ដោយមិនបណ្តាលឲ្យម៉ូតូរបស់មនុស្សស្រីនោះដួលនោះទេ ភ្លាមនោះឈ្មោះ [redacted]បន្ថែម ល្បឿនម៉ូតូឆ្ពោះទៅមុខទៀតយ៉ាងលឿន ចំណែកម្ចាស់កាបូបបានស្រែកខ្លាំងៗថា ចោរៗជួយផង និងបើកម៉ូតូតាមពួកខ្លួន ពេលនោះខ្លួនភ័យព្រោះឃើញមាននគរបាលតាមខ្លួនដែរ ខ្លួនក៏ទម្លាក់កាបូបនោះចោលទៅ[redacted] ល្បឿនម៉ូតូទៅមុខទៀតឆ្លាយចូលតាមមាត់ព្រែក ស្រាប់តែនគរបាលព័ទ្ធចាប់បានរូបខ្លួន និងឈ្មោះ [redacted] និងបញ្ជូនខ្លួនមកទីនេះតែម្តង។

-ជនត្រូវចោទឈ្មោះ [redacted]នឆ្លើយសារភាពថា ៖ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោងប្រហែលប្រាំពីរព្រឹក ខ្លួន និងឈ្មោះ [redacted] ជាកម្មករសំណង់ជាមួយគ្នា បានទាំគ្នាជិះម៉ូតូម៉ាកវីវ៉ា ពណ៌ខ្មៅ ស្លាកលេខ 1T-9523 ភ្នំពេញ។ ខ្លួនបើកម៉ូតូឌុបឈ្មោះ [redacted] ជិះឆ្លងស្ពានព្រែកសំរោងមកត្រើយខាងកើត រួចខ្លួនជិះតាមផ្លូវចុះមកស្រុកស្អាង ដល់ផ្សារមួយ ខ្លួនឃើញមានមនុស្សស្រីចំនួនបីនាក់ជិះម៉ូតូ ម៉ាកសង់កូរ៉េ ពណ៌ក្រហម ហើយមានកាន់កាបូបនៅនឹងដៃ ពេលនោះខ្លួនជិះម៉ូតូអែបឲ្យឈ្មោះ [redacted]ឆក់ ពេលឆក់នោះ ខ្លួនបើកម៉ូតូរត់មកមុខ ភ្លាមនោះខ្លួនឃើញមានម៉ូតូចំនួនពីរគ្រឿងដេញតាមពីក្រោយ ខ្លួនរត់បានប្រហែលមួយគីឡូម៉ែត្រ ខ្លួននៅតែឃើញមានគេដេញខ្លួនដដែល ខ្លួនក៏បានប្រាប់ឲ្យឈ្មោះ ស្រស់ បោះកាបូបនោះចោល រួចខ្លួនបើកម៉ូតូរត់ទៅដល់ត្រើយស្លា ទើបនគរបាលដេញចាប់ខ្លួនបានទាំងពីរនាក់តែម្តង។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]នឆ្លើយបំភ្លឺថា៖ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោងប្រហែលដប់ព្រឹក ពេលខ្លួនជិះមកដល់ចំណុចគល់ស្ពានព្រែកតានប់ ស្ថិតនៅភូមិព្រែកតានប់ ក៏ស្រាប់តែមានបុរសពីរនាក់ដែលខ្លួនមិនស្គាល់ឈ្មោះជិះម៉ូតូម៉ាកវីវ៉ា ពណ៌ខ្មៅ ជិះពីជើងមកត្បូងស្របទិសគ្នាជាមួយខ្លួនក៏បានឆក់កាបូបលុយដែលខ្លួនកាន់ដៃខាងឆ្វេងយកទៅ ហើយខ្លួនមិនបានដួលម៉ូតូទេ ហើយភ្លាមនោះខ្លួនស្រែកថា ចោរឆក់កាបូបពូមីងអើយជួយខ្ញុំផង ហើយខ្លួនក៏បានជិះម៉ូតូដេញតាមពីក្រោយចោរមកដល់ចំណុចវត្តឬស្សីជ្រោយក៏ជិះម៉ូតូលែងទាន់ចោរតែម្តង។

-សៀវភៅរូបថត ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ ដែលបង្ហាញពីចំនួនប្រាក់របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ,រូបថតរបស់ជនត្រូវចោទឈ្មោះ [redacted], ឈ្មោះ [redacted] និងរូបថតស្តីពីការប្រគល់ប្រាក់ឲ្យទៅដើមបណ្តឹងវិញដោយមន្ត្រីនគរបាលយុត្តិធម៌។

**ឃើញថា ៖ នៅដំណាក់កាលស៊ើបអង្កេតរបស់តំណាងអយ្យការ មានភស្តុតាងដូចខាងក្រោម ៖**

យោងតាមរបាយការណ៍សរុប លេខ ០៦៤ រ.ប.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ របស់អធិការដ្ឋាននគរបាលស្រុកស្អាង អយ្យការបានសួរយកចម្លើយជនត្រូវចោទឈ្មោះ [redacted] ដោយឈ្មោះ [redacted]បាន រក្សាទុកចម្លើយដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាល ទុកជាបានការដដែលពុំមានកែប្រែអីនោះទេ និងបានឆ្លើយសារភាពថា នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោងប្រាំបីព្រឹក ខ្លួន [redacted] បានជិះម៉ូតូមួយគ្រឿងម៉ាកវីវ៉ា គ្មានពន្ធ តែមានស្លាកលេខមិនចាំអក្សរ លេខ 9523 ដែលពេលនោះឈ្មោះ [redacted] ជាអ្នកឌុប លុះដល់ចំណុចផ្សារទំនប់ ក៏ឃើញមានស្ត្រីម្នាក់បើកម៉ូតូម៉ាកអាសង់ការ៉េឌុបគ្នាបីនាក់ ហើយក៏ឃើញកាបូបស្ត្រីនោះផ្តក់នៅលើដៃម៉ូតូ ពេលនោះឈ្មោះ [redacted]បានបើកម៉ូតូអែបម៉ូតូស្ត្រីនោះ ភ្លាមនោះខ្លួនក៏ធ្វើសកម្មភាពឆក់កាបូបស្ត្រីនោះបាន រួចក៏ជិះរត់គេចខ្លួន ប៉ុន្តែនៅពេលនោះក៏មានសមត្ថកិច្ចដេញតាម រួចខ្លួន

ក៏បោះកាបូបចោល លុះជិះបានចំងាយ១០គីឡូម៉ែត្រ ពីកន្លែងកើតហេតុ ស្រាប់តែសមត្ថកិច្ចចាប់ខ្លួន ពួកខ្លួនបានតែម្តង។

- ជនត្រូវចោទឈ្មោះ [redacted] ហៅ [redacted] បានរក្សាទុកចម្លើយដែលបានឆ្លើយនៅចំពោះមុខមន្ត្រីនគរបាល ទុកជាបានការដដែលពុំមានកែប្រែអ្វីនោះទេ និងបានឆ្លើយសារភាពថា នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោងប្រាំបីព្រឹក [redacted] បានជិះម៉ូតូ មួយគ្រឿងម៉ាកវីវ៉ា គ្មានពន្ធ តែមានស្លាកលេខភ្នំពេញ1T-9523 ដែលពេលនោះខ្លួនជាអ្នកឌុប លុះដល់ចំណុចផ្សារទំនប់ ក៏ឃើញមានស្ត្រីម្នាក់បើកម៉ូតូម៉ាកសង់ការ៉េឌុបគ្នាបីនាក់ ហើយក៏ឃើញកាបូបស្ត្រីនោះផ្តក់នៅលើដៃម៉ូតូ ពេលនោះខ្លួនបានបើកម៉ូតូអែបម៉ូតូស្ត្រីនោះ ភ្លាមនោះឈ្មោះ [redacted] បានធ្វើសកម្មភាពឆក់កាបូបស្ត្រីនោះបាន រួចពួកខ្លួនក៏ជិះរត់គេចខ្លួន ប៉ុន្តែនៅពេលនោះក៏មានសមត្ថកិច្ចដេញតាម ពេលនោះឈ្មោះ [redacted] ក៏បានបោះកាបូបនោះចោល លុះជិះដល់ត្រើយស្លា ស្រាប់តែសមត្ថកិច្ចចាប់ខ្លួនពួកខ្លួនបានតែម្តង។

**ឃើញថា ៖ នៅដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ មានភស្តុតាងដូចខាងក្រោម៖**

-ជនត្រូវចោទឈ្មោះ [redacted] បានរក្សាទុកចម្លើយដែលបានឆ្លើយនៅចំពោះសមត្ថកិច្ច និងនៅចំពោះមុខតំណាងអយ្យការ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ទុកជាបានការដដែល ពុំមានកែប្រែអ្វីនោះទេ។

-ជនត្រូវចោទឈ្មោះ [redacted] បានរក្សាទុកចម្លើយដែលបានឆ្លើយនៅចំពោះសមត្ថកិច្ច និងនៅចំពោះមុខតំណាងអយ្យការ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ទុកជាបានការដដែល ពុំមានកែប្រែអ្វីនោះទេ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា ៖ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោងប្រហែលប្រាំពីរ និងសាមសិបនាទីព្រឹក ខ្លួនបានទៅផ្សារដើម្បីទិញម្ហូប រួចខ្លួនក៏បានជិះម៉ូតូត្រឡប់មកវិញ មកដល់ចំណុចព្រៃកតាទប់ ពេលនោះក៏មានមនុស្សប្រុសពីរនាក់ជិះម៉ូតូមកជិតខ្លួន ហើយបានឆក់យកកាបូបរបស់ខ្លួន ហើយពេលនោះខ្លួនក៏បានស្រែកឱ្យគេជួយ បន្ទាប់មកក៏មានអ្នកជួយតាមចាប់ចោរបានតែម្តង។

-ជនត្រូវចោទឈ្មោះ [redacted] ត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្ន តាមដីកាសម្រេចលេខ ១៣៤៤ ដក.ស.ឃខ/១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ។

-ជនត្រូវចោទឈ្មោះ [redacted] ត្រូវបានចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្តោះអាសន្ន តាមដីកាសម្រេចលេខ ១៣៤២ ដក.ស.ឃខ/១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ។

## យល់ឃើញថា[២]

-អង្គហេតុខាងលើ បានកើតឡើងស្ថិតនៅក្នុងភូមិព្រៃកតាទប់ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល ហេតុដូច្នេះ ជាសមត្ថកិច្ចរបស់អយ្យការ និងសាលាដំបូងខេត្តកណ្តាល តាមមាត្រា៣៩ មាត្រា១២៣ និងមាត្រា**២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ។

-គិតចាប់ពីពេលដែលបទល្មើសកើតឡើង អាយុកាលនៃបទល្មើសមិនទាន់ផុតនៅឡើយទេ ដូច្នេះ អយ្យការ និងសាលាដំបូងខេត្តកណ្តាល នៅតែមានសមត្ថកិច្ចចាត់ការលើសំណុំរឿងនេះ តាមមាត្រា១០ និងមាត្រា១១ **នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ។

---

[២] សំអាងហេតុ សំអាងច្បាប់

-ជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] នៅដំណាក់កាលស៊ើបអង្កេត និងកិច្ចស៊ើបសួរបានឆ្លើយសារភាពថា៖ កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ ពួកខ្លួនពិតជាឆក់យកកាបូបលុយពីស្រីម្នាក់ដែលកំពុងជិះម៉ូតូស្របទិសគ្នា ដែលមានឈ្មោះ [redacted] បានសម្រេច ហើយក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួនបានប្រាកដមែន ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ឆ្លើយបញ្ជាក់ថា៖ កាលពីថ្ងៃកើតហេតុពិតជាមានឈ្មោះ [redacted] និងឈ្មោះ [redacted] បានជិះម៉ូតូមកអែបម៉ូតូរបស់ខ្លួន និងបានឆក់យកកាបូបលុយរបស់ខ្លួនបានសម្រេចប្រាកដមែន ។

-ជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ជានីតិជន មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តអំពើខាងលើ ។

-អំពើរបស់ជនត្រូវចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ពលរដ្ឋ ជាពិសេសច្បាប់បញ្ញត្តិអំពើនេះជាបទល្មើស **អំពើលួច** ដែលចែងឱ្យផ្តន្ទាទោសតាម៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

-មានភស្តុតាង និងធាតុផ្សំគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ២៤ ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ២២ ឆ្នាំ ពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រៃកតានប់ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

**សម្រេច**

ប្តឹងទៅចៅក្រមស៊ើបសួរ

១/.បញ្ជូនជនត្រូវចោទឈ្មោះ [redacted] ភេទប្រុស អាយុ២៤ ឆ្នាំ (ក្នុងឃុំ) និងឈ្មោះ [redacted] ភេទប្រុស អាយុ២២ ឆ្នាំ (ក្នុងឃុំ) ពីបទ **អំពើលួច** ប្រព្រឹត្តនៅភូមិព្រៃកតានប់ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥៣ និងមាត្រា៣៥៦ នៃក្រមព្រហ្មទណ្ឌ ទៅជំនុំជម្រះ។

កណ្តាល, ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៧

**តំណាងអយ្យការ**

[redacted]

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

**ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ**

លេខ: ..................ដក.ជស.ស

យើង ................................ ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល

_បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៤៨៤ អ.ក ចុះថ្ងៃទី០៦.០៦.២០១៤។

_បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ០៦៥ ដក.សពចុះថ្ងៃទី១៩.០១.២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

ក្រោយពីបានពិនិត្យស៊ើបសួរមូលចប់សព្វគ្រប់ហើយ

**យល់ឃើញថា:**

_តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ .................. នៅចំពោះមុខសមត្ថកិច្ច និងនៅចំពោះមុខតំណាងអយ្យការបានឆ្លើយបញ្ជាក់ថា: ខ្លួនពិតជាបានខ្ចីប្រាក់ពីឈ្មោះ ផាច រេកសៀក ចំនួន ៣.៤៥០ (បីពាន់បួនរយហាសិបដុល្លាអាមេរិក) ប្រាកដមែន ដោយខ្លួនបានធ្វើកិច្ចសន្យាជាមួយឈ្មោះ ...................... ដោយធ្វើការកាត់ប្រាក់ខែសង ។ ក្រោយមកខ្លួនបានធ្វើការបាន២ទៅ៣ខែ ហើយខ្លួនក៏បានបញ្ហាជាមួយគ្រួសារ ហើយខ្លួនក៏បានរត់ទៅធ្វើការនៅកន្លែងឡឥដ្ឋផ្សេង ទើបម្ចាស់ប្រាក់ប្ដឹងខ្លួន ក្រោយមកខ្លួនបានខ្ចីប្រាក់ពីឈ្មោះ .......................ចំនួន ២.២០០ ដុល្លា (ពីរពាន់ពីររយដុល្លាអាមេរិក ) ហើយខ្លួនបានធ្វើការឲ្យឈ្មោះ ....................បាន២ខែ ហើយខ្លួនក៏បញ្ហាជាមួយគ្រួសារ ទើបខ្លួនទៅតាមរកតែរកមិនឃើញក្រោយមកទើបខ្លួនទៅធ្វើការនៅឡឥដ្ឋរបស់ឈ្មោះ......................វិញ ទើបសមត្ថកិច្ចឃាត់តែម្ដង។

_តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ...................... បានឆ្លើយបញ្ជាក់ថា: ...................... និងប្រពន្ធបានមកខ្ចីប្រាក់ពីខ្លួនចំនួន២.៥៥០ ដុល្លា (ពីរពាន់ប្រាំរយហាសិប) ក្រោយពីឈ្មោះ ...................... ធ្វើការនៅឡឥដ្ឋខ្លួនបាន៥ខែ ឈ្មោះ នេះបណ្ដោះឲ្យប្រពន្ធចេញពីឡឥដ្ឋខ្លួន ក្រោយមកបាន២អាទិត្យឈ្មោះ ............................... បានលួចចេញពីឡឥដ្ឋ ខ្លួនក៏ឲ្យសមត្ថកិច្ចតាមរកទើបប្រទះឃើញធ្វើការនៅកន្លែងផ្សេង ហើយសមត្ថកិច្ចក៏នាំខ្លួនមកឡឥដ្ឋខ្លួន ហើយខ្លួនក៏រៀបចំឯកសារប្ដឹងសមត្ថកិច្ចតែម្ដង។

_មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ:

_ឈ្មោះ ..................ភេទប្រុស អាយុ៣២ឆ្នាំ ជាតិ ខ្មែរ សាសនា ព្រះពុទ្ធ មុខរបរៈ កម្មករឡូតដ្ឋ ទីកន្លែងកំណើតនៅភូមិក្តុលជ្រុំ ឃុំកំពង់ក្រសាំង ស្រុកបូរីជលសារ ខេត្តតាកែវ បច្ចុប្បន្ននៅភូមិអន្ទង់ ឃុំព្រៃកតាមាក់ ស្រុកមុខកំពូល ខេត្តកណ្តាល ប្រពន្ធឈ្មោះ ..........................មានកូនចំនួន០២នាក់ ឪពុកឈ្មោះ ....................(ស) ម្តាយឈ្មោះ..........................(រ) ទោសពីមុនគ្មាន ។

_**ត្រូវជាប់ចោទពីបទៈ ឆបោក** ប្រព្រឹត្តនៅភូមិក្រោម ឃុំព្រៃកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាលកាលពីថ្ងៃទី ០១.០៥.២០១៣ ។ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះ-សម្រេច

១_បញ្ជូនជនជាប់ចោទ .............ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ ខាងលើនេះ និងសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៧២ អ.ក ចុះថ្ងៃទី ២៦.០២.២០១៤ ព្រមទាំងវត្ថុតាងនិងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅសាលាដំបូងខេត្តកណ្តាល ដើម្បីជំនុំជំរះ ។

កណ្តាល,ថ្ងៃទី............ខែមិថុនា ឆ្នាំ ២០១.....

**ចៅក្រមស៊ើបសួរ**

**បានទទួលដំណឹងរួចហើយ**

កណ្តាល,ថ្ងៃទី ......... ខែ ........ ឆ្នាំ ២០......

**តំណាងអយ្យការ**

សាលាដំបូងខេត្តកណ្តាល

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ដីកាដំណោះស្រាយ

លេខ: ....................ពស.រប

យើង................................ ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល

_បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ២៦២ អ.ក ចុះថ្ងៃទី ២៤.០៣.២០១៦។

_បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៦៨៣ ដក.សព ចុះថ្ងៃទី២៩.០៨.២០១៦ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

## ក្រោយពីបានពិនិត្យស៊ើបសួរមូលចប់សព្វគ្រប់ហើយ

## យល់ឃើញថា:

_មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ៖

១.ឈ្មោះ ..................................ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ត្រែ ទីកន្លែងកំណើត និងទីលំនៅភូមិព្រៃក្តួច ឃុំភ្នំតូច ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ នៅលីវ ឪពុកឈ្មោះ មិច ចិត្ត (រ) ម្តាយឈ្មោះ កយ ខុន (រ) ទោសពីមុនគ្មាន។

**ឃុំខ្លួន ថ្ងៃ២៤ ខែមីនា ឆ្នាំ២០១៦**

២.ឈ្មោះ ................................ ភេទប្រុស អាយុ១៦ឆ្នាំ ជាតិខ្មែរ មុខរបរ សិស្ស ទីកន្លែងកំណើត និងទីលំនៅភូមិត្រពាំងអំពិល ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នៅលីវ ឪពុកឈ្មោះ ហៃ ជី (រ) ម្តាយឈ្មោះ ហ៊ិន ស្រីម៉ៅ (រ) ទោសពីមុនគ្មាន។

**ឃុំខ្លួន ថ្ងៃ២៤ ខែមីនា ឆ្នាំ២០១៦**

៣.ឈ្មោះ ........................................ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបរ សិស្ស ទីកន្លែងកំណើត និងទីលំនៅភូមិព្រៃគោ ឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាល ប្រពន្ធឈ្មោះ ម៉ឹង ធីតា ឪពុកឈ្មោះ រ័ត្ន សម្បត្តិ (រ) ម្តាយឈ្មោះ ឌឹម សៀង (រ) ទោសពីមុនគ្មាន។

**ឃុំខ្លួន ថ្ងៃ២៤ ខែមីនា ឆ្នាំ២០១៦**

៤.ឈ្មោះ ...............................ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតភូមិគរ ឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងទីលំនៅភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តក

ណ្តាល ប្រពន្ធឈ្មោះ ខន សុខគា ឪពុកឈ្មោះ សៅ ស៊ិន (រ) ម្តាយឈ្មោះ ពីម សុខហៀក (រ) ទោសពីមុនគ្មាន ។ឃុំខ្លួន ថ្ងៃ២៤ ខែមីនា ឆ្នាំ២០១៦

៦.ឈ្មោះ **ឆ្វ** គ្មានសាវតាជាតិគ្រប់គ្រាន់ គប្បីតុលាការលើកលែងការចោទប្រកាន់។ក្រៅឃុំ

ត្រូវជាប់ចោទពីបទ **ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន, ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ ៥១ ភូមិក្តាន់រយ ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាលកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤២ មាត្រា ៤៥ និងមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ហេតុដូច្នេះ-សម្រេច

១-លើកលែងការចោទប្រកាន់លើជនត្រូវចោទឈ្មោះ **ឆ្វ** គ្មានសាវតាជាតិ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ ៥១ ភូមិក្តាន់រយ ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាលកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២- បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ២៦២ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ និងជនត្រូវចោទឈ្មោះ ..............................ភេទប្រុស អាយុ ១៦ឆ្នាំ (ក្នុងឃុំ), ឈ្មោះ ..............................ភេទប្រុស អាយុ ១៦ឆ្នាំ (ក្នុងឃុំ), ឈ្មោះ .............................. ភេទប្រុស អាយុ ២៣ឆ្នាំ (ក្នុងឃុំ) ឈ្មោះ ..............................ភេទប្រុស អាយុ ២៨ឆ្នាំ (ក្នុងឃុំ) ពីបទ **ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងបទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិមាត្រា ៤២ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចផ្លូវជាតិលេខ ៥១ ភូមិក្តាន់រយ ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាលកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០១៦ ទៅជំនុំជម្រះតាមនីតិវិធីច្បាប់ ។

២-រក្សាជនត្រូវចោទ ដែលមាននៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងសំណុំរឿង នេះទៅជំនុំជម្រះតាមច្បាប់

កណ្តាល,ថ្ងៃទី........ខែ..............ឆ្នាំ២០១....

**ចៅក្រមស៊ើបសួរ**

**បានទទួលដំណឹងរួចហើយ**

កណ្តាល,ថ្ងៃទី ......... ខែ ........ ឆ្នាំ២០១....

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

# ដីកាដំណោះស្រាយ

លេខ .................. ដកដស

យើង ................................ ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្តាល ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៦ អក ចុះថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០១៥ ។

-បានឃើញដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ៣៣៤ ដកសស.១៥ ចុះថ្ងៃទី១៤ ខែ- ឧសភា ឆ្នាំ ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខៈ ១០០១ ដកសព ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការ អមសាលាដំបូងខេត្តកណ្តាល ។

**ក្រោយពីបានពិនិត្យមូលចប់សព្វគ្រប់ ៖**

**<u>យល់ឃើញថា</u>**

**១**-ជនត្រូវចោទឈ្មោះ ............................ ហៅឌី និងឈ្មោះ .......................... ត្រូវបានតំណាងអយ្យការ បើកការស៊ើបសួរកំណត់បទល្មើស ពីបទៈ **"ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន"** និងឈ្មោះ ................................, ឈ្មោះ ........................., ឈ្មោះ .......................... និងឈ្មោះ .......................... ត្រូវបានតំណាងអយ្យការបើកការស៊ើបសួរកំណត់បទល្មើសពីបទ **"ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន"** តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ៣៣៤ ដកសស.១៥ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

**២**-តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ ................................ បានឆ្លើយថាៈ កាលពីថ្ងៃកើតហេតុនោះ ខ្លួនរួមជាមួយឈ្មោះ......................... ឈ្មោះ............................... និងឈ្មោះ................................ បានចូលលុយគ្នាបានចំនួន ២០ ដុល្លារ ដើម្បីទិញគ្រឿងញៀនជក់ ពេលបានលុយរួចខ្លួនបានជិះម៉ូតូទៅទិញថ្នាំញៀនមួយកញ្ចប់តូចពីឈ្មោះ ............................. នៅមុំពេទ្យលោកសង្ឃ។ ក្រោយពេលទិញថ្នាំញៀនរួច ខ្លួនបានជិះម៉ូតូត្រលប់មកស្រុកលើកដែកវិញ ដោយបានទាំងទិញដែកកេះ ទុយោ ទិញស្ករកៅស៊ូមកជាមួយ ហើយបានណាត់ជួបឈ្មោះខាងលើដែលបានចូលលុយគ្នា ដើម្បីមកជក់ថ្នាំនៅក្នុងផ្ទះសំណាក់ឈ្មោះ មានកោះមាស ក្រោយពេលជក់អស់ស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួន ខ្លួន និងឈ្មោះ ..................... តែម្តង ។

**៣**-តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ ......................................... បានឆ្លើយថាៈ ខ្លួន រួមជាមួយឈ្មោះ ......................, ឈ្មោះ .........................និងឈ្មោះ .......................... បានចូលលុយគ្នាបានចំនួន ២០ ដុល្លារ រួចហើយឈ្មោះ .............................. ជិះម៉ូតូទៅទិញថ្នាំញៀនចំនួនមួយកញ្ចប់តូចនៅមុខពេទ្យលោកសង្ឃ។ ពេលឈ្មោះ ............................ ទិញបានហើយ ក៏បានណាត់ជួប ខ្លួន,.............................និង.................. ទៅជក់ថ្នាំញៀននៅក្នុងផ្ទះសំណាក់ មាន កោះមាស ក្រោយពេលជក់អស់ សមត្ថកិច្ចបានមកដល់ឃាត់ខ្លួន ខ្លួន និងឈ្មោះ..................តែម្តង ។

**៤**-តាមដីកាសន្និដ្ឋានស្ថាពរលេខៈ ១០០១ ដកសព/១៥ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការ អមដំបូងខេត្តកណ្តាល បានប្តឹងសុំឲ្យតុលាការកែប្រែការចោទប្រកាន់លើជនត្រូវចោទឈ្មោះ .................................. ពីបទៈ "**ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" មកបទៈ "**ប្រើប្រាស់ដោយខុស**

**ច្បាប់នូវសារធាតុញៀន**" វិញ ឃើញថា៖ ការប្តឹងសុំនេះមានលក្ខណៈត្រឹមត្រូវ ដូចការយល់ឃើញរបស់ចៅក្រមស៊ើបសួរដែរ ដូច្នេះ គប្បីតុលាការសម្រេចកែប្រែការចោទប្រកាន់លើ ជនត្រូវចោទឈ្មោះ ........................ ពីបទ៖ "**ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" មកបទ៖ "**ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" វិញ ។

៥-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ក្នុងការដាក់បន្ទុកលើឈ្មោះ ........................ ពីបទ៖ "**ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**", ឈ្មោះ ........................................ពីបទ" **ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" និងឈ្មោះ............................., ឈ្មោះ ........................, ឈ្មោះ ............................,ឈ្មោះ ........................ ពីបទ "**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**" ប្រព្រឹត្តនៅភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥ មាត្រា ៤២ និងមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៦-តាមបញ្ញត្តិមាត្រា **២០៤** នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា៖ *"ការឃុំខ្លួនបណ្តោះអាសន្នអាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទ ឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពីមួយឆ្នាំ"* ឃើញថា៖ ជនត្រូវចោទឈ្មោះ អ៊ូ សួយទ្រី ត្រូវបានកែប្រែការចោទប្រកាន់មកបទ៖ "**ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" ដែលជាបទល្មើសមានការផ្តន្ទាទោសកម្រិតអតិបរិមាត្រឹមតែ ០៦ខែ ប៉ុណ្ណោះ ដូច្នេះ ពុំអាចធ្វើការឃុំខ្លួនបណ្តោះអាសន្នលើជននេះបានទៀតទេ គប្បីដោះលែងជននេះឲ្យនៅក្រៅឃុំវិញ ។

**<u>ហេតុដូច្នេះសម្រេច</u>**

១-កែប្រែការចោទប្រកាន់លើជនត្រូវចោទឈ្មោះ .................. ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ពីបទ៖ "**ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកបទ៖ "**ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**" តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនវិញ ។

២-ដោះលែងជនត្រូវចោទឈ្មោះ .................. ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ឲ្យនៅក្រៅឃុំជាបណ្តោះអាសន្ន ។

៣-បញ្ជូនជនត្រូវចោទឈ្មោះ .................... ភេទប្រុស អាយុ ១៨ឆ្នាំ **ពីបទប្រើប្រាស់ដោយខុសច្បាប់**នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន

-បញ្ជូនជនត្រូវចោទឈ្មោះ .................... ភេទប្រុស អាយុ ២០ឆ្នាំ (ក្នុងឃុំ) ពីបទ **ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិមាត្រា៤២នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-បញ្ជូនជនត្រូវចោទឈ្មោះ .............. ភេទប្រុស អាយុ ៣១ឆ្នាំ, ឈ្មោះ .................. ភេទប្រុស អាយុ ៣៤ឆ្នាំ,ឈ្មោះ .............. ភេទប្រុស អាយុ ៣១ឆ្នាំ, និងឈ្មោះ ................. ភេទប្រុស អាយុ ២៩ឆ្នាំ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៦ ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៥ ព្រមទាំងវត្ថុតាង និងបញ្ជី រាយនាមជនដែលទាក់ទិនក្នុងសំណុំរឿងនេះ ទៅជំនុំជម្រះតាមនីតិវិធី ។

៤- រក្សាជនត្រូវចោទឈ្មោះ លីម វណ្ណី ដែលមាននៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន ក្នុងសំណុំរឿងនេះបញ្ជូនទៅជំនុំជម្រះ ។

កណ្តាល, ថ្ងៃទី.............ខែ............ឆ្នាំ២០១......

**ចៅក្រមស៊ើបសួរ**

បានទទួលដំណឹងរួចហើយ

កណ្តាល,ថ្ងៃទី.........ខែ...........ឆ្នាំ២០.....

**តំណាងអយ្យការ**

**សាលាដំបូងខេត្តកណ្ដាល**

**លេខ......................ពស.ព្រឧ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ដីកាបង្គាប់រក្សាទុក**

**ជនត្រូវចោទឱ្យនៅពន្ធនាគារជាបណ្ដោះអាសន្ន**

យើង ............................................ ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល

_បានឃើញក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាច្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០០៧ ។

_បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ១០៧ អ.ក ចុះថ្ងៃទី១៩ ខែមករា ២០១៧។

_បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ០៧៩ ដក.សស ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ ២០១៧របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញសំណុំរឿងស៊ើបសួរលេខ ០៧៥ ដក.សស ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នលេខ ២៥៧ដក.ប.ឃខចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល។

-បានឃើញដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ២៥៨ ដក.ប.ឃខចុះថ្ងៃទី១៩ខែ មករា ឆ្នាំ ២០១៧របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល។

-បានឃើញដីកាសន្និដ្ឋានស្ដាពរលេខ ៦៦១ ដក.ស.ព ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញដីកាដំណោះស្រាយលេខ..................ដក.ដរ ចុះថ្ងៃទី........ខែ............ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ។

**<u>យល់ឃើញថា</u>**

-ដើម្បីបញ្ចប់បទល្មើសនិងបង្ការ កុំឱ្យកើតមានបទល្មើសសាជាថ្មី គប្បីរក្សាជនជាប់ចោទទុកជូនចៅក្រមជំនុំជំរះ ចាត់ការតាមនីតិវិធីច្បាប់ ។

**<u>ហេតុដូច្នេះសម្រេច</u>**

-បង្គាប់ឱ្យប្រធានមន្ទីរឃុំឃាំងខេត្តកណ្ដាល រក្សាទុកជនជាប់ចោទឈ្មោះ ....................ខាងលើ ឱ្យនៅក្នុងឃុំជាបណ្ដោះអាសន្នសិន រហូតដល់មានសេចក្ដីសម្រេចផ្សេងពីនេះ។

កណ្ដាល ,ថ្ងៃទី ......ខែ.................ឆ្នាំ២០១៧

**ចៅក្រមស៊ើបសួរ**

យើង ................................. ប្រធានមន្ទីរឃុំឃាំងខេត្តកណ្ដាល បានអនុវត្ត រក្សាការឃុំខ្លួន ឈ្មោះ ........................ឃុំខ្លួន លេខ:................... ចុះថ្ងៃទី ..........
ខែ............... ឆ្នាំ ២០....... ។

**ពីបទ:**.......................................................................................................

ប្រព្រឹត្តនៅភូមិ ..................... ឃុំ .......................ស្រុក ......................... ខេត្ត ...................... កាលពីថ្ងៃទី ....... ខែ ......... ឆ្នាំ ២០....... តាមអំណាចដីកានេះ នៅថ្ងៃទី ....... ខែ............ ឆ្នាំ ២០ .......រួចហើយ។

***សំគាល់:*** ឈ្មោះនេះបានឃុំខ្លួនផ្សេងទៀតពីបទ:.............................................................

.................................................................................................................

កាលពីថ្ងៃទី .......... ខែ ........... ឆ្នាំ ២០........ត្រង់ លេខខ្លួន......................................

ចុះថ្ងៃទី ........ ខែ ............... ឆ្នាំ ២០ ....... របស់សាលាដំបូងខេត្តកណ្ដាល(បើគ្មានត្រូវដាក់ថា: គ្មានឬមាន)

ធ្វើនៅកណ្ដាល,ថ្ងៃទី ......... ខែ......... ឆ្នាំ ២០១៧

**ប្រធានមន្ទីរឃុំឃាំង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**

**លិខិតជូនដំណឹងពីការសម្រេចបញ្ជូន**
**សំណុំរឿងទៅជំនុំជម្រះ**

លេខ............................

*យើង...................................... ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល*

*សូមជូនដំណឹងដល់ឈ្មោះ ...................................ហៅ ...............................ភេទប្រុស អាយុ ២៣ឆ្នាំ ជាជនត្រូវចោទ មានទីលំនៅភូមិព្រែកអញ្ចាញ សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល។*

*ជ្រាបថា: ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល បានសម្រេចដាក់សំណុំរឿងទៅជំនុំជម្រះ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៤៨៤ អ.ក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤ ពីបទ: "**ធ្វើឱ្យខូចខាតដោយចេតនា**" ប្រព្រឹត្តនៅភូមិព្រែកអញ្ចាញ សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ។*

*អាស្រ័យហេតុនេះ សូមលោក-លោកស្រីជ្រាបជាដំណឹង។*

*ថ្ងៃ.......................ខែ.........ឆ្នាំរកា នព្វស័ក ព.ស២៥៦១*

*កណ្តាល, ថ្ងៃទី.......ខែ.........ឆ្នាំ២០១៨*

**ចៅក្រមស៊ើបសួរ**

យើង.......................................បានប្រគល់លិខិត ជូនដំណឹង
នេះដល់ឈ្មោះ...................................
ទីលំនៅភូមិ.............................ឃុំ..........................ស្រុក
................................ខេត្ត.............................
នៅថ្ងៃទី.....ខែ...........ឆ្នាំ.........ផ្ទាល់ដៃរួចហើយ។
ធ្វើនៅថ្ងៃទី............ខែ................ឆ្នាំ២០....
អ្នកទទួល អ្នកប្រគល់

## ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**

## លិខិតជូនដំណឹងពីការសម្រេចបញ្ជូន
## សំណុំរឿងទៅជំនុំជម្រះ

លេខ..............................

***យើង .................................. ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល***

*សូមជូនដំណឹងដល់ឈ្មោះ ................................... ភេទស្រី អាយុ ៤៨ឆ្នាំ ជាដើមបណ្ដឹង មានទីលំនៅភូមិព្រែកអញ្ចាញ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល។*

*ជ្រាបថា: ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល បានសម្រេចដាក់សំណុំរឿងទៅជំនុំជម្រះនៃសំណុំរឿងព្រហ្មទណ្ឌលេខ ៤៨៤ អ.ក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤ ពីបទ: "**ធ្វើឱ្យខូចខាតដោយចេតនា**" ប្រព្រឹត្តនៅភូមិព្រែកអញ្ចាញ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៣ តាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ ។*

*អាស្រ័យហេតុនេះ សូមលោក-លោកស្រីជ្រាបជាដំណឹង។*

*ថ្ងៃ......................ខែ.........ឆ្នាំរកា នព្វស័ក ព.ស២៥៦១*

*កណ្ដាល, ថ្ងៃទី.......ខែ.........ឆ្នាំ២០១៨*

**ចៅក្រមស៊ើបសួរ**

យើង.......................................បានប្រគល់លិខិត ជូនដំណឹង
នេះដល់ឈ្មោះ...................................
ទីលំនៅភូមិ.............................ឃុំ..........................ស្រុក
...............................ខេត្ត.............................
នៅថ្ងៃទី.....ខែ...........ឆ្នាំ.........ផ្ទាល់ដៃរួចហើយ ។
ធ្វើនៅថ្ងៃទី............ខែ.................ឆ្នាំ២០....
អ្នកទទួល អ្នកប្រគល់